

គណៈកម្មាធិការនៃអង្គការ
មិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់
ទម្រង់នៃការរើសអើងស្ត្រីភេទ

THE CAMBODIAN NGO
COMMITTEE ON CEDAW

# របាយការណ៍ស្រមោល ឆ្នាំ២០១៣

## ការវាយតម្លៃពីការវិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្ត អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់ រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

# គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)

អ៊ិន ជី អូ ស៊ី-ដវ (NGO-CEDAW) គឺជាសម្ពន្ធ័នៃអង្គការមិនមែនរដ្ឋាភិបាលចំនួន ៩០ ដែលបំពេញការងារដើម្បីឧត្តមប្រយោជន៍របស់ស្ត្រី ។

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (អ៊ិនជីអូ ស៊ីដវ) បង្កើតឡើងនៅឆ្នាំ១៩៩៥ ដោយមានការគាំទ្រពីការិយាល័យឧត្តមស្នងការ អង្គការ សហប្រជាជាតិស្តីពីសិទ្ធិមនុស្សប្រចាំកម្ពុជា។ គណៈកម្មាធិការនេះបង្កើតឡើងជាលើកដំបូង ដោយមាន សមាជិកចំនួនតែ ៩ អង្គការ មកដល់សព្វថ្ងៃនេះមានសមាជិករហូតដល់ទៅ ៩០ អង្គការ។ គោលដៅចំបងរបស់ NGO-CEDAW គឺធ្វើការតាមដាន និងផ្តល់នូវរបាយការណ៍ឯករាជ្យ ស្តីពីដំណើរការអនុវត្តអនុសញ្ញា ស៊ីដវ នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនាមជាសម្ព័ន្ធនៃអង្គការស្ត្រី សមាជិកនៃ NGO-CEDAW អនុវត្តសកម្មភាពការងារស្ទើរតែគ្រប់វិស័យនៅក្នុងសង្គម ។ សមាជិករបស់ NGO-CEDAW ក៏មានចំណាប់អារម្មណ៍ក្នុងនីតិវិធីបោះឆ្នោត ហើយបានគាំទ្រអ្នកសង្កេតការណ៍បោះឆ្នោត ។

## គោលបំណងនៃNGO-CEDAW

**តាមដាន** វិភាគ និងរាយការណ៍អំពីការអនុវត្តអនុសញ្ញា ស៊ីដវ ពិធីសារបន្ថែម និង សេចក្តីសង្កេតសន្និដ្ឋាន ។

**បោះពុម្ពផ្សាយ**នូវរបាយការណ៍ស្រមោល រាល់ពេលដែលរដ្ឋាភិបាលរាយការណ៍ទៅកាន់គណៈកម្មាធិការទទួលបន្ទុកស៊ីដវ នៃអង្គការសហប្រជាជាតិ ។

**ចូលរួម** នូវរាល់សកម្មភាពនានាទាក់ទងនិងបញ្ហាស្ត្រី និងដឹកនាំការស្វែងរកមតិគាំទ្រ ដើម្បីផ្លាស់ប្តូរ និងភាពរីកចម្រើន ។

ផ្តួចផ្តើមក្នុងការ**ស្រមបស្រមួលការផ្សព្វផ្សាយជាសាធារណៈ** លើបញ្ហាសិទ្ធិស្ត្រី តាមរយៈសារព័តមាន និងយុទ្ធនាការនានា ។

**ស្រមបស្រមួលការផ្លាស់ប្តូរព័តមាន** និងសេវាកម្មនានា ក្នុងចំណោមសមាជិករបស់ NGO-CEDAW និងអង្គការនានា នៅកម្រិតក្នុងស្រុក ថ្នាក់តំបន់ (អេស៊ាន) និងអន្តរជាតិ ។

សម្របសម្រួលវគ្គបណ្តុះបណ្តាលដល់សមាជិករបស់ NGO-CEDAW សង្គមស៊ីវិលនានា និងរដ្ឋាភិបាល ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធាននៃ NGO-CEDAW
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)១២ ៨០២ ៥០៦
អ៊ីមែល: ngocedaw.pnh@gmail.com
គេហទំព័រ:www.ngocedaw.org Facebook: www.facebook.com/ngocedaw

រូបថតនៅគម្រប ជាកម្មសិទ្ធរបស់អង្គការ លីកាដូ

# មាតិកា


| | |
|---|---|
| អារម្ភកថា | ១ |
| សេចក្ដីសង្ខេប | ២ |
| សេចក្ដីផ្ដើម | ៧ |
| ពាក្យបំព្រួញ | ៩ |
| សេចក្ដីផ្ដល់មតិទូទៅ | ១០ |
| មាត្រា ១: និយមន័យនៃការរើសអើងលើស្ត្រីភេទ | ១១ |
| មាត្រា ២: កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើង | ១៣ |
| មាត្រា ៣: ការអភិវឌ្ឍន៍និងភាពរីកចម្រើនរបស់ស្ត្រី | ១៦ |
| មាត្រា ៤: ការពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី | ១៨ |
| មាត្រា ៥: តួនាទីភេទ និងផ្នត់គំនិត | ២០ |
| មាត្រា ៦: អំពើកេងប្រវ័ញ្ចលើស្ត្រី | ២៦ |
| មាត្រា ៧: ជីវភាពនយោបាយ និងជីវភាពសាធារណៈ | ៣៣ |
| មាត្រា ៨: ភាពជាតំណាង និងការចូលរួមនៅលើឆាកអន្តរជាតិ | ៣៦ |
| មាត្រា ៩:សញ្ជាតិ | ៣៧ |
| មាត្រា ១០:ការអប់រំ | ៤០ |
| មាត្រា ១១: ការងារ | ៤៥ |
| មាត្រា ១២: សមភាពក្នុងការទទួលបានការថែទាំសុខភាព | ៥០ |
| មាត្រា ១៣: ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម | ៥៦ |
| មាត្រា ១៤: ស្ត្រីរស់នៅជនបទ | ៥៨ |
| មាត្រា ១៥: ភាពស្មើគ្នាចំពោះមុខច្បាប់ និងក្នុងបញ្ហារដ្ឋប្បវេណី | ៦៥ |
| មាត្រា ១៦:ភាពស្មើគ្នាក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ | ៦៨ |
| អនុសាសន៍ទូទៅ ១៩: អំពើហិង្សាលើស្ត្រី | ៧៣ |

# អារម្ភកថា

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការសហប្រជាជាតិ ដើម្បីស្ត្រី (UNWOMEN) ដែលជាអ្នកគាំទ្រដ៏សំខាន់នៅក្នុងដំណើរការនៃការរៀបចំរបាយការណ៍នេះ ។

សូមអរគុណយ៉ាងខ្លាំងចំពោះជំនួយព្រះវិហារដាឌីម៉ាក និងព្រះវិហារគ្រិស្ត (DCA/CA) ក្នុងការបន្តការគាំទ្រដល់គណៈកម្មាធិការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW) ។

សូមអរគុណជាពិសេសចំពោះអង្គការ សន្តិភាព និងការអភិវឌ្ឍន៍ (PYD) និង អង្គការឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីអន្តរជាតិ អាស៊ីប៉ាស៊ីហ្វិច (IWRAW-AP) ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងប្រឹក្សា ។

សូមថ្លែងអំណរគុណចំពោះអង្គការ សមាគមជាសមាជិក អនុគណៈកម្មាធិការទាំងប្រាំពីរ បុគ្គលិក និងអ្នករាល់គ្នាដែលបានគាំទ្រកម្មវិធីនេះ។

សូមអរគុណជាពិសេសចំពោះ លោកស្រី Binta Niambi សម្រាប់ការរួមចំណែកដ៏ថ្លៃថ្លាក្នុងការដាក់បញ្ចូលគ្នា។ ហើយក៏សូមអរគុណយ៉ាងខ្លាំងដល់ លោកស្រី Eva Galabru និងលោក Tony Posnett ចំពោះការរួមចំណែកដ៏មានសារៈសំខាន់ ។

យើងពិតជាដឹងគុណដ៏ជ្រាលជ្រៅដល់ គណៈកម្មាធិការស្ត្រីកម្ពុជា ( CAMBOW) សម្រាប់ការរួមចំណែកដ៏មានតម្លៃ តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍ កាណាដា (CIDA)។

យើងសង្ឃឹមថា របាយការណ៍នេះនឹងអាចត្រួសត្រាយផ្លូវអោយឈានទៅរកការផ្លាស់ប្តូរ ដើម្បីអោយមានសមភាពរវាងស្ត្រី និងបុរសជាលក្ខខណ្ឌចាំបាច់ ដើម្បីអោយមានការអភិវឌ្ឍន៍សង្គមមួយប្រកបដោយស្ថេរភាពនិងសុខដុមរមនា។

# សេចក្តីសង្ខេប



អ៊ិន ជី អូ ស៊ី-ដវ (NGO-CEDAW) បានរៀបចំរបាយការណ៍ស្រមោលនេះឡើងដោយមានជំនួយគាំទ្រពីក្រុមអ្នកផ្តល់ប្រឹក្សា និងក្រុមមេធាវីអន្តរជាតិជាច្រើនរូប។ សម្ព័ន្ធអង្គការ មិនមែនរដ្ឋាភិបាលចំនួន ៧២ ជាសមាជិកនៃគណៈកម្មាធិការ នៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) បានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបទៅនឹងរបាយការណ៍ របស់រដ្ឋភាគីដែលរៀបចំ ឡើងដោយរាជរដ្ឋា ភិបាលកម្ពុជា "RGC" ស្របទៅនឹងបទប្បញ្ញត្តិ និងលក្ខខណ្ឌនៃអនុសញ្ញាអន្តរជាតិ ស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ "CEDAW" ។

ក្រុមអ្នកសរសេររបាយការណ៍នេះ បានបើកកិច្ចប្រជុំនិងបានធ្វីបទសម្ភាសន៍ជាច្រើនលើកជាមួយសមាជិក អ៊ិន ជី អូ ស៊ី-ដវ ព្រមទាំង ជាមួយអ្នកជំនាញឯកទេសផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីស្ថានភាពរបស់ស្ត្រី និងកុមារីកម្ពុជា ហើយបានចុះជួបជាមួយក្រុមសហគមន៍នានា និងប្រជាពលរដ្ឋកម្ពុជាផងដែរ។ លើសពីនេះ ក្រុមអ្នកសរសេររបាយការណ៍ បានចុះជួបសម្ភាសន៍ដោយផ្ទាល់នៅតាមមូលដ្ឋានជាច្រើនលើក ដើម្បីគាំទ្រដល់ការស្រាវជ្រាវ និងការអះអាងរបស់ពួកគាត់ដែលបានដាក់បញ្ចូល នៅក្នុងរបាយការណ៍ស្រមោលនេះ។ ក្រុមអ្នកសរសេររបាយការណ៍ក៏បានធ្វើការសិក្សាលើសៀវភៅឯកសារ និងរបាយ-ការណ៍ស្រាវជ្រាវជាច្រើនទៀត ដែលបានរៀបរៀងដោយអ្នកជំនាញឯកទេស និងអង្គការមិនមែនរដ្ឋា-ភិបាលនានា ដែលមានមូលដ្ឋានទាំង នៅក្នុង និងក្រៅប្រទេសកម្ពុជា។

ក្រុមអ្នកសរសេររបាយការណ៍ស្រមោលជួបប្រទះនូវបញ្ហាប្រឈម និងកង្វះខាតជាច្រើនរាប់មិនអស់នៅអំឡុងពេលរៀបចំធ្វើរបាយការណ៍ស្រមោលនេះ។ កម្ពុជាពិតជាប្រឈមនឹងឱនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងឱនភាពនៃសមត្ថ-ភាពផ្នែកច្បាប់ ដែលត្រូវការជាចាំបាច់ក្នុងការផ្តល់នូវការឆ្លើយតបមួយប្រកបដោយភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយតាមលក្ខណៈច្បាប់ទៅនឹងរបាយ-ការណ៍ជាតិរបស់រដ្ឋាភិបាលកម្ពុជា ដែលជារដ្ឋភាគីនោះ។

ឯកសារផ្លូវការរបស់រដ្ឋាភិបាលនៅមានកំរិតយ៉ាងខ្លាំង និងមានបញ្ហាជាច្រើនផងដែរ។ ការពុំមានទិន្នន័យរបស់រដ្ឋាភិបាល ច្បាស់លាស់ និងតួលេខបញ្ជាក់ធ្វើឲ្យមានការលំបាកយ៉ាងខ្លាំង ក្នុងការវាយតម្លៃ ទៅលើការរីកចម្រើនរបស់រដ្ឋាភិបាលកម្ពុជា

ក្នុងការអនុវត្តតាមអនុសញ្ញា ស៊ី-ដវ ។ របាយការណ៍ស្រមោលនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការស្រាវជ្រាវការអង្កេត ដែលផ្អែកលើការពិសោធន៍របស់ក្រុមអ្នកសរសេររបាយការណ៍ សមាជិក អ៊ិន ជី អូ ស៊ី-ដវ និងរបាយការណ៍រួមទាំងភស្តុតាងពីហេតុការណ៍ជាក់ស្តែង របស់អនុគណៈកម្មាធិការរបស់ អ៊ិន ជី អូ ស៊ី-ដវ។

មិនត្រឹមតែមានបញ្ហាប្រឈមជាក់ស្តែង ក្នុងការប្រមូលរបាយការណ៍ប្រភេទនេះ ប៉ុណ្ណោះទេ ថែមទាំងមានឧបសគ្គមួយចំនួន ដែលអ្នកចូលរួមក្នុងការសរសេររបាយការណ៍នេះ បានប្រឈមផងដែរ។ ការគំរាមកំហែង ប្រើអំពើហិង្សាការបៀតបៀន ការចាប់ខ្លួន និងអំពើពុករលួយគ្រប់រូបភាពទាំងអស់ ដែលកើតឡើងយ៉ាងអនាធិបតេយ្យ ពេញទូទាំងប្រទេសកម្ពុជាបានគំរាមកំហែងដល់លទ្ធភាព របស់អ្នកចូលរួម និងលទ្ធភាពរបស់បុគ្គលិក ក្នុងការស្រាវជ្រាវធ្វើសេចក្តីព្រាង និងបង្កើតនូវការឆ្លើយតបមួយឲ្យមានលក្ខណៈច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ។ការគំរាមកំហែងទាំងនេះ មានការកើនឡើង នៅអំឡុងពេល និងក្រោយពេលបោះឆ្នោតជាតិ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ មិនតែប៉ុណ្ណោះការគំរាមកំហែងទាំងនេះ ក៏ធ្វើឲ្យកាត់ បន្ថយនូវសន្ទុះនៃការស្ម័គ្រចិត្តក្នុងការផ្តល់ និងធ្វើបទសម្ភាសន៍ ព្រោះអ្នកទាំងនោះមិនហាននិយាយដោយស្មោះត្រង់ និងនិយាយដោយ សេរី ដោយសារមានភាពភ័យខ្លាចនឹងការចងគំនុំ ព្យាបាទ ឬ មានការភ័យខ្លាចនឹងការទទួលគ្រោះថ្នាក់ណាមួយ ដែលធ្ងន់ធ្ងរជាងការចងគំនុំព្យាបាទនេះទៅទៀត។

បើទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ជាផ្លូវការ និងជារដ្ឋភាគីនៃអនុ សញ្ញា ស៊ី-ដវ នេះក៏ដោយ និងបើទោះបីជា រាជរដ្ឋាភិបាលបានអះអាងថា រដ្ឋាភិបាលបានគោរពតាមនិយមន័យនៃការរើសអើង ដែលបានប្រកាសឲ្យប្រើនៅក្នុងអនុសញ្ញា ស៊ី-ដវ ក៏ដោយ ក៏ការរើសអើងដែលមានលក្ខណៈជាប្រព័ន្ធទៅ លើស្ត្រី និងកុមារីនៅតែបន្តកើតមាននៅទូទាំងប្រ ទេ ស កម្ពុជាទាំងតាមផ្លូវច្បាប់និងទាំងការអនុវត្ត ជាក់ស្តែងដោយផ្អែកលើកត្តាសេដ្ឋកិច្ច វប្បធម៌ សង្គម និងកត្តានយោបាយ។ យើងជឿជាក់ថាបញ្ហា រើសអើងនេះ នៅតែបន្តកើតមានដោយសារតែមួយផ្នែក បណ្តាលមកពីការពុំ មាននិយមន័យច្បាស់លាស់នៃការរើសអើងដូចបានចែងនៅក្នុងអនុសញ្ញា ស៊ី-ដវ ដាក់បញ្ចូលទៅក្នុងច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាទាំងឡាយ របស់ប្រទេសកម្ពុជានៅឡើយ និងមួយផ្នែកទៀតបណ្តាលមកពីភាពស្ទាក់ស្ទើរនៃក្រុមមន្ត្រីរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធិភាព អំពីគុណតម្លៃ សិទ្ធិ និងឱ កាសផ្សេ ងៗ ដែលត្រូវបានបកស្រាយដោយអនុសញ្ញាស៊ី-ដវទៅដល់សង្គមស៊ីវិលនៅគ្រប់កម្រិត។




រូបថត លីកាដូ

ជាលទ្ធផលវិធានការអនុវត្តប្រឆាំងនឹងការរើសអើងមួយចំនួន ដែលរដ្ឋាភិបាលបានបង្កើតឡើងនោះ ឃើញថា ការអនុវត្ត និងការប្រើប្រាស់នូវច្បាប់ បទប្បញ្ញត្តិនិងគោលនយោបាយទាំងនេះមានកម្រិតតិចតួច ឈានទៅដល់កម្រិតគ្មាន ការអនុវត្ត និងគ្មានការប្រើប្រាស់ទាល់តែសោះ ដែលប្រការនេះ មិនមែនជារឿងភ្ញាក់ផ្អើលនោះទេនៅកម្ពុជា ព្រោះថាប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ តែងតែជាបញ្ហាចោទ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកិច្ចខិតខំប្រឹងប្រែងមួយចំនួន ដើម្បីដោះសាយរាល់ទម្រង់នៃការរើសអើងលើស្ត្រី និងកុមារី និងដើម្បីដោះស្រាយបញ្ហាវិសមភាពរបស់ស្ត្រី និងកុមារី ដែលបន្តកើតមានជាយូរមកហើយនៅទូទាំងសង្គមកម្ពុជា។ កិច្ចប្រឹងប្រែងនានាដែលមានកម្រិតតិចតួច ត្រូវបានបង្កើតឡើងក្នុងបទប្បញ្ញត្តិ បទបញ្ជា គោលនយោបាយ ច្បាប់ និងកម្មវិធី ផ្សេងៗជាច្រើន ដែលបានតាក់តែងឡើងដោយស្ថាប័នខុសៗគ្នារបស់រដ្ឋាភិបាលកម្ពុជា។ មិនតែប៉ុណ្ណោះដោយសារអំពើពុករលួយ ដែលមានសភាពត្រាំត្រែងនៅក្នុងជួររដ្ឋាភិបាល និងប្រព័ន្ធច្បាប់ បានធ្វើឲ្យច្បាប់បង្កើតឡើងក្នុងគោលបំណងកាត់បន្ថយការរើសអើង និងដើម្បីបង្កើនសមភាពរបស់ស្ត្រី និងកុមារី ឃើញថា កម្រត្រូវបានយកទៅអនុវត្តណាស់ បើទោះជាយកទៅអនុវត្តក៏មិនត្រូវបានជំរុញឲ្យប្រើប្រាស់ច្បាប់ទាំងនេះដែរ។ ប្រជាពលរដ្ឋកម្ពុជា មិនសូវមានការយល់ដឹងច្រើនអំពីសិទ្ធិ សេរីភាព និងកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងច្បាប់ទាំងនេះ នៅ ឡើយ ជាពិសេសនោះប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ជនបទ ដែលមានប្រជាពលរដ្ឋរស់នៅចំនួន ៨០ ភាគរយ នៃចំនួនប្រជាពលរដ្ឋសរុប។ អាជ្ញាធរមូលដ្ឋាន ដែលជាធម្មតាជាអ្នកទទួលខុសត្រូវ ក្នុងការដាក់ឲ្យអនុវត្តច្បាប់ទាំងនេះ បែរជាពួកគាត់ខ្វះទាំងការយល់ដឹង និងខ្វះទាំងការបណ្តុះបណ្តាលអំពីច្បាប់ និងវិធីការផងដែរ។ នៅក្នុងករណីខ្លះ បើទោះបីជាអាជ្ញាធរទាំងនេះ មានការយល់ដឹងក៏ដោយ ក៏អាជ្ញាធរទាំងនេះជារឿយៗងាយនឹងទទួលយក ទម្រង់នៃអំពើពុករលួយខុសៗគ្នា ហេតុដូច្នេះ អាជ្ញាធរទាំងនេះ ហាក់ពុំសូវជំរុញឲ្យមានការប្រើប្រាស់ច្បាប់ និងគោលនយោបាយទាំងនេះទេ បើទោះជាជាក់ស្តែង អាជ្ញាធរទាំងនេះ មានការយល់ដឹងអំពីច្បាប់ និងគោល - នយោបាយទាំងនេះក៏ដោយ។

ស្ត្រី និងកុមារីនៅក្នុងប្រទេសកម្ពុជា ជាទូទៅមានការអប់រំតិចជាងបុរស និងក្មេងប្រុស។ អនុបាតរបស់ក្មេងស្រីធៀបនឹងក្មេងប្រុស មានទំហំប្រហាក់ប្រហែលគ្នានៅកម្រិតអប់រំថ្នាក់ទាប ក៏ប៉ុន្តែមានគម្លាតកាន់តែធំនៅកម្រិតថ្នាក់អប់រំកាន់តែខ្ពស់។

នៅកម្ពុជា ស្ត្រីមិនមានឱកាសការងារ ដូចបុរសនោះទេ ដោយសារតែមួយផ្នែកបណ្តាលមកពីការអប់រំ របស់ពួកគេមានកម្រិតទាបជាងគ្នាខ្លាំង ក៏ប៉ុន្តែមួយផ្នែកទៀត ក៏បណ្តាលមកពីការប្រកួតប្រជែង និងការ អនុវត្តផ្សេងៗដែលមានលក្ខណៈជាប្រព័ន្ធផងដែរ។ទម្លាប់ដែលកើតចេញពីបញ្ហាខាងលើនេះ ធ្វើឲ្យមនុស្សទាំងពីរភេទ បន្តបង្កើតជំនឿ និងទស្សនៈទៅលើស្ត្រីនៅក្នុងប្រទេសកម្ពុជា។ ជាឧទាហរណ៍ ស្ត្រីហាក់ពុំសូវបានចូលរួមនៅក្នុងតួនាទីថ្នាក់ដឹកនាំនៅក្នុងជីវភាពសាធារណៈ និងជីវភាពនយោបាយនោះទេ។ ភាគរយខ្ពស់បំផុតនៃចំនួនស្ត្រីធ្វើការនៅក្នុងវិស័យការងារក្នុងប្រព័ន្ធ គឺនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ដែលជារឿយៗអ្នកទាំងនេះ ទទួលរងនូវការអនុវត្តប្រកបដោយការរើសអើងជាច្រើនមកលើខ្លួន។ ស្ថានភាពនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ មានលក្ខណៈមិនល្អ ដោយមានប្រាក់ឈ្នួលទាប លក្ខខណ្ឌការងារគ្មានសុវត្ថិភាព និងមានការបៀតបៀនផ្លូវភេទផងដែរ ដែលអំពើបៀតបៀនផ្លូវភេទនេះ ជាបញ្ហាមួយនៅក្នុងចំណោមបញ្ហានៃការរំលោភសិទ្ធិមនុស្ស និងការរំលោភសិទ្ធិការងារធ្ងន់ធ្ងរផ្សេងទៀត។

ស្ត្រីកាន់តែងាយទទួលរងគ្រោះ និងងាយទទួលរងការរើសអើងមកលើខ្លួន នៅក្នុងទម្រង់នៃការជួញដូរមនុស្ស ការជួញដូរផ្លូវភេទ និងការធ្វើពេស្យាកម្ម ដែលអំពើទាំងអស់នេះ ជាឧស្សាហកម្មរកប្រាក់ចំណូលបានយ៉ាងច្រើន នៅក្នុងប្រទេសកម្ពុជា។ អ្នកបម្រើការងារក្នុងឧស្សាហកម្មផ្តល់សេវាកំសាន្តក៏ទទួលរងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច និងការ រើសអើង ដែលអំពើទាំងនេះបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រី ដែលជាជនរងគ្រោះទាំងនោះ។ ច្បាប់ប្រឆាំងនឹងអំពើទាំងនេះមិនត្រូវបាន



យកទៅប្រើប្រាស់នោះទេ ជារឿយៗគេឃើញមានការចោទប្រកាន់ (ដោយមិនទាន់មានភស្តុតាងមកសំអាង) ទៅលើអាជ្ញាធរថាបានចូលរួមចំណែក នៅក្នុងឧស្សាហកម្មនេះ ដោយអាជ្ញាធរទាំងនេះក៏ជាអ្នកប្រើប្រាស់សេវា និងជាអ្នកទទួលបានសំណូក ឬមួយក៏ជាអ្នកទទួលបានផលប្រយោជន៍ពីការចូលដៃនៅក្នុងឧស្សាហកម្មផ្លូវភេទនៅកម្ពុជា។ ស្ត្រីក៏ត្រូវបានគេរើសអើងមកលើខ្លួនផងដែរនៅក្នុងបញ្ហាអាពាហ៍ពិពាហ៍ ដោយស្ត្រីត្រូវបង្ខំទទួលយកអាពាហ៍ពិពាហ៍តាមការទុកដាក់ពីអាណាព្យាបាល ព្រមទាំងបញ្ហាដែលមានកូនក្រមុំស្ថិតក្នុងវ័យកុមារផងដែរ នេះជាបញ្ហាដែលកំពុងកើតមាននៅកម្ពុជា។ ស្ត្រីប្រឈមនឹងបញ្ហាលំបាក ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ដោយសារតែមួយផ្នែកបណ្ដាលមកពីភាសាដែលប្រើនៅក្នុងច្បាប់ ដែលចែងអំពីការរំលាយចំណងអាពាហ៍ពិពាហ៍មានលក្ខណៈរើសអើង។

ស្ត្រីជន ជាតិដើមភាគតិច នៅទូទាំងប្រទេសកម្ពុជាទទួលរងទម្រង់នៃការរើសអើងជាច្រើនប្រភេទ ធ្លាក់ក្នុងភាពក្រីក្រ រងគ្រោះពីអំពើហិង្សា ដោយសារខ្វះនូវសិទ្ធិអំណាច នៅក្នុងសហគមន៍របស់ពួកគេ និងនៅក្នុងសង្គមទាំងមូល។ ស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា មានចំនួនប្រមាណ ៥៥,០០០ ទៅ ៧៥,០០០ នាក់។

នៅប្រទេសកម្ពុជា ស្ត្រីវ័យចំណាស់ជួបនូវបញ្ហាប្រឈមខាងផ្នែកសេដ្ឋកិច្ច សង្គម និងសុខភាព និងជួបនូវបញ្ហាខ្វះខាតយ៉ាងខ្លាំង ដោយសារតែបទដ្ឋានយេនឌ័រ បានកំហិត នូវការអប់រំ និងភារកិច្ចរបស់ពួកគាត់ ជាអ្នកថែទាំ និងការចូលរួមរបស់ពួកគាត់នៅក្នុងវិស័យសាធារណៈ។ លើសពីនេះ ការដែលពុំមានកិច្ចគាំពារសង្គម និងការថយចុះនូវទំនៀមទំលាប់ នៃការជួយឧបត្ថម្ភក្រុមគ្រួសារបានបង្កើតជាសម្ពាធ ទៅលើជីវភាពរស់នៅ ចំពោះស្ត្រីវ័យចំណាស់។

របាយការណ៍ ដែលចេញដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការកម្ពុជា "ទិន្នន័យអំពីចំនួនប្រជាពលរដ្ឋ អត្រាកំណើនមនុស្សវ័យចំណាស់នៅកម្ពុជាឆ្នាំ២០១២" បានបង្ហាញការកើនឡើងជាលំដាប់នូវចំនួនប្រជាពលរដ្ឋវ័យចំណាស់ និងបានទទួលស្គាល់ ថាការប្រែប្រួលរចនាសម្ព័ន្ធមនុស្សវ័យ

ចំណាស់នេះ បង្ហាញពីភាពចាំបាច់ចំពោះប្រទេសកម្ពុជា ក្នុងការបង្កើនជំនួយឧបត្ថម្ភផ្នែកសេដ្ឋកិច្ចសង្គម។របាយការណ៍ក៏បានបង្ហាញពីចំនួនស្ត្រីវ័យចំណាស់ ដែលកំពុងមានការកើនឡើង ប្រៀបធៀបនឹងចំនួនបុរស។ អត្រាភេទ (អនុបាត ភេទ) បានបង្ហាញការកើនឡើងក្នុងចំណោមស្ត្រី ១០០ នាក់ មានបុរស ៦៩.១នាក់ នៅឆ្នាំ២០១៨ បុរសនឹង មាន ៦៧.០ នាក់ និងតាមការគណនាឃើញថាបុរស នឹងកើនដល់ ៧៦.៣នាក់ នៅឆ្នាំ២០៣០។

របាយការណ៍នេះ បានបន្ថែមទៀតថា ស្ត្រី វ័យចំណាស់ចំនួនប្រហែល ៤២ ភាគរយជា ស្ត្រីមេ ម៉ាយ បុរសវ័យចំណាស់ចំនួន ១០ ភាគរយជាបុរសពោះម៉ាយ។ សម្រាប់ស្ត្រីមានអាយុ ៨០ឆ្នាំ ឬ អាយុលើសពីនេះភាគច្រើនជាស្ត្រីមេម៉ាយ។ តាមរបាយការណ៍ជា ច្រើនបានបង្ហាញថាភាពជាស្ត្រីមេម៉ាយ និងភាពក្រីក្រដើរទន្ទឹមគ្នាក្នុងចំណោមស្ត្រីវ័យចំណាស់នៅក្នុងប្រទេសកម្ពុជា។

ប្រជាពលរដ្ឋវ័យចំណាស់ នៅក្នុងសង្គមជាទំនៀមទំលាប់ទទួលបានជំនួយឧបត្ថម្ភពីកូនចៅ ឬពីសាច់ញាតិក្នុងក្រុមគ្រួសារដែលរស់នៅជុំគ្នាច្រើន។ កំណើន នៃការធ្វើចំណាក ស្រុករបស់មនុស្សវ័យក្មេង ដោយសារកត្តាសេដ្ឋកិច្ច ធ្វើឲ្យស្ត្រីវ័យចំណាស់មិនទទួលបានការថែទាំដូចពីមុនពីសមាជិកវ័យក្មេងនៅក្នុងគ្រួសារ និងជារឿយពួកគាត់ក្លាយជាបុគ្គលដ៏សំខាន់ក្នុងការមើលថែទាំចៅ គ្រួសារទាំងនេះ គេហៅថាជគ្រួសារផ្លោះជំនាន់ (មានតែចៅៗ និងយាយតា)។

## ៥៥,០០០ ទៅ ៧៥,០០០ នាក់

ស្ត្រីជនជាតិដើមភាគតិច នៅទូទាំងប្រទេសកម្ពុជាទទួលរងនៃការរើសអើង ជាច្រើនប្រភេទធ្លាក់ក្នុងភាពក្រីក្ររងគ្រោះពីអំពើហិង្សា ដោយសារខ្វះនូវសិទ្ធិអំណាច នៅក្នុងសហគមន៍របស់ពួកគេ និងនៅក្នុងសង្គមទាំងមូលស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា។

# សេចក្តីផ្តើម



ប្រទេសកម្ពុជា មានផ្ទៃដីទំហំ១៨១,០៣៥ គីឡូម៉ែតការ៉េ ស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃ វៀតណាម និងឡាវ។ ភ្នំពេញជារាជធានីនៃទេសកម្ពុជា និងមានខេត្តចំនួន ២៤។ ប្រជាពលរដ្ឋសរុបមានចំនួន ១៥,២០៥,៥៣៩ នាក់។ អត្រាមរណភាពរបស់ទារក នៅក្នុងប្រទេសកម្ពុជាមានចំនួន ៥២.៧ ក្នុងចំណោមទារកចំនួន ១,000 ដែល បានប្រសូតមក អត្រានេះ ធ្វើឲ្យប្រទេសកម្ពុជាជាប់ចំណាត់ ថ្នាក់ទី៣៧ នៅលើពិភពលោក។ ការចំណាយទៅលើសុខភាពមានចំនួន ៥.៦% នៃផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា(GDP)។ ការចំណាយទៅលើការអប់រំមានចំនួន ២.៦% នៃផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា(GDP)។ ផ្អែកទៅលើពត៌មានដែល ទទួលបានប្រជាពលរដ្ឋដែលចេះអាន និងចេះសរសេរមានចំនួន ៧៧.៦% នៃចំនួនប្រជាពលរដ្ឋសរុប (ក្នុងនោះ ៨៥.១% ជាបុរស និង ៧០.៩ % ជា ស្ត្រី)។

រាជរដ្ឋាភិបាលកម្ពុជា បានចាប់កំណើតឡើងតាមគោលការណ៍លិទ្ធិប្រជាធិបតេយ្យសេរីពហុបក្សក្រោមរបបរាជានិយមអាស្រ័យ រដ្ឋធម្មនុញ្ញ និងបានអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដែលមានអាយុចាប់ពី ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត នៅក្នុងការបោះឆ្នោតជាតិ។

ប្រទេសកម្ពុជាទទួលបានឯករាជ្យពីប្រទេសបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ អំណាចកំពូលរបស់រដ្ឋ ត្រូវបានបែងចែក ដាច់ដោយឡែកពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (UNTAC) បានរៀបចំការបោះឆ្នោតជាតិលើកដំបូងនៅកម្ពុជា ដែលមានលក្ខណ:សកល សេរី យុត្តិធម៌ និងប្រជាធិបតេយ្យ កាលពីខែឧសភា ឆ្នាំ១៩៩៣។ រដ្ឋសភាជាតិជាលើកដំបូង មានសមាជិកតំណាងរាស្ត្រចំនួន ១២០ នាក់ ដែលមកពីគណ:បក្សនយោបាយជាប់ឆ្នោតចំនួន៤ ខុសៗគ្នាមានដូចជាគណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៥៨ អាសន: គណបក្សប្រជាជនកម្ពុជាទទួលបាន ៥១ អាសន: គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន ១០ អាសន: និងគណបក្សម៉ូលីណាកា ទទួលបាន ១ អាសន:។

រដ្ឋសភាជាតិនៅនីតិកាលទីពីរ បានចាប់ផ្តើមនៅឆ្នាំ១៩៩៨ និងបានបញ្ចប់អាណត្តិនៅ ឆ្នាំ២00៣ ហើយរដ្ឋសភាជាតិនៅនីតិកាលទីពីរនេះ បានបង្កើតឡើង ដោយស្រដៀង ទៅនឹងដំណើរការនៃការបោះឆ្នោតជាសកល។ នៅក្នុងនីតិកាលទីពីរ រដ្ឋសភាជាតិមានសមាជិកតំណាងរាស្ត្រចំនួន ១២២ នាក់ ដែល

ក្នុងនោះមាន ១៤ រូបជាស្ត្រី។ នៅដើមខែមីនា ឆ្នាំ ១៩៩៩ រដ្ឋសភាជាតិបានធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើតអង្គនីតិបញ្ញត្តិផ្សេងមួយទៀត គឺព្រឹទ្ធសភា។ រដ្ឋធម្មនុញ្ញ ដែលបានធ្វើវិសោធនកម្មរួចនេះ បានបង្កើតព្រឹទ្ធសភា ដែលមានសមាជិក ៦១ នាក់ ក្នុងនោះមាន ស្ត្រី ៨ រូប។

ចាប់តាំងពីការបោះឆ្នោតជាតិ ឆ្នាំ១៩៩៣ ស្ថាប័នប្រជាធិបតេយ្យ និងនីតិរដ្ឋត្រូវបានធ្លាក់ចុះយ៉ាងគំហុកដោយសារអំពើពុករលួយ និងដោយសារការប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត។ នៅអំឡុងពេល បោះឆ្នោតជាតិ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅថ្មីៗនេះ បានបង្ហាញថា លទ្ធផលនៃចំនួនអាសនៈមិនខុសឆ្ងាយពីគ្នាច្រើននោះទេ រវាងគណបក្សកាន់អំណាច និងគណបក្សសង្គ្រោះជាតិកម្ពុជា ដែលជាគណបក្សទើបបង្កើតថ្មី ដោយកើតចេញពីការរួមបញ្ចូលគណបក្សសិទ្ធិមនុស្ស ជាមួយនឹងគណបក្សសមរង្ស៊ី។ គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៨ អាសនៈ ដែលនៅក្នុងអាណត្តិមុនទទួលបាន ៩០ អាសនៈលទ្ធផលនេះ បានធ្វើឲ្យ គណបក្សប្រជាជនបាត់បង់ការគ្រប់គ្រងលើអង្គនីតិបញ្ញត្តិ ដែលតម្រូវឲ្យមានសម្លេង ២ ភាគ ៣ នោះ។ គណបក្សសង្គ្រោះជាតិកម្ពុជាបានទទួលអាសនៈចំនួន ៥៥ ហើយគណបក្សនេះ ជឿថា ខ្លួននឹងឈ្នះ សម្លេងភាគច្រើន បើមិនមានការលួចបន្លំ ដែលរងការចោទប្រកាន់ នៅអំឡុងពេលបោះឆ្នោតទេនោះ។ គណបក្សសង្គ្រោះជាតិ និងអ្នកគាំទ្ររបស់ខ្លួនមាន មន្ទិលទៅលើភាពត្រឹមត្រូវ នៃលទ្ធផលបោះឆ្នោត ដោយចោទថាការបោះឆ្នោតនេះ មានភាពខុសប្រក្រតីជាច្រើន ជាអាទិ៍ មានការលួចបន្លំសន្លឹកឆ្នោត និងមានការដកសិទ្ធិអ្នកបោះឆ្នោត នៅតាមតំបន់ជាច្រើន។ អង្គការឯករាជ្យផ្សេងៗ បានរកឃើញថា ចំនួនអ្នកចុះឈ្មោះបោះឆ្នោតលើសចំនួនប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតមួយចំនួន និងមានការចោទប្រកាន់យ៉ាងខ្លាំងលើការចេញកាតសំគាល់អ្នកបោះឆ្នោតទៅឲ្យជនបរទេស ដើម្បីឲ្យពួកគេអាចបោះឆ្នោតបាន។ គណបក្សសង្គ្រោះជាតិកម្ពុជា បានចាញ់ការប្រកួតប្រជែងរបស់ខ្លួន ក៏ប៉ុន្តែស្ថានភាពនៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានសភាពនឹងនៅឡើយ ដោយ សារថា ការតវ៉ា និងការជួបជុំគ្នាផ្សេងៗត្រូវរងការ គំរាមកំហែងមិនតែប៉ុណ្ណោះ ក៏អាចកើតមានអំពើហិង្សាតិចតួចផងដែរ ពាក់ព័ន្ធនឹងការបោះឆ្នោត។

[1] សូមមើល ឯកសារទូទៅរបស់ the CIA World Factbook on Cambodia

# ពាក្យបំព្រួញ

| | |
|---|---|
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CEDAW | អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីភេទ |
| CNCW | ក្រុមប្រឹក្សាជាតិកម្ពុជាសម្រាប់ស្ត្រី |
| CNRP | គណបក្សសង្គ្រោះជាតិ |
| CPP | គណបក្សប្រជាជនកម្ពុជា |
| GMA | សមាគមរោងចក្រកាត់ដេរ |
| GMAG | ក្រុមបញ្ជ្រាបសកម្មភាពផ្នែកយេនឌ័រ |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងព័ត៌មាន |
| MoL | ក្រសួងការងារ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoWA | ក្រសួងកិច្ចការនារី |
| NGO | អង្គការមិនមែនរដ្ឋាមិនមែនរដ្ឋាភិបាល |
| NGO-CEDAW | គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុប បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| PLHIV | អ្នកផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍ |
| PSI | សេវាកម្មប្រជាពលរដ្ឋអន្តរជាតិ |
| RCG | រាជរដ្ឋាភិបាលកម្ពុជា |
| STI | ជំងឺកាមរោគ |
| TBA | ឆ្មបបុរាណ |
| UNTAC | អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |

# សេចក្ដីផ្ដល់មតិទូទៅ

រាជរដ្ឋាភិបាលកម្ពុជានៅក្នុងរបាយការណ៍ជាតិគួបលើកទី៤ និងទី៥ ខែឧសភា ឆ្នាំ២០១០ ស្ដីអំពីការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ នៅក្នុងប្រទេសកម្ពុជាបានធ្វើសេចក្ដីយោងជាក់លាក់ទៅនឹងបទប្បញ្ញត្តិនានានៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា[២] និងក្រមព្រហ្មទណ្ឌកម្ពុជា[៣] ថែមទាំងមានគម្រោងអនុម័តច្បាប់នានាបន្ថែមទៀត ដើម្បីធានានូវសមភាពពេញលេញរវាងស្ត្រី និងបុរសក្នុងការផ្ដល់ការការពារ និងការទទួលបានសិទ្ធិមនុស្ស និងដើម្បីផ្ដល់ការការពារដល់ស្ត្រីពីគ្រប់ទម្រង់នៃការរើសអើង។

ការអនុម័តច្បាប់នានា ដែលធានានូវការការពារស្មើភាពគ្នាដល់ស្ត្រី និងភាពគ្មានការរើសអើង មិនគួរច្រឡំនឹងការផ្ដល់ឲ្យជាក់ស្ដែងនូវសិទ្ធិស្មើគ្នា និងការអនុវត្តដែលគ្មានរើសអើងពិតប្រាកដស្របតាមស្មារតី និងគោលបំណងនៃអនុសញ្ញាស៊ី-ដវ នោះឡើយ។ ក្នុងករណីនេះ មានច្បាប់ បញ្ញត្តិ បទបញ្ជា គោលនយោបាយជាច្រើនរបស់រាជរដ្ឋាភិបាល (រួមទាំងគម្រោងអនុម័តច្បាប់នានា) ឃើញថា ច្បាប់មិនត្រូវបានយកទៅអនុវត្ត ឬប្រើប្រាស់នោះទេ ដែលជាលទ្ធផលបង្ហាញថា ស្ត្រីនៅកម្ពុជាបន្តប្រឈមនឹងភាពអយុត្តិធម៌រាប់មិនអស់រងការប្រព្រឹត្តិមិនស្មើភាពទទួលរងការរើសអើង និងមិនទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ខ្លួន។

[២] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា
[៣] មាត្រា ២៦៥ ដល់ ២៧០ នៃក្រមព្រហ្មទណ្ឌ

# មាត្រា ១:
# និយមន័យនៃការរើសអើងលើស្ត្រីភេទ



រូបថត STAR Kampuchea

ថ្វីត្បិតតែខ្លឹមសារក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" ក៏នៅក្នុងរបាយការណ៍ជាតិមិនបានដាក់បញ្ចូលពត៌មានស្តីពីការជំរុញឲ្យអនុវត្តនូវសេចក្តីសម្រេច ដែលធានាដោយរដ្ឋធម្មនុញ្ញដែលអាចនិយាយបានថាច្បាប់នេះមិនត្រូវបានយកមកប្រើប្រាស់នោះទេ ហេតុដូច្នេះ ច្បាប់នេះមានឥទ្ធិពលតិចតួចណាស់ទៅលើជីវភាពរស់នៅរបស់ស្ត្រីកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងបន្ថែមទៀតថា រដ្ឋាភិបាលពឹងផ្អែកទៅលើនិយមន័យជាក់ស្តែងនៃពាក្យ "ការរើសអើងលើស្ត្រីភេទដូចដែលបានកំណត់និយមន័យនៅក្នុងអនុសញ្ញា ស៊ីដ-ដវ" ។ ក៏ប៉ុន្តែ គេក៏មិនទាន់ឃើញមាននិយមន័យគោល នៃ"ការរើសអើង" ត្រូវបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញនោះទេ ហើយ យើងក៏មិនទាន់ឃើញមានសេចក្តីយោងច្បាប់ជាក់លាក់ទៅ នឹ ងនិយមន័យនៃការរើសអើងក្នុងច្បាប់ណាមួយដែលមានគោលបំណងលុបបំបាត់ការរើសអើងលើស្ត្រីនៅឡើយនោះទេ ។ បច្ចុប្បន្ន ថ្វីត្បិតតែរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ទូទៅនានាដែលហាមឃាត់ មិ នឲ្យមានការរើសអើងលើស្ត្រីដោយផ្អែកលើភេទរបស់ពួកគេ ក៏ប៉ុន្តែតាមការសិក្សាវាយតម្លៃរបស់ អ៊ិនជីអូ ស៊ីដ-ដវ លើច្បាប់ បទប្បញ្ញត្តិ ឬគោលនយោបាយ យើងក៏មិនទាន់ឃើញមានសេចក្តីយោងជាក់លាក់ ឬច្បាស់លាស់ណាមួយ ទៅនឹងមាត្រា ១ នៃអនុសញ្ញា ស៊ីដ-ដវ ដែលកំណត់និយមន័យនៃរើសអើងលើស្ត្រីនោះដែរ។ និយមន័យនៃការរើសអើងលើស្ត្រី គឺសំដៅលើការបែងចែក ការផាត់ចេញ ឬការរឹតត្បិត

## អនុសាសន៍:

- ធ្វើវិសោធនកម្ម ច្បាប់ បទប្បញ្ញត្តិ បទបញ្ជា គោលនយោបាយទាំងអស់ ដើម្បីដាក់បញ្ចូលនិយមន័យនៃ "ការរើសអើង" ឲ្យបានច្បាស់លាស់ ដែលប្រកាសឲ្យប្រើ ដោយគណៈកម្មាធិការ ស៊ីដ-ដវ ។
- ផ្សព្វផ្សាយនិយមន័យ នៃការរើសអើង ក្រោយពីបានធ្វើវិសោធនកម្មរួច និងផ្សព្វផ្សាយការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តអនុសញ្ញា ស៊ីដ-ដវ ដល់បុគ្គលិករបស់រដ្ឋាភិបាលទាំងអស់ ព្រម ទាំងធានាថាពួកគេដឹង និងយល់ពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងការជំរុញឲ្យអនុវត្តនិយមន័យ នៃការរើសអើង ក៏ដូចជាច្បាប់ និងគោលនយោបាយទាំងអស់នឹងការរើសអើងផងដែរ។

ផ្អែកលើភេទដែលមានអនុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកតាមគោលការណ៍ស្មើភាពគ្នារវាងបុរស និងស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្នុង វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យដទៃទៀត។

បើទោះជារាជរដ្ឋាភិបាលកម្ពុជា បានដាក់បញ្ចូលបទប្បញ្ញត្តិប្រឆាំងនឹងការរើសអើងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ព្រហ្មទណ្ឌក៏ដោយ ក៏បទប្បញ្ញត្តិទាំងនោះមិនមានប្រសិទ្ធិភាពនោះដែរ ដោយសារតែបទប្បញ្ញត្តិទាំងនោះ មិនត្រូវបានបញ្ចូលនិយមន័យនៃការរើសអើង ដូចដែលមានចែងក្នុងមាត្រា១ នៃអនុសញ្ញា ស៊ីដ-ដវ នោះនៅឡើយ ហើយដោយសារតែបទប្បញ្ញត្តិទាំងនោះ មិនបានទប់ស្កាត់ផងដែរនូវការរើសអើងដោយផ្ទាល់ និងការរើសអើងដោយអចេតនា (ដោយប្រយោល) លើស្ត្រីភេទ។ម្យ៉ាងវិញទៀត គេមិនឃើញមាន ទិន្នន័យស្តីអំពីការរំលោភបំពានលើមាត្រានានានៃច្បាប់ព្រហ្មទណ្ឌនៅឡើយជាអាទិ៍ថាតើមាត្រាទាំងនោះត្រូវរំលោភបំពានដោយរបៀបណា និងមានប៉ុន្មានករណី។ ពាក្យបណ្តឹងផ្សេងៗមិនត្រូវបានដាក់ប្តឹង និងមិនធ្លាប់បានដាក់ប្តឹងទៅតុលាការ ឬទៅអាជ្ញាធរអនុវត្ត ច្បាប់ផ្សេងទៀតនោះទេ មួយផ្នែកបណ្តាលមកពីអំពើពុករលួយ និងមួយផ្នែកទៀតបណ្តាលមកពីភាពធុញទ្រាន់របស់ប្រជាពលរដ្ឋកម្ពុជាទៅនឹងការដោះស្រាយតាមប្រព័ន្ធច្បាប់។

ដោយសារកង្វះនូវរបាយការណ៍ គេមិនបានដឹងច្បាស់ទេ ថាតើមានស្ត្រីប៉ុន្មានភាគរយ នៅក្នុងប្រទេសកម្ពុជាប្រឈមនឹងការរើសអើងផ្អែកលើ យេនឌ័រនោះដែរ។

- អប់រំសាធារណៈជន អំពីរបៀបដាក់ពាក្យបណ្តឹង នៅពេលដែលសិទ្ធិរបស់ពួកគេ ត្រូវបានរំលោភបំពាន និងបង្កើតយន្តការនានាដើម្បីធានានូវសុវត្ថិភាពដល់ប្រជាពលរដ្ឋ ដែលមករាយការណ៍។
- បង្កើតកម្មវិធីនានា ដែលមានប្រសិទ្ធិភាព ដែលសំដៅលុបបំបាត់ការរើសអើងលើស្ត្រី។

# មាត្រា ២៖
# កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើង




មាត្រា ២ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី "ធ្វើការថ្កោលទោសចំពោះការរើសអើលើស្ត្រីភេទក្នុងគ្រប់ទម្រង់ទាំងអស់" ហើយរដ្ឋភាគី "ព្រមព្រៀងអនុវត្តគោលនយោបាយ លុបបំបាត់ការរើសអើងលើស្ត្រីភេទតាមគ្រប់មធ្យោបាយសម ស្របទាំងអស់ និងដោយឥតពន្យាពេល"។អនុសញ្ញា ស៊ី-ដវ ក៏ ចែងពីកាតព្វកិច្ចក្នុងការចាត់វិធានការដាក់លាក់នានា ដូចជាធ្វើការបញ្ចូលគោលការណ៍សមភាពទៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ ដែលសមស្របឯទៀត។ អនុសញ្ញា ស៊ី-ដវ ក៏ស្នើឲ្យអនុម័តវិធានការសមស្របនានា ដែលហាមឃាត់មិនឲ្យមានការរើសអើងលើស្ត្រីភេទ ដោយបង្កើតកិច្ចការពារផ្លូវច្បាប់ដល់ សិទ្ធិរបស់ស្ត្រី ដោយផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាឲ្យមានកិច្ចការពារដល់ស្ត្រីពីការរើសអើងតាមរយៈសាលាជំរះក្តីជាតិ ដែលមានសមត្ថកិច្ច និងតាមរយៈស្ថាប័នសាធារណៈដទៃទៀត។ អនុសញ្ញា ស៊ី-ដវ ក៏ស្នើឲ្យទប់ស្កាត់ការអនុវត្ត ដែលមានលក្ខណៈរើសអើងលើស្ត្រីភេទ ស្នើឲ្យចាត់វិធានការលុបបំបាត់ការរើសអើងនៅក្នុងសហគ្រាសឯកជន ដើម្បីធ្វើការកែប្រែ ឬលុបបំបាត់ច្បាប់ បទបញ្ជា ទំនៀមទំលាប់ និងការអនុវត្តទាំង ឡាយដែលមានការរើសអើង និងដាក់ឲ្យនិរាករណ៍បទប្បញ្ញត្តិទាំងឡាយណា នៃច្បាប់ព្រហ្មទណ្ឌជាតិ ដែលបង្កើតឲ្យ មានការរើសអើងលើស្ត្រីភេទ។

បើទោះជារាជរដ្ឋាភិបាល បានហា មប្រាមមិនឲ្យមានការរើសអើងលើស្ត្រីភេទដូចមានចែង ក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាល

## អនុសាសន៍៖

- ការរើសអើងឲ្យបានហ្មត់ចត់ទៅលើទៅលើច្បាប់ បទប្បញ្ញត្តិ បទបញ្ជា និងគោលនយោបាយទាំងអស់ ហើយធ្វើការកែប្រែច្បាប់ បទប្បញ្ញត្តិ បទបញ្ជា និងគោលនយោបាយទាំងនោះ ដើម្បីដកចេញនូវពាក្យពេចន៍ណា ដែលមានលក្ខណៈរើសអើងដោយផ្ទាល់ ឬដោយប្រយោលលើស្ត្រីភេទ។
- បង្កើនការយល់ដឹង ដល់សាធារណជនអំពីច្បាប់ និងគោលនយោបាយទាំងឡាយដែលទប់ស្កាត់ការរើសអើង ដោយធ្វើការផ្សព្វផ្សាយ តាមប្រព័ន្ធពត៌មានសង្គម ទូរសព្ទដៃ វិទ្យុ និងតាមរយៈផ្ទាំងប៉ាណូ ដើម្បីធ្វើការអប់រំសាធារណជនជាប្រចាំអំពីសិទ្ធិរបស់ពួកគេ និងអំពីរបៀបស្វែងរកជំនួយនៅពេលដែលពួកគេទទួលរងការរើសអើងមកលើខ្លួន

នៅមិនទាន់បានដាក់បញ្ចូលនិយមន័យ នៃការរើសអើងឲ្យបានជាក់លាក់ និងច្បាស់លាស់ ដូចដែលមានចែងនៅក្នុងមាត្រា ១ នៃអនុសញ្ញា ស៊ី-ដវ នោះនៅឡើយ ហេតុដូច្នេះ ការហាមឃាត់មិនឲ្យមានការរើសអើង ដូចមានចែងក្នុងមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ឃើញថា មិនសូវមានន័យ ឬគ្មានទម្ងន់ផ្លូវច្បាប់នោះទេ។

រាជរដ្ឋាភិបាល បានលើកឡើងពីបទប្បញ្ញត្តិ និងវិធានការផ្សេងៗទៀតដែលរដ្ឋាភិបាលបានអនុម័តកន្លងមក ដើម្បីហាមប្រាមមិនឲ្យមានការរើសអើងលើស្ត្រីភេទ ក៏ប៉ុន្តែខ្លឹមសារជាក់ស្តែងនៅក្នុងបទប្បញ្ញត្តិទាំងនេះ មានបង្កប់លក្ខណៈរើសអើង ជាប់រហូតមក ហើយមិនបានផ្តល់ឲ្យស្ត្រីនូវកិច្ចការពារស្មើភាពគ្នា ឬសិទ្ធិស្មើភាពគ្នានៅក្នុងច្បាប់នោះឡើយ។ ការពិតនោះ គឺថាខ្លឹមសារនៅក្នុងបទប្បញ្ញត្តិមួយចំនួននៅក្នុងវិធានការដែលលើកឡើងនេះ មាន លក្ខណៈរើសអើងស្រេចរួចទៅហើយ។

ម្យ៉ាងទៀត ច្បាប់ទាំងនេះផ្ទាល់តែម្តងមានឥទ្ធិពលតិចតួចណាស់ក្នុងការបញ្ឈប់រើសអើងលើស្ត្រីភេទ។ អំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ និងបញ្ហាខ្វះការយល់ដឹងនៅតាមតំបន់ជនបទ ជាកត្តាធំៗពីរដែលរារាំងបទប្បញ្ញត្តិនានា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញមិនអាចអនុវត្តឲ្យមានប្រសិទ្ធិភាពទៅបាន ឬមិនអាចមានឥទ្ធិពលពិតប្រាកដក្នុងការបញ្ឈប់ការរើសអើងលើស្ត្រីភេទ។

នៅតាមតំបន់ជនបទជាច្រើន ជារឿងធម្មតាទៅហើយដែលច្បាប់ទាំងនេះត្រូវបានមើលរំលង ហើយជារឿយៗមិនត្រូវបានយកទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ឬដល់អាជ្ញាធរដែលទទួលខុស ត្រូវក្នុងការអនុវត្ត និងការដាក់ឲ្យប្រើប្រាស់ច្បាប់ទាំងនេះនោះទេ។ នៅក្នុងករណីខ្លះ អាជ្ញាធរយល់ដឹង ពីច្បាប់ ប៉ុន្តែដោយសារខ្វះនូវឆន្ទះនយោបាយ និងអភិបាលកិច្ច ទន់ខ្សោយ ធ្វើឲ្យពួកគាត់មិនប្រើប្រាស់ច្បាប់ទាំងនេះ នៅពេលដែលស្ត្រីចង់ប្រើប្រាស់សិទ្ធិរបស់ពួកគេ ដូចមានចែងក្នុងច្បាប់នោះ។ នៅក្នុងករណីជាច្រើនបានរាយការណ៍មកថា អាជ្ញាធរ ដែលទទួលខុសត្រូវក្នុងការជំរុញឲ្យអនុវត្តបទប្បញ្ញត្តិនានា ដែលទប់ស្កាត់ការរើសអើងពួកគាត់បែរជាទទួល យកការបង់ថ្លៃក្រៅផ្លូវការ ឬសំណូកជាប្រចាំពីជនជាប់ចោទ ដែលប្រព្រឹត្តអំពើរើសអើង ហើយ ជាលទ្ធផលនោះ បង្ហាញថា បទប្បញ្ញត្តិនានាដែលទប់ស្កាត់ការរើសអើងស្ទើរតែមិនត្រូវបានជំរុញឲ្យអនុវត្តទាល់តែសោះ។ ម្យ៉ាងវិញទៀត នេះមិនមែនជារឿងចំឡែកនោះទេ ដែលចៅក្រមមានភាពលំអៀងទៅខាងបុរសជាងស្ត្រីនៅអំឡុងពេលសវនាការ បញ្ហានេះ កើតឡើង ក៏ដោយសារកត្តាយេនឌ័រផ្ទាល់តែម្តងឬដោយសារបុរសមានលុយច្រើនជាងស្ត្រី ហើយហេតុដូច្នេះ បុរសអាចផ្តល់សំណូកដល់មន្ត្រីតុលាការ។

រាជរដ្ឋាភិបាលបានសរសេរក្នុង របាយការណ៍ជាតិថា រដ្ឋាភិបាល

ឬនៅពេល ដែលសិទ្ធិរបស់ ពួកគេត្រូវបានរំលោភបំពាន។

- ដាក់បញ្ចូលគោលការណ៍យុត្តិធម៌សមភាព និងគោលការណ៍គ្មានការរើសអើងទៅក្នុងកម្មវិធីអប់រំ។
- ពង្រឹង និងជំរុញឲ្យអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ ២០១០ រួមមាន ផ្តល់កិច្ចការពារករាយការណ៍អំពីអំពើពុករលួយ និងបង្កើនការដាក់ទោស ចំពោះការ ប្រព្រឹត្តអំពើពុករលួយ ជាពិសេសផ្តល់ការការពារដល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលសំដៅលុបបំបាត់ការរើសអើងលើស្ត្រី និងកុមារី។
- ផ្តល់សិទ្ធិអំណាច ដល់ក្រសួងកិច្ចការនារី ក្នុងការតាមដានត្រួតពិនិត្យ សកម្មភាពទាំងឡាយរបស់អាជ្ញាធរអនុវត្តច្បាប់ និងស្ថាប័នសាធារណៈនានា ដោយផ្អែកលើគោលការណ៍គ្មានការរើសអើងលើស្ត្រីភេទ
- ដោយប្រើប្រាស់ឧបករណ៍សមស្របនានាដូចជាឧបករណ៍តាមដានរបស់ អ៊ិន ជី អូ ស៊ី-ដវ ជាដើម។

បានផ្តល់សិទ្ធិអំណាចដល់ក្រសួងកិច្ចការនារី (MoWA) និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) ដើម្បីតាមដានត្រួតពិនិត្យសកម្មភាពនានា របស់អាជ្ញាធរ និងស្ថាប័នសាធារណៈ ក្នុងការអនុវត្តគោលការណ៍គ្មានការរើសអើងលើស្ត្រីភេទ។ រាជរដ្ឋាភិបាលបានសរសេរបន្ថែមទៀតថា រដ្ឋាភិបាលបានអនុវត្តវិធានការនានា ក្នុងដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីសិក្សាដូចដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ។

ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង បានបង្ហាញថា មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ មិនត្រូវបានអនុវត្ត និងមិនត្រូវបានជំរុញឲ្យប្រើប្រាស់នោះទេ និងមិនតែប៉ុណ្ណោះ វិធានការក្នុងការអនុវត្តគោលនយោបាយបានលើកឡើងក្នុង របាយការណ៍ជាតិនោះ ឃើញថា មានប្រសិទ្ធិភាពតិចតួច រហូតដល់គ្មានប្រសិទ្ធិភាពទាល់តែសោះ ក្នុងការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងលើស្ត្រីភេទ នៅកម្ពុជា។ ម្យ៉ាងទៀត មានភស្តុតាងតិចតួចដែលបង្ហាញថា ក្រសួងកិច្ចការនារី (MoWA) ពិតជាកំពុងធ្វើការត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាពនានារបស់អាជ្ញាធរ និងស្ថាប័នសាធារណៈ ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការរើសអើងលើស្ត្រីភេទ។ បើទោះជាក្រសួងកិច្ចការនារី អាចបង្ហាញថាជាក់ស្តែង ក្រសួងនេះបានធ្វើការឃ្លាំមើលកិច្ចខិតខំប្រឹងប្រែងនានា ក្នុងការកាត់បន្ថយការរើសអើងលើស្ត្រីភេទក៏ដោយ ក៏នេះគ្រាន់តែជាគោលនយោបាយមួយ ដែលមិនសូវមានឥទ្ធិពលពិតប្រាដក ពីព្រោះថា បើគ្រាន់តែជាការតាមដានត្រួតពិនិត្យធម្មតាៗ ទៅលើសកម្មភាពដោយមិនមានការចែង និងការអនុវត្តឲ្យបានច្បាស់លាស់នូវវិធានការគោលនយោបាយក្នុងការបញ្ឈប់ការរើសអើងនេះទេនោះ គឺជារឿងដែលមិនសូវមានន័យ។

ថ្វីត្បិតតែអនុសញ្ញា ស៊ីដ-ដវ មិនបានតម្រូវឲ្យគិតគូរ ឬពិភាក្សាដាច់ដោយឡែកអំពីស្ត្រីជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍របស់រដ្ឋភាគីក៏ដោយ ក៏គួរកត់សំគាល់ថា កាតព្វកិច្ច ក្នុងការលុបបំបាត់ការរើសអើងលើស្ត្រី ភេទបានស្នើឲ្យធ្វើការពិភាក្សាជាក់លាក់ តែទៅលើស្ត្រីជនបទ និងស្ត្រីរស់នៅតំបន់ជនបទ ក៏ប៉ុន្តែដោយត្រង់បែរជាមិនបានទទួលស្គាល់ស្ត្រីជនជាតិដើមភាគតិច។ តាមការប៉ាន់ប្រមាណជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា មានប្រហែល ១% នៃចំនួនប្រជាពលរដ្ឋសរុប (ស្ត្រីជនជាតិដើមភាគតិចមានចំនួន ចាប់ពី ៥៥,000 ទៅ ៧៥,000 នាក់)។ សិទ្ធិ សម្ភូហភាព តម្រូវការ និងផលប្រយោជន៍របស់ស្ត្រីជនជាតិដើមភាគតិច និងការរើសអើង ដែលកំពុងបន្តកើតមានមកលើពួកគាត់ដោយផ្ទាល់នោះ គួរត្រូវ បានទទួលស្គាល់ និងត្រូវចាត់ជាក្តីកង្វល់ដែលគួរធ្វើការដោះស្រាយជាបន្ទាន់។


រូបថត លីកាដូ

# មាត្រា ៣៖
# ការអភិវឌ្ឍន៍ និងភាពរីកចម្រើនរបស់ស្ត្រី



មាត្រា ៣ នៃអនុសញ្ញា ស៊ីដវ តម្រូវឲ្យរដ្ឋភាគីនៃអនុសញ្ញានេះចាត់នូវ "រាល់វិធានការសមស្របនានា...ក្នុងការបង្កើនការអភិវឌ្ឍន៍ និងភាពរីកចម្រើនរបស់ស្ត្រីឲ្យបាន ពេញលេញដើម្បីធានាថាស្ត្រីអាចប្រើប្រាស់និងទទួលបានសិទ្ធិមនុស្ស ព្រមទាំងសេរីភាពជាមូលដ្ឋាន ផ្អែកលើគោលការណ៍ស្មើភាពគ្នានឹងបុរស"។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារខាងផ្នែកបញ្ជ្រាបយេនឌ័រ ដើម្បីឆ្លើយតបទៅនឹងមាត្រា ៣ នៃអនុសញ្ញា ស៊ីដវ។ នៅក្នុងឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមបង្កើតកម្មវិធីមួយដែលមានឈ្មោះថា សិលា នៅថ្នាក់មូលដ្ឋានក្នុងគោលបំណង អនុវត្តគោលនយោបាយនានាសំរាប់កាត់បន្ថយភាពក្រីក្រ និងបង្កើនអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន ព្រមទាំងអនុវត្តវិធានអប់រំតាមរយៈការបញ្ជ្រាបយេនឌ័រផងដែរ។

យន្តការ នៃការបញ្ជ្រាបយេនឌ័រមានតែមួយដែលប្រើ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងមុខតំណែងជាថ្នាក់ដឹកនាំ។ ក្រសួងយុត្តិធម៌ បានធ្វើការពិនិត្យសើរើឡើងវិញលើច្បាប់មួយចំនួន ដើម្បីកំណត់នូវភាពស្របគ្នាទៅនឹងអនុសញ្ញា ស៊ីដវ ។ ក្នុងចំណោមច្បាប់ ទាំងនេះក៏មានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារផងដែរ តែច្បាប់នេះបានចែងបទប្បញ្ញត្តិមួយចំនួន ដែលធ្វើឲ្យស្ត្រីមានសិទ្ធិតិចជាងបុរស។ រដ្ឋាភិបាលក៏កំពុងរៀបចំសេចក្តីព្រាងច្បាប់ផ្សេងៗផងដែរ ក្នុងគោលបំណងធ្វើឲ្យស្ថានភាពរបស់ស្ត្រីបានប្រសើរឡើង។

រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថាអាជ្ញាធរមូលដ្ឋានបានបើកវគ្គបណ្តុះបណ្តាលជាច្រើន ស្តីអំពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុង គ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ក៏ប៉ុន្តែពាក់ព័ន្ធនឹងចំនួនវគ្គបណ្តុះបណ្តាល គេមិនបានដឹងច្បាស់នោះទេថាតើជាក់ស្តែងវគ្គបណ្តុះបណ្តាលទាំងនេះ បានបើកប៉ុន្មានដង ហើយយើងក៏មិនទាន់បានរកឃើញទិន្នន័យ ដែលបញ្ជាក់អំពីប្រសិទ្ធិភាពនៃវគ្គបណ្តុះបណ្តាលទាំងនេះនៅឡើយដែរ។ ប្រការដែលគ្មានការទប់ស្កាត់ធ្វើឲ្យ

# មាត្រា ៤៖ ការពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី



មាត្រា ៤ នៃអនុសញ្ញា ស៊ី-ដវ អនុញ្ញាតឲ្យរដ្ឋភាគីនៃអនុសញ្ញានេះ បង្កើតចំណាត់ការជាវិជ្ជមានបណ្ដោះអាសន្នព្រមទាំងគោលនយោបាយ និងការអនុវត្តផ្សេងៗទៀត ដើម្បីធ្វើការពន្លឿនសមភាពពិតប្រាកដរវាងស្ត្រី និងបុរសនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។រាជរដ្ឋាភិបាលបានលើកឡើងថា រដ្ឋាភិបាលបានធ្វើការវាយតម្លៃជាបន្តបន្ទាប់ លើវិធានការចាំបាច់នានា ដើម្បីពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី ដោយធ្វើការដកស្រង់នូវគោលនយោបាយដូចមានរៀបរាប់ នៅក្នុងឃ្លាខាងរោម ដែលជាសាក្ខីកម្មនៃចំណាត់ការវិជ្ជមានរបស់រដ្ឋាភិបាល ក្នុងការពន្លឿនឲ្យមានសមភាពនោះថា "រាជរដ្ឋាភិបាលកម្ពុជានឹងចាត់វិធានការនានា ដើម្បីធ្វើឲ្យមានការចូលរួមរបស់ស្ត្រីបានដល់កម្រិតអតិបរមា ក្នុងស្ថាប័នរដ្ឋនៅគ្រប់កម្រិត គឺចាប់ពីស្ថាប័នរដ្ឋបាលថ្នាក់ជាតិដល់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។"

រាជរដ្ឋាភិបាល បានលើកឡើងពីចំណាត់ការជាច្រើនផ្សេងទៀត ដែលរដ្ឋាភិបាលបានអនុវត្តកន្លងមកក្នុងការពន្លឿនសមភាពរបស់ស្ត្រីនៅក្នុងជួររដ្ឋាភិបាលចំណាត់ការទាំងនោះ រួមមានការកំណត់កូតាជាច្រើនផ្សេងៗគ្នាដល់បេក្ខជនជាស្ត្រី សម្រាប់មុខតំណែងនៅក្នុងក្រសួងផ្សេងៗជាច្រើន។ រាជរដ្ឋាភិបាលបានតែងតាំងស្ត្រីចំនួន ២៤ រូបឲ្យកាន់មុខតំណែងជាអភិបាលរងខេត្ត-ក្រុង ក្នុងឆ្នាំ២០០៩ ហើយនៅឆ្នាំ២០០៩ នេះដែរមាន ស្ត្រីចំនួន ១៨៧ រូប ត្រូវបានតែងតាំងជាអភិបាលរងខេត្ត-ក្រុង

**បច្ចុប្បន្ន មានស្ត្រីមួយចំនួនមានមុខតំណែងនៅក្នុងជួររាជរដ្ឋាភិបាលក្នុងនោះរួមមាន៖**

**១**

រូបជាឧបនាយករដ្ឋមន្ត្រីជាស្ត្រី (ក្នុងចំណោមឧបនាយករដ្ឋមន្ត្រី ៩ រូប។ ឧបនាយករដ្ឋមន្ត្រីនៅ ក្នុងរាជរដ្ឋាភិបាលកម្ពុជា គឺជាប្រភេទមុខតំណែងដែលខ្វះនូវអំណាច និងសិទ្ធិអាជ្ញាពិតប្រាកដ)

**២**

រូបជារដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រី នៃក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

**១៤**

រូបជាដ្ឋលេខាធិការ

**២៩**

រូបជាអនុរដ្ឋលេខាធិការ

អំពើហិង្សាក្នុងគ្រួសារមិនត្រឹមតែបន្តកើតមានពេញទូទាំងប្រទេសកម្ពុជាប៉ុណ្ណោះទេហើយការរកឃើញក៏បង្ហាញថា អំពើហិង្សាក្នុងគ្រួសារក៏មានការកើនឡើងផងដែរ ដែលនេះបង្ហាញថា បើទោះបីជាវគ្គបណ្តុះបណ្តាលទាំងនេះបានកើតឡើងក៏ដោយ ក៏ប្រសិទ្ធិភាពមានតិចតួចនៅឡើយ។ម្យ៉ាងវិញទៀត ទស្សនៈតាមបែបប្រពៃណី វប្បធម៌មកលើស្ត្រី នៅមិនទាន់មានការផ្លាស់ប្តូរនៅឡើយ នៅកម្រិតថ្នាក់មូលដ្ឋាន។



រូបថត លីកាដូ

មាត្រា ៤ នៃអនុសញ្ញា ស៊ី-ដវ អនុញ្ញាតឲ្យរដ្ឋភាគីនៃអនុសញ្ញានេះ បង្កើតចំណាត់ការជាវិជ្ជមានបណ្តោះអាសន្នព្រមទាំងគោលនយោបាយ និងការអនុវត្តផ្សេងៗទៀត ដើម្បីធ្វើការពន្លឿនសមភាពពិតប្រាកដរវាង ស្ត្រី និងបុរសនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។រាជរដ្ឋាភិបាលបានលើកឡើងថា រដ្ឋាភិបាលបានធ្វើការវាយតម្លៃជាបន្តបន្ទាប់ លើវិធានការចាំបាច់នានា ដើម្បីពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី ដោយធ្វើការដកស្រង់នូវគោលនយោបាយដូចមានរៀបរាប់ នៅក្នុងឃ្លាខាងរោម ដែលជាសាក្ខីកម្មនៃចំណាត់ការវិជ្ជមានរបស់រដ្ឋាភិបាល ក្នុងការពន្លឿនឲ្យមានសមភាពនោះថា "រាជរដ្ឋាភិបាលកម្ពុជានឹងចាត់វិធានការនានា ដើម្បីធ្វើឲ្យមានការចូលរួមរបស់ស្ត្រីបានដល់កម្រិតអតិបរមា ក្នុងស្ថាប័នរដ្ឋនៅគ្រប់កម្រិត គឺចាប់ពីស្ថាប័នរដ្ឋបាលថ្នាក់ជាតិដល់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។"

រាជរដ្ឋាភិបាល បានលើកឡើងពីចំណាត់ការជាច្រើនផ្សេងទៀត ដែលរដ្ឋាភិបាលបានអនុវត្តកន្លងមកក្នុងការពន្លឿនសមភាពរបស់ស្ត្រីនៅក្នុងជួររដ្ឋាភិបាលចំណាត់ការទាំងនោះ រួមមានការកំណត់កូតាជាច្រើនផ្សេងៗគ្នាដល់បេក្ខជនជាស្ត្រី សម្រាប់មុខតំណែងនៅក្នុងក្រសួងផ្សេងៗជាច្រើន។ រាជរដ្ឋាភិបាលបានតែងតាំងស្ត្រីចំនួន ២៤ រូបឲ្យកាន់មុខតំណែងជាអភិបាលរងខេត្ត-ក្រុង ក្នុងឆ្នាំ២០០៩ ហើយនៅឆ្នាំ២០០៩ នេះដែរមានស្ត្រីចំនួន ១៨៧ រូប ត្រូវបានតែងតាំងជាអភិបាលរងខេត្ត-ក្រុង និងអភិបាលរងស្រុក-ខណ្ឌ។ ការបង្កើនចំនួនអភិបាលរងជាស្ត្រី គឺជារឿងចាំបាច់ ព្រោះថា ស្ត្រីមានគំនិតបើកទូលាយច្រើនជាងបុរសនៅក្នុងមុខតំណែងស្មើគ្នា ក្នុងការពិភាក្សាអំពីបញ្ហាស្ត្រី និងកុមារ។ ជាទូទៅអភិបាលរងជាស្ត្រីងាយស្រួលធ្វើការ ចុះជួប និងឆ្លើយ តបទៅនឹងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ជាធម្មតាពួកគាត់តែងតែស្ម័គ្រចិត្តជួយដោយស្ថិតក្នុងតំណែង ដែលអំណាចនៅមានកម្រិត ហើយយោងទៅតាមកត្តានេះក៏ថានេះជាការតំណាងនូវឱកាស ក្នុងការជំរុញឲ្យមានសមភាពកាន់តែប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា។

ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីមានចំនួនប្រមាណ ២០% នៃចំនួនមន្ត្រីរាជការសរុបនៅក្នុងប្រទេសកម្ពុជា។រាជរដ្ឋាភិបាលបានលើកឡើងថា រដ្ឋាភិបាលមានបំណងបង្កើនចំនួនមន្ត្រីរាជ ការស៊ីវិលជាស្ត្រីរហូតដល់ ៥០ ភាគរយ ក៏ប៉ុន្តែបានអះអាងថា គោលដៅនេះ ពិបាកសម្រេចទៅបាន ដោយសារតែកង្វះនូវស្ត្រី ដែលមានចំណេះដឹងគ្រប់គ្រាន់។ ការដែលមិនសម្រេចតាមគោលដៅនេះ បង្ហាញឲ្យឃើញពីភាពចាំបាច់ ក្នុងការផ្តល់ការអប់រំកាន់តែច្រើនបន្ថែមទៀតដល់ស្ត្រី។

ក្រោយពីការបោះឆ្នោត កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ ចំនួនស្ត្រីនៅក្នុងតំណែងសមាជិកសភា នៅសល់តែ ២៥ រូបប៉ុណ្ណោះ ចំនួននេះ បង្ហាញពីការថយចុះនៃចំនួនសមាជិកសភាជាស្ត្រី

## អនុសាសន៍:

- កែលម្អការអប់រំទូទៅដល់ស្ត្រី និងបង្កើតកម្មវិធីបណ្តុះបណ្តាលជាក់លាក់នានា ដែលសំដៅបង្កើនសមត្ថភាពស្ត្រី ដែលមានចំណេះដឹង មិនទាន់គ្រប់គ្រាន់ អាចត្រៀមខ្លួន សម្រាប់មុខតំណែងជាថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល/ផ្នែកសាធារណៈ។
- ឧបត្ថម្ភ និងជំរុញឲ្យមានកម្មវិធីទំនុកបម្រុងដល់ស្ត្រី និងលើកទឹកចិត្តដល់ស្ត្រី ឲ្យឈរឈ្មោះសម្រាប់មុខតំណែងដែលធ្វើការ
- កំណត់កូតា ក្នុងការបង្កើនចំនួនអភិបាលជាស្ត្រី និងផ្តល់ឲ្យស្ត្រីនូវជំនួយនានា ដើម្បីធានាឲ្យមានការតែងតាំងដល់ស្ត្រី។ ធ្វើការផ្លាស់ប្តូរ ទម្រង់ជ្រើសរើសអភិបាល ពីរបៀបជ្រើសតាំងមកជារបៀបបោះឆ្នោត។
- កំណត់កូតា ក្នុងការបង្កើនចំនួនរដ្ឋមន្ត្រីជាស្ត្រី។ ក្រៅពីភាពចាំបាច់ក្នុងការតែងតាំងស្ត្រី ឲ្យក្លាយជារដ្ឋមន្ត្រីនៅក្នុងតួនាទីដែលបម្រើផលប្រយោជន៍ជាក់លាក់ដល់ស្ត្រី ស្ត្រីក៏គួរត្រូវបានតែងតាំងជារដ្ឋមន្ត្រី នៅក្នុងក្រសួងឯទៀតផងដែរ ទោះក្រសួងទាំងនោះមិនធ្វើការផ្តោតជាក់លាក់តែទៅលើយេនឌ័រក៏ដោយ។
- កំណត់កូតាក្នុងការបង្កើនចំនួនស្ត្រីនៅក្នុងកម្មវិធីផ្តល់ការអប់រំជាន់ខ្ពស់។
- កំណត់កូតាសម្រាប់បង្កើនចំនួនសមាជិកសភាជាស្ត្រី។
- ពិនិត្យឡើងវិញលើវិស័យផ្សេងទៀតដែលស្ត្រីមិនទទួលបានភាពស្មើគ្នានឹងបុរស និងអនុវត្តកម្មវិធី និងវិធានការនានាដែលសំដៅពន្លឿនសមភាពរវាងស្ត្រីនឹងបុរស នៅក្នុងវិស័យទាំងនោះ។

# មាត្រា ៥៖
# តួនាទីភេទ និងផ្នត់គំនិត




LICADHO Photo

មាត្រា ៥ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគីចាត់វិធានការសមស្របនានា ដើម្បីលុបបំបាត់នូវភាពលំអៀង និងការអនុវត្តតាមលក្ខណៈប្រពៃណី ដែលផ្អែកលើទស្សនៈ នៃភាពទាបជាង ឬភាពខ្ពស់ជាងនៃភេទទាំងពីរ ឬផ្អែកលើផ្នត់គំនិតដែលកំណត់នូវតួនាទីសំរាប់ស្ត្រីនិងបុរស ព្រមទាំងតម្រូវឲ្យរដ្ឋភាគីធានាថា ការអប់រំគ្រួសារមានដាក់បញ្ចូលផងដែរនូវការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ៣ ដែលជាមុខងាររបស់សង្គម និងការទទួលខុសត្រូវ រួមរបស់បុរសនិង ស្ត្រីក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូនៗ (ប្រការនេះជាកាតព្វកិច្ចរបស់ភេទទាំងពីរ)។

រាជរដ្ឋាភិបាល បានអះអាងថា រដ្ឋាភិបាលកំពុងផ្តល់អាទិភាពខ្ពស់ ក្នុងការជំរុញលើកកម្ពស់ស្ថានភាពស្ត្រី និងតំណែងរបស់ស្ត្រីកម្ពុជាដែលមានគោលបំណងកាត់បន្ថយ ការរើសអើង និងកសាងសមត្ថភាពដល់ស្ត្រីប្រកបដោយនិរន្តរភាព។[៤]

រាជរដ្ឋាភិបាលបាន អះអាងទៀតថា "ស្ត្រីត្រូវតែទទួលបានភាពស្មើគ្នាក្នុងការទទួលបានការថែ ទាំងសុខភាព ការអប់រំ ការអប់រំ វិជ្ជាជីវៈ និងធនធានសេដ្ឋកិច្ចនានា" ហើយទាំងនេះ គឺជាវិធានការ ដែលរាជរដ្ឋាភិបាលបានលើកឡើង ដើម្បីធ្វើការកាត់បន្ថយការរើសអើង និងដើម្បីបង្កើនសមត្ថភាពដល់ស្ត្រី។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែង ស្ត្រីមិនទទួលបានភាពស្មើគ្នានោះទេ នៅក្នុងការទទួលបានធនធានទាំងប៉ុន្មាន ដូចបានពន្យល់បកស្រាយ ដោយរាជរដ្ឋាភិបាលពី ខាងលើនេះ ជាលទ្ធផលបានបង្ហាញថា ដោយសារកង្វះនូវសេវាទាំងនេះ ផ្តល់ដល់ស្ត្រីនាំឲ្យការរើសអើង និងវិសមភាពចំពោះស្ត្រីនឹងនៅតែបន្តកើតមាននៅក្នុងស្ថានភាពកាន់តែពិបាកជាងមុន ហើយការកសាងសមត្ថភាពដល់ស្ត្រីនឹងនៅតែមានការខ្វះខាតដដែល។

រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា "ស្ត្រី

[៤] ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និងលើកទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ នៅកម្ពុជា ៩៥។ ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០ ។

ក៏មានឯករាជ្យ និងមានភាពម្ចាស់ការកម្មសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗ ដូចជាដីធ្លីការចាត់ចែងហិរញ្ញវត្ថុ និងការបញ្ចេញយោបល់ក្នុងការធ្វើសេចក្ដីសម្រេចផ្សេងៗនៅក្នុងគ្រួសារ។"[៥] បច្ចុប្បន្ននេះ នៅប្រទេសកម្ពុជាជាទូទៅ ស្ត្រីមានអំណាចតិចជាងបុរសលើការ ចំណាយ ការងារ និងការធ្វើសេចក្ដីសម្រេចក្នុងគ្រួសារ។[៦] វប្បធម៌កម្ពុជាបានបង្ហាញពីជំនឿជឿជាក់លើសមត្ថភាពរបស់បុរសនៅក្នុងការចាត់ចែងហិរញ្ញវត្ថុគ្រួសារ និងការធ្វើសេចក្ដីសម្រេច តែផ្ទុយមកវិញ ស្ត្រីមិនត្រូវបានគេយល់ថា មានសមត្ថភាពពេញ លេញនៅក្នុងកិច្ចការទាំងនេះឡើយ បើទោះបីជា ៣០% នៃចំនួនគ្រួសារសរុប ស្ត្រីជាអ្នកដឹកនាំក៏ដោយ។[៧]

ករណីអំពើហិង្សាក្នុងគ្រួសារជាច្រើន បណ្ដាលមកពីស្ត្រីហ៊ានធ្វើហួសព្រំដែននៃតួនាទីផ្នត់គំនិតយេនឌ័ររបស់ពួកគេ ករណីនេះកើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ដូចជាករណីមួយនៅខេត្តព្រៃវែង ដែលបុរសជាប្ដីមិនអាចផ្គត់ផ្គង់ជីវភាព គ្រួសារបាន ដូច្នេះស្ត្រីជាភរិយាបានជំរុញឲ្យបុរសនេះធ្វើការ និងរកប្រាក់មកផ្គត់ផ្គង់គ្រួសារ។ បុរសជាប្ដីយល់ថា នេះមិនមែនជាតួនាទីរបស់ប្រពន្ធនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តដូចជានៅក្នុងការជ្រើសរើសមុខរបរសម្រាប់គ្រួសារនោះទេ ហេតុដូច្នេះហើយបុរសរូបនេះ ក៏បានប្រើអំពើហិង្សាក្នុងគ្រួសារ ដើម្បីទុកជាដាក់ទោសដល់ស្ត្រីជាភរិយាដែលហ៊ានធ្វើហួសពីតួនាទីរបស់ខ្លួននោះ។[៨]

ក្រៅពីនេះ ស្ត្រីនៅតែខ្វះសិទ្ធិអំណាចក្នុងការសេចក្ដីសម្រេចចិត្តក្នុងគ្រួសារ បើទោះជាច្បាប់កម្ពុជាបានចែងថា "ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ"[៩] ក៏ប៉ុន្តែស្ត្រីនៅតែត្រូវបានរារាំងពីការដាក់ឈ្មោះខ្លួននៅក្នុងកម្មសិទ្ធិដីធ្លី ដោយសេរី និងដាក់លាក់នៅឡើយ។ ស្ត្រីអាចជាម្ចាស់លើដីធ្លីបាន លុះត្រាតែមានការយល់ព្រមពីស្វាមីរបស់ពួកគេ ប្រការនេះ អនុញ្ញាតឲ្យស្វាមីរបស់ពួកគេមានសិទ្ធិសម្រេចដ៏មានប្រសិទ្ធិភាពទៅលើកម្មសិទ្ធិដីធ្លី និងធ្វើឲ្យច្បាប់កម្ពុជាមិនសូវមានប្រសិទ្ធិភាព។ បន្ថែមពីលើនេះទៀត ស្ត្រីត្រូវ បានសង្គមចាត់ទុកថាមិនមានសមត្ថ ភាពក្នុងការគ្រប់គ្រងការងារនានា ឬចាត់ចែងថវិកាក្នុងមុខរបរធំដុំ/ចំនួនទឹកប្រាក់ច្រើន។[១០] នេះមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ដោយសារថា ស្ត្រីត្រូវបានគេបន្ទាបតម្លៃពីព្រោះស្ត្រីមានតួនាទីមិនសូវមានសារៈសំខាន់ ហើយស្ត្រីក៏ត្រូវបានរារាំងមិនឲ្យធ្វើជាម្ចាស់កម្មសិទ្ធិ ដីធ្លីដែលនេះជាផលវិបាកដែលកើតចេញពីបញ្ហាខាងលើ។

## អនុសាសន៍:

- រាជរដ្ឋាភិបាលកម្ពុជា គួរដាក់បញ្ចូលនិយមន័យ នៃការរើសអើងដែលបានចង នៅក្នុងអនុសញ្ញាស៊ីដ-ដវ ទៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ ព្រមទាំងច្បាប់ និងបទបញ្ញាទាំងអស់ផ្សេងទៀតដែលប៉ះពាល់ដល់ការរស់នៅរបស់ស្ត្រី និងកុមារី។

- ការបង្កើនភាពជាតំណាងរបស់ស្ត្រី នៅក្នុងតួនាទីនយោបាយ នឹងនាំឲ្យមានការផ្លាស់ប្ដូរ ផ្នត់គំនិតយេនឌ័រ និងទស្សនៈទៅលើស្ត្រីកម្ពុជា។ រដ្ឋាភិបាលកម្ពុជា គួរលើកចិត្តស្ត្រីឲ្យឈរឈ្មោះ និងកំណត់ចំនួនស្ត្រីឲ្យបានកម្រិតអប្បបរមា ដែលនឹងត្រូវជាប់ឆ្នោត។ ប្រសិនបើស្ត្រីត្រូវបានគេមើលឃើញថា ស្ត្រីជាអ្នកដឹកនាំ និងជាអ្នកធ្វើសេចក្ដីសម្រេចចិត្ត នោះនឹងអាចផ្លាស់ប្ដូរ ផ្នត់គំនិតនានាដែលផ្ដល់ផលប៉ះពាល់ ជាអវិជ្ជមានដល់ស្ត្រី។

- ការផ្សាយ របស់ទូរទស្សន៍ជាតិ និងវិទ្យុជាតិ គួរធ្វើការផ្សព្វផ្សាយជាប្រចាំ នូវបញ្ហានានាដែលពាក់ព័ន្ធនឹងអនុសញ្ញា ស៊ីដ-ដវ នៅក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងអំពីផ្នត់គំនិតយេនឌ័រ ដែលមានលក្ខណៈអវិជ្ជមាន។ បណ្ដាញព័ត៌មានសង្គម ក៏អាចយកមកប្រើប្រាស់ធ្វើ ជាឧបករណ៍មួយដែលមានប្រសិទ្ធិភាពផងដែរ សម្រាប់ធ្វើការអប់រំពីផ្នត់គំនិតយេនឌ័រ និងភាពលំអៀងទៅលើយេនឌ័រ។ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជានានា គួរសហការជាមួយក្រុមហ៊ុនទូរស័ព្ទចល័តផ្សេងៗ ដើម្បីធ្វើការផ្សព្វផ្សាយឲ្យបានច្បាស់លាស់ ខ្លីហើយមានខ្លឹមសារ ងាយស្រួលយល់

---

[៥] ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី ៤ និងលើកទី៥ ស្ដីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ នៅកម្ពុជា ១៨។ ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០ ។

[៦] "នយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា: ការបង្កើនភាពជាតំណាងរបស់ជាស្ត្រី។" ៣០ មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ខែមីនា ឆ្នាំ២០១៣

[៧] អ៊ិន ជី អូ ស៊ីដ-ដវ បទសម្ភាសន៍ជាលក្ខណៈក្រុម ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៣

[៨] អ៊ិន ជី អូ បទសម្ភាសន៍ជាលក្ខណៈបុគ្គល ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣

[៩] រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា មាត្រា ៤៤

[១០] អ៊ិន ជី អូ ស៊ីដ-ដវ បទសម្ភាសន៍ជាលក្ខណៈបុគ្គល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣

យោងតាមរដ្ឋធម្មនុញ្ញ ស្ត្រីមានសិទ្ធិទទួលបានការឈប់សម្រាកលំហែមាតុភាពដោយទ ទួល បា ន ប្រាក់ឈ្នួលពេញ និងមិនប្រឈមនឹងការបាត់បង់អតីតភាពការងារ ព្រមទាំងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។[១១] ក៏ប៉ុន្តែច្បាប់ការងាររបស់ប្រទេសកម្ពុជា មាត្រា១៨៣បានចែងថា "នៅអំឡុងពេលឈប់សម្រាកលំហែមាតុភាព. . . . ស្ត្រីមានសិទ្ធិទទួលបានប្រាក់ឈ្នួល៥០%។"[១២] រដ្ឋធម្មនុញ្ញកម្ពុជា មិនបានបញ្ជាក់ពីរយៈពេលនៃការឈប់សម្រាក លំហែមាតុភាពនោះទេ ក៏ប៉ុន្តែនៅក្នុងរបាយ ការណ៍ជាតិបានប ង្ហា ញថា "ស្ត្រីមានសិទ្ធិទទួលបានការឈប់សម្រាកលំហែមាតុភាពចំនួន ៩០ ថ្ងៃ ដោយទទួលបានប្រាក់ឈ្នួល ៥០%។"[១៣] នៅក្នុងការអនុវត្តជាក់ស្តែងជារឿយៗ ស្ត្រីត្រូវបានជ្រើសរើសឲ្យបម្រើការងារ ក្នុងកិច្ចសន្យារយៈពេលខ្លី ដែលកត្តានេះ បានផ្តល់ឱកាសឲ្យនយោជកដក់សិទ្ធិរបស់ស្ត្រីពីការទទួលបានអត្ថប្រយោជន៍វិជ្ជាជីវៈផ្សេងៗ ដែលអត្ថប្រយោជន៍ទាំងនេះត្រូវបានផ្តល់ទៅឲ្យស្ត្រី ប្រសិនបើពួកគេស្ថិតក្នុងកិច្ចសន្យាការងាររយៈពេលវែង។ ជាលទ្ធផលដោយសារតែពុំមានច្បាប់ណាមួយ ដែលចែងអំពីការរំលោភបំពានដោយផ្ទាល់លើសិទ្ធិឈប់សម្រាកលំហែមាតុភាពនេះ ហើយទើបផ្តល់ឱកាសឲ្យ នយោជកប្រើប្រាស់កិ ច្ច សន្យាការងាររយៈពេលខ្លី ដើម្បីគេច វេសពីការផ្តល់ប្រាក់ឈ្នួល ពេញដល់ស្ត្រី ដែលនេះ គឺជាការផ្តល់នូវឱកាសគេចចេញពីការទទួលខុសត្រូវ ដ៏ស្របច្បាប់ដែលអនុញ្ញាតឲ្យនយោជកប្រព្រឹត្ត អំពើរើសអើងលើស្ត្រីជាច្រើននាក់ នៅប្រទេសកម្ពុជា ដែលទើបនឹងក្លាយជាម្តាយជាលើកដំបូងនោះ ។[១៤]

បើទោះបីជានៅក្នុងករណី ដែលកិច្ច សន្យាខ្លីមិនត្រូវបានប្រើប្រាស់ ដើម្បីគេចចេញ ពីការអនុវត្តតាមបទប្បញ្ញត្តិ ស្តីពីការឈប់សម្រាកលំហែមាតុភាពក៏ដោយ ក៏កិច្ចការពារ ដែលមានចែងនៅក្នុងបទប្បញ្ញត្តិទាំងនេះមានភាពខ្វះខាតនៅឡើយ ដោយហេតុថា ស្ត្រីជាច្រើនទទួលបានប្រាក់ឈ្នួលមិនគ្រប់គ្រាន់ ដែលពួកគេត្រូវបង្ខំចិត្តត្រឡប់ចូលធ្វើការវិញនៅមុនរយៈពេលកំណត់ នៃការឈប់សម្រាក លំហែមាតុភាព ៩០ ថ្ងៃ ដើម្បីគ្រាន់តែងចិញ្ចឹមជីវិតបន្តទៅទៀតប៉ុណ្ណោះ។ ការចំណាយក្នុងការចិញ្ចឹមកូន និងក្នុងការផ្តល់នូវតម្រូវការមូលដ្ឋាន ជាធម្មតាការចំណាយទាំងនេះមានកម្រិតលើសពាក់កណ្តាលនៃ ចំនួនទឹកប្រាក់ ដែលទទួលបាននៅអំឡុងពេលឈប់សម្រាកលំហែមាតុភាពនោះទៅទៀត ហេតុដូច្នេះ ថ្វីត្បិតមានបទប្បញ្ញត្តិចែងអំពីការឈប់សម្រាកលំហែមាតុភាព នៅក្នុងច្បាប់កម្ពុជាក៏ដោយ ក៏ជាក់ស្តែងជា ការមួយលំបាកចំពោះស្ត្រីភាគច្រើន ដែលរស់ពឹងផ្អែកលើចំនួនទឹកប្រាក់ ដែលទទួលបាននៅអំឡុងពេលឈប់

និងធ្វើបច្ចុប្បន្នភាព អំពីអនុសញ្ញាស៊ីដ-ដវ ព្រ មទាំងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ការរើសអើងឲ្យបានជាប្រចាំតាមប្រព័ន្ធទូរស័ព្ទ។ បន្ថែមពីលើនេះ គួរធ្វើការថ្កោលទោសច្បាប់ ស្រី ហើយបើមិនដូច្នោះទេគួរបញ្ជាក់ឲ្យបានម៉ឺងម៉ាត់អំពីគុណតម្លៃរបស់ស្ត្រី និងកុមារី។

- ផ្តល់ការអប់រំ អំពីអនុសញ្ញាស៊ីដ-ដវ ដល់ក្រុមមន្ត្រីបំរើការងារក្នុងសភាជាតិ និងក្រុមមន្ត្រីអនុវត្តច្បាប់ ដើម្បីជំរុញឲ្យមានការអនុវត្តប្រកប ដោយប្រសិទ្ធិភាពនូវច្បាប់ដែលមានស្រាប់។ ធ្វើការលើកទឹកចិត្ត ដល់ក្រុមមន្ត្រីបំរើការងារ ក្នុងសភាជាតិ និងក្រុមមន្ត្រីអនុវត្តច្បាប់ ឲ្យអនុវត្តនិងដាក់ទណ្ឌកម្មឲ្យបានតឹងតែង និងប្រាកដប្រជាចំពោះអំពើដែលទទួលយកសំណូក។

[១១] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៤៦
[១២] ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណជាតិគួបលើកទី៤ និងលើកទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ៣៧។ ភ្នំពេញកម្ពុជា ខែឧសភា ឆ្នាំ២០១០។
[១៣] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៦៣។
[១៤] អ៊ិន ជី អូ ស៊ីដ-ដវ បទសម្ភាសន៍ជាលក្ខណៈបុគ្គល ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។

សម្រាកលំហែមាតុភាពនោះ។ ដោយហេតុថា បច្ចុប្បន្ននេះ ប្រាក់ឈ្នួលគោល សម្រាប់កម្មកររោងចក្រនៅប្រទេសកម្ពុជាមានត្រឹមតែចំនួន ៨០ ដុល្លារសហរដ្ឋអាមេរិក ហើយប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនគិតជាមធ្យមមានចំនួន ៦៦ ដុល្លារសហរដ្ឋអាមេរិក ដូច្នេះបើទោះបីជាមានការបន្ថែមប្រាក់ឈ្នួល / ប្រាក់បៀវត្សរ៍ពាក់កណ្តាលទៀតក៏ដោយ ក៏នៅតែមិនគ្រប់គ្រាន់សម្រាប់បំពេញតាមសេក្តីត្រូវការជាមូលដ្ឋាននោះដែរ។

ច្បាប់ស្រីជាក្រិតក្រមពីបុរាណរបស់ប្រទេសកម្ពុជាទៅលើស្ត្រីដែលច្បាប់នេះ គឺជាច្បាប់ប្រពៃណី និងមានសរសេរជាលាយ លក្ខណ៍អក្សរផងដែរ ហើយមានប្រភពដើម តាំងពីសត្សវត្តទី ១៩ មកម្លេះ។ នាពេលកន្លង មកច្បាប់ស្រីនេះមានក្នុងកម្មវិធីអប់រំនៅកម្រិតបឋមសិក្សា ដែលធ្វើឲ្យច្បាប់នេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌កម្ពុជា។ ច្បាប់នេះ បានកំណត់ជាក់លាក់នូវភារកិច្ច និងការរំពឹងទុកទៅលើឥរិយាបថរបស់ស្ត្រី។ បើទោះជា មិនមានលក្ខខណ្ឌផ្លូវច្បាប់តម្រូវឲ្យបង្រៀនច្បាប់នេះនៅក្នុងកម្មវិធីសិក្សាតទៅទៀតក៏ដោយ ក៏មនោគមវិជ្ជា ដែលបង្កើតដោយច្បាប់ស្រីនេះ នៅតែមានឥទ្ធិពលពេញទូទាំងវប្បធម៌កម្ពុជា ជាពិសេសនោះ នៅទីជនបទដែលមានប្រជាពលរដ្ឋរស់នៅចំនួន ៨០% នៃចំនួនប្រជាពលរដ្ឋសរុប។ មនោគមនវិជ្ជានេះបានជំរុញឲ្យស្ត្រីស្ថិតក្រោមការបង្គាប់បញ្ជា និងគោរពទៅតាមការចង់បានរបស់ស្វាមីរបស់ពួកគេ ព្រមទាំងមិនឲ្យធ្វើការតវ៉ាទៅនឹងសេចក្តីសម្រេចនានា ដែលស្វាមីរបស់ពួកគេបានកំណត់រួចហើយ។ ការអនុវត្តតាមលក្ខណៈប្រពៃណីវប្បធម៌បែបនេះ មិនជំរុញ លើកទឹកចិត្តឲ្យស្ត្រីក្លាយជាអ្នកចូលរួម ប្រកបដោយភាពស្មើគ្នានៅក្នុងជីវិតគ្រួសារនោះទេ តែផ្ទុយមកវិញការអនុវត្តបែបនេះ បានជួយបន្តអាយុកាលនៃផ្នត់គំនត់ ដែលដាក់ស្ត្រីឲ្យស្ថិតក្នុងសិទ្ធិអំណាចទាបជាងបុរស។[១៥] ឧ. មួយដែលកើតចេញពីឥទ្ធិពលនៃច្បាប់ស្រីនេះ តែម្តងគឺ "បើនាងមិនខ្លាចក្រែងស្វាមីរបស់ខ្លួនជម្លោះនឹងកើតមានកេរ្តិ៍ឈ្មោះ របស់នាងនឹង ធ្លាក់ចុះ ព្រមទាំងបង្កឲ្យមានការបែកបាក់គ្នា។"ឧទាហរណ៍នេះ បង្ហាញច្បាស់ណាស់ថា ឃ្លាដែលបានលើកឡើងខាងលើកំពុងកប់ជ្រៅទៅក្នុងវប្បធម៌កម្ពុជា ដែលជាលទ្ធផលនោះ ធ្វើឲ្យមានវិសមភាព ដោយគ្មានលាក់លៀម និងមានរយៈដ៏យូររវាងបុរស និងស្ត្រី។

រាជរដ្ឋាភិបាលកម្ពុជា បានអះអាងថា បញ្ហាផ្នត់គំនិត និងការយល់ឃើញលើស្ត្រីថាជាភេទតូចទាបនោះ គឺជាបញ្ហាដែល "កំពុងមានការផ្លាស់ប្តូរបន្តិចម្តងៗ" និង "ត្រូវការរយៈ ពេលវែង ព្រមទាំងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថទាំងស្រុង ពាក់ព័ន្ធនឹងសមភាពយេនឌ័រជាពិសេសនោះ នៅតាមតំបន់ជនបទ។"[១៦] ក៏ប៉ុន្តែ នៅក្នុងរបាយការណ៍ជាតិគេពុំឃើញមានការកំណត់នូវគោលដៅ ឧបករណ៍សម្រាប់ធ្វើការវាស់វែង ឬវិធានការណាមួយជាក់លាក់ ដើម្បីធានាថាអ្វីដែលរដ្ឋាភិបាលបានលើកឡើងនេះ កំពុងដំណើរការតាមវិធីសាស្ត្រមួយ ដែលមានប្រសិទ្ធិភាព។ ជាលទ្ធផលនេះជាសេចក្តីថ្លែងមួយ ដែលមិនត្រូវបានយកទៅអនុវត្ត ហេតុដូច្នេះហើយការលើកឡើងនេះទំនង ជានឹងមិនអាចកាត់បន្ថយការរើសអើងលើស្ត្រី និងកុមារីបាននោះទេ។

នៅក្នុងមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសការងារដែលសមស្របទៅតាមសមត្ថភាពរបស់ខ្លួន និងទៅតាមតម្រូវការសង្គម។"យោងតាមបទប្បញ្ញត្តិនេះ បុរស និងស្ត្រីគួរត្រូវបានអនុញ្ញាត និងត្រូវបានលើកទឹកចិត្តឲ្យស្វែងរកការងារ តាមសេចក្តីប្រាថ្នារបស់ខ្លួន និងមិនត្រូវមានការរើសអើងដោយផ្អែកលើភេទនោះទេ។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង បុរសជាអ្នកគ្របដណ្តប់លើសលុបលើការងារវិជ្ជាជីវៈច្រើនបំផុត (ពិសេសនោះការងារ

---

[១៥] "នយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា: ការបង្កើនភាពជាតំណាងរបស់ស្ត្រី ។" ៣០. មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធមនុស្ស ខែមីនា ឆ្នាំ២០១៣។
ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និងលើកទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ។ ២០. ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១៣
[១៦] ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និងលើកទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ។ ២០. ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ ២០១៣។

ដែលប្រើកម្លាំងដោយដៃ) ដែលផ្តល់ប្រាក់ឈ្នួលឲ្យស្ត្រីតិចជាងបុរស ចំពោះការងារដែលមានចំនួនដូចគ្នា។ ការផ្តល់ប្រាក់ឈ្នួលឲ្យស្ត្រីតិចជាងបុរសនេះ គឺកើត មានជាច្រើននៅក្នុងទំហំមួយដ៏ធំ ដោយសារតែការរីករាលដាលនៃជំនឿដែលថា បុរសមានសមត្ថភាពអាចធ្វើការធ្ងន់ៗបាន និងអាចធ្វើការងារដោយប្រើកម្លាំងបានច្រើនជាងស្ត្រី នៅក្នុងរយៈពេលធ្វើការដូចគ្នា ហេតុដូច្នេះ បុរសគួរតែទទួលបានប្រាក់កម្រៃខ្ពស់ជាងស្ត្រី។[១៧]

សរុបជារួមមក រាជរដ្ឋាភិបាលកម្ពុជាពិតជាមានច្បាប់ជាក់លាក់ជាច្រើន ដែលមានឆន្ទះជំរុញឲ្យមានសមភាពរវាងបុរស និង ស្ត្រី នៅក្នុងសង្គម ក៏ប៉ុន្តែច្បាប់ដែលបានអនុម័ត រួចទាំងនេះ ស្ទើរគ្រប់ពេលតែងតែខ្វះព័ត៌មានជាក់លាក់គ្រប់គ្រាន់ ដើម្បីបង្កើតលទ្ធភាពឲ្យមានការអនុវត្តច្បាប់ទាំងនេះទៅបាន។ ការពុំមាននូវការប្រើប្រាស់និយមន័យនៃ "ការរើសអើង" ឬមិនមានឧទាហរណ៍ជាក់លាក់ណាមួយដែលបង្ហាញពី "ការអនុវត្តប្រពៃណីវប្បធម៌ ដែលបង្កផលប៉ះពាល់ជាអវិជ្ជមាន" ហេតុដូច្នេះហើយ ច្បាប់នេះ មិនត្រូវបានយកទៅអនុ វត្ត ឬមិនអាចជំរុញឲ្យប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពបានទេ។[១៨]

---

១៧ អ៊ិន ជី អូ ស៊ី-ដវ បទសម្ភាសន៍ជាលក្ខណៈបុគ្គល ខែឧសភា ឆ្នាំ២០១០។
១៨ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញា ស៊ី-ដវៈ ប្រទេសកម្ពុជា ២. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ខែមករា ឆ្នាំ២០០៦។

# មាត្រា ៦: អំពើកេងប្រវ័ញ្ចលើស្ត្រី



រូបថត Ratanak International

មាត្រា ៦ នៃអនុសញ្ញា ស៊ី-ដរ តម្រូវឲ្យរដ្ឋភាគី "ចាត់វិធានការសមស្របទាំងអស់ រួមទាំងការតាក់តែងច្បាប់ ដើម្បីបង្ក្រាបរាល់ទម្រង់នៃការជួញដូរស្ត្រី និងការធ្វើអាជីវកម្មខាងពេស្យាកម្មលើស្ត្រី។"

មាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញ បានហាមប្រាមនូវការជួញដូរមនុស្ស និងព្យាចារកម្ម ដែលក្នុងមាត្រានេះបានចែងថា "អំពើលក់ដូរមនុស្ស ការធ្វើពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។" ក៏ប៉ុន្តែការ ពន្យល់បកស្រាយបែបនេះមិនមានភាពច្បាស់លាស់នោះទេ មិនច្បាស់នៅត្រង់ថាតើបទប្បញ្ញត្តិនេះត្រូវអនុវត្តទៅលើបុគ្គលណាខ្លះ និងអនុវត្តយ៉ាងដូចម្តេច ឬថាតើមានការដាក់ទោសទណ្ឌ ដែរឬទេ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូរផ្លូវភេទ ពេស្យាកម្ម និងអំពើកេងប្រវ័ញ្ចឯទៀតលើស្ត្រី និងកុមារី។ ច្បាប់ស្តីអំពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវ ភេទ (The TIP LAW) ត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០៨ កាន់តែធ្វើឲ្យមានភាពភាន់ច្រឡំបន្តទៅទៀត។

បើទោះជាមានការបង្កើតនូវអង្គភាពពិសេស ដើម្បីទប់ស្កាត់បទល្មើសផ្លូវភេទ អង្គភាពធ្វើការឃ្លាំមើល គណៈកម្មាធិការ ក្រុមការងារ

## អនុសាសន៍:

- ស្រោមអនាម័យ គួរមានតម្លៃសមរម្យដែលអាច ឲ្យក្រុមអ្នកងាយរងគ្រោះ មានលទ្ធភាពទិញបាន។
- រាជរដ្ឋាភិបាលកម្ពុជា គួរតាក់តែងអនុក្រិត្យមួយ ដើម្បីបកស្រាយ និងបំភ្លឺបន្ថែមលើមាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញ ដើម្បីលុបបំបាត់ នូវភាពមិនច្បាស់លាស់សំរាប់បុគ្គលទាំងឡាយណា ដែលទទួលខុសត្រូវ ក្នុងការអនុវត្តមាត្រានេះ។
- រាជរដ្ឋាភិបាលកម្ពុជាគួរអនុម័តច្បាប់ការពារជនរងគ្រោះ ដើម្បីផ្តល់កិច្ចការពារ ដល់អ្នកបម្រើសេវាកំសាន្ត និងធ្វើការបណ្តុះបណ្តាលអំពីការអនុវត្តច្បាប់ក្នុង

ពិសេសលេខាធិការដ្ឋាន និងគោលនយោបាយនានា ។ល។ ក៏បញ្ហានៃការជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ព្រមទាំង បញ្ហាបន្ទាប់បន្សំដទៃទៀត ដែលពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ ដូចជាការរំលោភសេពសន្ថវៈអំពើហិង្សាលើស្ត្រី ជម្ងឺ ការញៀនស្រា ។ល។ នៅតែបន្តរីករាលដាល។

ការជួញដូរស្ត្រី និងក្មេងស្រីដើម្បីធ្វើពេស្យាកម្ម គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅក្នុងប្រទេសកម្ពុជា។ បើទោះជាមានការកើនឡើងនៃការចុះបង្ក្រាបលើក្រុមអ្នកបើកផ្ទះបន នៅរាជធានីភ្នំពេញក៏ដោយក៏បញ្ហានៅតែបន្តកើតមាន តួយ៉ាង ដូចជា អំពើពេស្យាកម្ម និងអំពើជួញដូរផ្លូវភេទជាដើម។ តាមការប៉ាន់ស្មាននៃចំនួនស្ត្រី ដែលកំពុងបម្រើសេវាកំសាន្តនៅក្នុងរបរនេះ មានប្រហែលពី ១៤,៧២៥ ទៅ ១៨,២៥០ នាក់។[១៩] ទេសចរណ៍ផ្លូវ ភេទជាបញ្ហាមួយដែលមានការកើនឡើងដោយសារតែការរីក រាលដាលនៃភាពក្រីក្រ អំពើពុករលួច និងនិទណ្ឌភាព។

របាយការណ៍មួយចំនួនបានបង្ហាញថា ចំនួនករណីជួញដូរ ផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការប៉ុនប៉ងរំលោភសេពសន្ថវៈនៅប្រទេសកម្ពុជា បានកើនឡើងក្នុងឆ្នា២០១២ បើប្រៀបធៀបនឹងឆ្នាំ២០១១។[២០] លទ្ធផលនេះ បានបង្ហាញពីការទម្លាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានាពេ លថ្មីៗនេះ ក្នុងរបាយការណ៍ ឆ្នាំ២០១៣ ស្តីពីការជួញដូរមនុស្សរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ពីលំដាប់ទី២ (Tier 2 ទៅលំដាប់ថ្នាក់លេខ២ ស្ថិតនៅក្នុងបញ្ជីឃ្លាំមើល (Tier 2 Watch List) ពីព្រោះកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ត្រូវបានគេរាយការណ៍ថា មានការធ្លាក់ចុះជាងឆ្នាំមុន។[២១] របាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានលើកឡើងពីកង្វះនៃការ កំណាត់រក និងពីអត្រាទាបនៃការកាត់ទោស ដែលនេះជាហេតុផលពីរ ក្នុង ចំណោមហេតុផលជាច្រើនទៀត ដែលនាំឲ្យមានការទម្លាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជា។

លាវ ស្រីរ័ត្ន ត្រូវបានបញ្ចុះបញ្ចូល ដោយឈ្មោះ ឈាង ម៉ានី ជាអ្នកភូមិជាមួយគ្នានៅក្នុងខេត្តកណ្តាល ហើយថានឹងផ្តល់ការងាររោងចក្រឲ្យធ្វើនៅក្នុងប្រទេសចិន ដែលទទួលបានប្រាក់ខែចាប់ពី ៨០០ ដល់ ១,០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ហើយស្រីរ័ត្នក៏ត្រូវរៀបការជាមួយនឹងបុរសជនជាតិចិនផងដែរ។ មេខ្យល់បានផ្តល់លុយចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិកដល់ក្រុមគ្រួសារស្រីរ័ត្ន។ នៅពេលដល់ប្រលានយន្តហោះ

---

[១៩] "របាយការណ៍អំពីសិទ្ធិមនុស្ស ឆ្នាំ២០០៨ ប្រទេសកម្ពុជា" ក្រសួងការបរទេសសហរដ្ឋអាមេរិក ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩។ គេហទំព័រ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣។
[២០] នយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា: ការបង្កើនភាពជាតំណាងរបស់ស្ត្រី. Rep. N.p.: n.p., 2013. នយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា: ការបង្កើនភាពជាតំណាងរបស់ស្ត្រី។ មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ខែមីនា ឆ្នាំ២០១៣។ គេហទំព័រ: ថ្ងៃទី៩ ខែគុម្ភៈ ឆ្នាំ២០១៣។
[២១] ការបាយការណ៍ឆ្នាំ២០១៣ ស្តីអំពីការជួញដូរមនុស្ស។ Rep. N.p.: n.p., 2013. របាយការណ៍ឆ្នាំ២០១៣ ស្តីអំពីការជួញដូរមនុស្ស ក្រសួងការបរទេសសហរដ្ឋអាមេរិកឆ្នាំ២០១៣។ គេហទំព័រ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣។

គោលបំណងជំរុញឲ្យមានការអនុវត្តច្បាប់នេះ។

- រាជរដ្ឋាភិបាលកម្ពុជា គួរផ្តល់វគ្គបណ្តុះបណ្តាល អំពីការយល់ដឹងយែនឌ័រ ស្តីអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការស៊ើបអង្កេត និងវិធីសាស្ត្រសម្ភាសន៍ជនរងគ្រោះ។
- រាជរដ្ឋាភិបាលកម្ពុជា គួរដក អាជ្ញាប័ណ្ណ ពីផ្ទះសំណាក់ទាំងឡាយណា ដែលបម្រើសេវាកម្មស្នាក់នៅរយៈពេលខ្លីៗ ដើម្បីស្កាត់អំពើពេស្យាចារ។
- ពង្រឹងការអនុវត្តច្បាប់ ទាំងឡាយណា ដែលទប់ស្កាត់ការរើសអើង លើស្ត្រីផ្ទុកមេរោគ
- អេដស៍/ជម្ងឺអេដស៍ និងអ្នកបម្រើសេវាកំសាន្ត។ ផ្តល់ការបណ្តុះបណ្តាលអំពីការយល់ដឹងយែនឌ័រដល់មន្ត្រីនគរបាល ទៅលើបញ្ហាទាំងនេះ។
- បង្កើនការយល់ដឹងពី អំពើជួញដូរផ្លូវភេទ ព្រមទាំងផលវិបាកជាអវិជ្ជមាន នៃអំពើជួញដូរនេះ និងបង្កើនការអនុវត្តច្បាប់បង្ក្រាបការជួញដូរបច្ចុប្បន្ន តាមរយៈយុទ្ធ នាការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាន ដោយមានការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាល។
- រដ្ឋាភិបាល គួរបង្កើតមូលនិធិពិសេសមួយ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ និងធនធានសមស្របឯទៀត ដល់ជនរងគ្រោះនៃអំពើជួញដូរផ្លូវភេទ អំពើជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ និងអំពើពេស្យាចារ។
- បង្កើនកិច្ចខិតខំប្រឹងប្រែង របស់រដ្ឋាភិបាល ព្រមទាំងបង្កើនការចំណាយ ទៅលើកម្មវិធីស្តារលទ្ធភាពឡើងវិញ ដល់ស្ត្រីទាំងឡាយ ដែលបានចាកចេញពីឧស្សាហកម្មផ្តល់សេវាកំសាន្ត

នៅប្រទេសចិនមេខ្យល់ម្នាក់ទៀត ក៏បានមកទទួលស្រីរ័ត្ន ហើយនាំស្រីរ័ត្នទៅកាន់ផ្ទះមួយតែម្តង ដែលតាមពិតទៅផ្ទះនោះគឺជាផ្ទះបន ដែលស្រីរ័ត្នត្រូវបានបង្ខំឲ្យធ្វើជាស្រីបម្រើផ្លូវភេទរហូតដល់ថ្ងៃ ដែលអនាគតស្វាមីរបស់ស្រីរ័ត្ន បានមកទទួលស្រីរ័ត្នពីផ្ទះបននោះ។ បន្ទាប់មក ស្រីរ័ត្ន ក៏បានរស់នៅក្នុងផ្ទះក្រុមគ្រួសាររបស់ស្វាមី ដែលនៅទីនោះស្រីរ័ត្នត្រូវបានគេចាត់ ទុកដូចជា ទេសករ និងរងការបៀតបៀនពីស្វាមីនិងសាច់ថ្លៃ។ ស្រីរ័ត្នបានព្យាយាមទូរស័ព្ទមកក្រុមគ្រួសាររបស់គាត់ នៅប្រទេសកម្ពុជាហើយបានប្រាប់ឲ្យពួកគាត់ដាក់ពាក្យបណ្តឹង ទៅអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលធ្វើការទៅលើបញ្ហាសិទ្ធិមនុស្ស។ បុគ្គលិកអង្គការលីកាដូ បានជូនម្តាយជនរងគ្រោះទៅដាក់ពាក្យបណ្តឹង នៅនាយដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃនៅទីក្រុងភ្នំពេញ។ ជាលទ្ធផលក្រសួងមហាផ្ទៃបានបង្គាប់ឲ្យឧត្តមស្នងការនគរបាល ខេត្តកណ្តាលចេញដីកា និងដាក់ពាក្យបណ្តឹងទៅតុលាការ។ ដោយមានកិច្ចសហការជាមួយស្ថានទូតកម្ពុជាប្រចាំ នៅប្រទេសចិន ស្រីរ័ត្នក៏ត្រូវបានជួយសង្គ្រោះ និងបានវិលត្រឡប់មក ផ្ទះ វិញ។ ស្ត្រីមេខ្យល់ដែលជាជនជាតិកម្ពុជារូបនេះ កំពុងត្រូវបានស៊ើបអង្កេត និងនៅមិនទាន់បានចាប់ខ្លួននៅ ឡើយ។

ស្ត្រីជាជនរងគ្រោះពីរនាក់ មានឈ្មោះ ផ ស ម អាយុ ៣២ ឆ្នាំ និង ស្ត្រីម្នាក់ទៀតឈ្មោះ ន ស ន អាយុ ៣០ ឆ្នាំ ត្រូវបានបញ្ឆោះបញ្ឆូលឲ្យទៅធ្វើការនៅក្លឹបខារ៉ាអូខេ នៅខេត្តកោះកុងដោយស្ត្រីម្នាក់មានឈ្មោះហៅក្រៅថា ម៉ែអា ខ្នាង (ឈ្មោះពិតរបស់ស្ត្រីនេះពុំមានអ្នកស្គាល់នោះទេ)។ ស្ត្រីជាជនរងគ្រោះទាំងពីរនាក់ត្រូវបានគេសន្យាថានឹងផ្តល់ប្រាក់ខែចំនួនពី ៥០ ទៅ ៦០ ម៉ឺនរៀលក្នុងមួយខែ អាស្រ័យលើ ការងាររបស់ពួកគេ។ នៅខែវិច្ឆិកា ឆ្នាំ២០១២ ស្ត្រីជាជនរងគ្រោះទាំងពីរ បានសម្រេចចិត្តទៅជាមួយស្ត្រីឈ្មោះម៉ែអា ខ្នាង ព្រមទាំងមានស្ត្រី ម្នាក់ទៀត រួមដំណើរផងដែរ។ នៅពេលមក ដល់ខេត្តកោះកុង ពួកគេត្រូវបានយកទៅដាក់ផ្ទះបនមួយកន្លែង ដែលម្ចាស់ផ្ទះបននោះមានឈ្មោះថា រុំ (នាមត្រកូលរបស់បុរសនេះពុំមានអ្នកស្គាល់នោះទេ) ហើយប្រពន្ធឈ្មោះ ថៃ ស៊ី។ នៅថ្ងៃបន្ទាប់ ស្ត្រីឈ្មោះម៉ែអាខ្នាង និងស្ត្រី ដែលរួមដំណើរម្នាក់ទៀតបានមកយកលុយពីម្ចាស់ផ្ទះបន។ បន្ទាប់មក ទើបស្ត្រីជាជនរងគ្រោះទាំងពីរបានដឹងថាខ្លួនត្រូវបាន គេបោកយកមកលក់ឲ្យផ្ទះបនដែលនៅទីនោះ ពួកគេត្រូវបានបង្ខំឲ្យបម្រើភ្ញៀវដើម្បីដោះបំណុល។ គិតជាមធ្យម ភ្ញៀវម្នាក់ត្រូវបង់ ៣ ម៉ឺនរៀល ដែលចំនួននេះ ត្រូវចែកពាក់ កណ្តាលទៅឲ្យម្ចាស់បន ឬមួយពួកគេអាចយកជាប្រាក់ខែចំនួន ៥០ ម៉ឺនរៀល ក្នុង១ខែ។ ស្ត្រីទាំងពីរនាក់ ត្រូវធ្វើការរហូតដល់ម៉ោង ៣ ព្រឹក ហើយត្រូវបានគេតាមយាមគ្រប់ទីកន្លែងដែលពួកគេទៅ។ ពួកគេបាន លួចរត់ចេញដោយសុវត្ថិភាព ដោយសារ មិនចង់ធ្វើការនៅទីនោះ បន្តទៅទៀត។ ក្រោយមកទៀត ពួកគេក៏បានដាក់ពាក្យបណ្តឹងនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលធ្វើការផ្តោតទៅលើការពារសិទ្ធមនុស្ស ដើម្បីសូមឲ្យជួយអន្តរាគមន៍ទៅតុលាការ។[២២]

ករណីជាច្រើនដូចករណីទាំងនេះមានការកើតឡើងជាញឹកញាប់នៅក្នុងប្រទេសកម្ពុជា ដែលស្ត្រី ឬកុមារីច្រើនត្រូវបានគេសន្យាថានឹងផ្តល់ការងារឲ្យធ្វើ នៅក្នុងតំបន់ ប្រជុំជន ហើយបន្ទាប់មកស្ត្រី និងកុមារី ក៏ត្រូវបានគេលក់ទៅឲ្យក្លឹបកំសាន្តរាត្រី សណ្ឋាគារ និងហាងម៉ាស្សាជាដើម។ ជួនកាលពួកគេត្រូវបានមេខ្យល់បញ្ឆោះបញ្ឆូលឲ្យរៀបការ ដើម្បីធ្វើនិប្បវេសន៍ទៅប្រទេសផ្សេងទៀត រួចពួកគេត្រូវបានគេបញ្ជូនទៅក្រៅប្រទេស ដោយខុសច្បាប់ តាមច្រករវាងខេត្តកោះកុង។

ការកើនឡើងនូវអំពើជួញដូរផ្លូវភេទ នៅប្រទេសកម្ពុជា គឺជាប់ពាក់ព័ន្ធនឹងកត្តាផ្សេងៗគ្នាជាច្រើនក្នុងនោះ រួមមានភាពក្រីក្រវិសមភាពផ្នែកសេដ្ឋកិច្ចសង្គមរវាងតំបន់ជនបទ និងតំបន់ប្រជុំជននានា ការរំលោភយកដីធ្លី ភាពគ្មានដីធ្លី ដោយសារការបម្រែបម្រួល អាកាសធាតុ ឬកម្មវិធីអភិវឌ្ឍន៍នានា ភាពគ្មានការងារប្រព័ន្ធអប់រំមិនសូវមានគុណភាព និងកង្វះព័ត៌មានស្តីពីបញ្ហានៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

ចាប់តាំងពីការធ្វើពេស្យាកម្ម ត្រូវបានចាត់ទុកជាអំពើខុសច្បាប់នៅប្រទេសកម្ពុជា ធ្វើឲ្យអ្នកបម្រើ

សេវាកំសាន្ត (អ្នកប្រកបរបរផ្លូវ ភេទ) ជាច្រើននាក់បាន ចាប់ផ្ដើមធ្វើរបរនេះ ដោយលួចលាក់ ដែលកត្តានេះធ្វើឲ្យអង្គការមិនរដ្ឋាភិបាលនានាពិបាកចុះជួបពួកគេ។ ការចុះបង្ក្រាបរបស់រដ្ឋាភិបាល ទៅលើផ្ទះបន និង ពេស្យាកម្មដែលមានការរៀបចំទុក បាននាំឲ្យ មានការផ្លាស់ប្ដូរទៅជាឧស្សាហកម្មផ្ដល់សេវាកំសាន្តវិញម្ដង។



កន្លងមក ក៏ មា នរបាយការណ៍ជាច្រើនបានលើកឡើងអំពីមន្ត្រីនគរបាលប្រព្រឹត្តអំពើពុករលួយ ដែ លជារឿយៗមន្ត្រីទាំងនេះ បានអនុញ្ញាតឲ្យមានករណីជួញដូរផ្លូវភេទកើតឡើងក្រោមការឃ្លាំមើលរបស់ពួកគេ ឬក៏ចូលរួមពាក់ព័ន្ធដោយផ្ទាល់ក្នុងការធ្វើជំនួញនេះ។ បើទោះបីជាច្បាប់មិនមានការរើសអើងលើអ្នកបម្រើសេវាកំសាន្តក៏ដោយ ក៏ការអនុវត្តជាក់ស្ដែង ពួកគេមិនទទួលបានសិទ្ធិជាច្រើនទៀតដូចដែលបានផ្ដល់ទៅឲ្យប្រជាពលរដ្ឋកម្ពុជាទូទៅនោះទេ។

ជារឿយៗ អ្នកបម្រើសេវាកំសាន្តក៏ជាជនរងគ្រោះផងដែរពីការបៀតបៀនរាងកាយ ពីសំណាក់មន្ត្រីនគរបាល។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានសម្ភាសន៍អ្នកបម្រើសេវាកំសាន្តជាង ៩០ នាក់ ដែលពួកគេទាំងនោះ បានរាយការណ៍ថា ពួកគេរងការវាយដំពីណាក់មន្ត្រីនគរបាលដោយកណ្ដាប់ដៃ ដំបងឈើ និងដំបងឆក់ជាដើម។ ពួកគេមួយចំនួនបានរាយការណ៍ថា មន្ត្រីនគរបាលខ្លះទាមទាររួមភេទជាមួយពួកគេ និងអ្នកបម្រើសេវាកំសាន្តមួយចំនួន ជាក់ស្ដែងបានទទួលរងការរំលោភសេពសន្ថវៈនៅអំឡុងពេលឃុំខ្លួន។ អ្នកបម្រើសេវាកំសាន្តដែលបានផ្ដល់បទសម្ភាសន៍ទាំងអស់ បាននិយាយថា មន្ត្រីនគរបាលបានទាររកប្រាក់សំណូក ឬក៏យកលុយពីពួកគេ។២៣

យោងតាមច្បាប់កម្ពុជា ស្ដីអំពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានអនុម័កាលពីឆ្នាំ២០០៨ មេបន ត្រូវប្រឈមនឹងការដាក់ទោសធ្ងន់ធ្ងរ ជាងស្ត្រីពេស្យាចារ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្ដែង ជារឿយៗជនប្រព្រឹត្តអំពើជួញដូរ ផ្លូវភេទប្រើប្រាស់បក្សពួកនិយមអំណាច និងថវិកា ដើម្បីរួចផុតពីការកាត់ទោស។ នៅពេលខ្លះ ក្រុមគ្រួសារជនល្មើស បង់ជម្ងឺចិត្តដល់ក្រុមគ្រួសារជនរងគ្រោះ ហើយដាក់សម្ពាធឲ្យពួកគេដកពាក្យបណ្ដឹងវិញ។ ដោយសារភាពក្រីក្រ ជារឿយៗជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេព្រមទទួលយកសំណងជម្ងឺចិត្តជាប្រាក់។ នៅក្នុងឆ្នាំ២០១២ មានការចាប់ខ្លួនជនជាប់ចោទត្រឹមតែ ២៣% ប៉ុណ្ណោះ នៃចំនួនជនជាប់ចោទពីបទជួនដូរផ្លូវភេទសរុប។

ពេលដែលករណីអំពើជួញដូរផ្លូវភេទ ត្រូវបានបញ្ជូនទៅតុលាការ មេបនមានថវិកាគ្រប់គ្រាន់ ដើម្បីជួលមេធាវីឯកជនសម្រាប់ការពារក្ដីឲ្យខ្លួន ប៉ុន្តែចំណែកឯជនរងគ្រោះវិញ ត្រូវពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាលដោយសារមិនមែនលទ្ធភាពបង់ថ្លៃសេវា។ ចំនួនមេធាវីមិនគ្រប់គ្រាន់នោះទេ សូម្បីតែនៅក្នុងផ្នែកឯកជនក៏ដោយ ហេតុនេះ ហើយ ការរក

២២ បញ្ហានានាពាក់ព័ន្ធនឹងសិទ្ធិរបស់ស្ត្រី សិទ្ធិកុមារ និងសិទ្ធិកម្មករចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា ។ REP. N.P.: N.P., 2012. បញ្ហានានាពាក់ព័ន្ធនឹងសិទ្ធិរបស់ស្ត្រី សិទ្ធិកុមារ និងសិទ្ធិកម្មករចំណាកស្រុកនៅក្នុងប្រ់ទេសកម្ពុជា ។ សមាគមការពារសិទ្ធមនុស្ស និងការអភិវឌ្ឍន៍ ឆ្នាំ ២០១២។ គេហទំព័រ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣។

មេធាវីដើម្បីការពារជនរងគ្រោះ ដោយឥតបង់ថ្លៃ ឬ បញ្ចុះតម្លៃនោះ ជាការសលំបាក។ នៅកម្ពុជា ចំនួនមេធាវីសរុប៨០០នាក់ ដែលចំនួននេះរាប់ទាំងវិស័យឯកជន និងវិស័យសាធារណៈ។ តាមការប្រៀបធៀបចំនួនមេធាវីមានតិចជាង ½ នៃកម្លាំងការងារ ផ្នែកច្បាប់នៅក្រុមហ៊ុនឯកជនអន្តរជាតិ ដែល បម្រើសេវាផ្លូវច្បាប់។ ជាគោលការណ៍ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់មេធាវី ដោយមិនយកថ្លៃសេវាពីពលរដ្ឋក្រីក្រ និងនៅពេលចូលសវនាការចំពោះករណីព្រហ្មទណ្ឌ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង មិន អាចទៅរួចនោះទេ ដោយសារមេធាវីទាំងនេះមានការងារឯកជនផ្ទាល់ខ្លួន និងមមាញឹកពេក គ្មានពេលសម្រាប់ជួយចុងចោទដែលមានការខ្វះខាតនោះបានទេ។

តួនាទីជាច្រើនផ្នែករបស់កម្ពុជាក្នុងការកំចាត់អំពើជួញដូរ លើប្រជាពលរដ្ឋរបស់ខ្លួនបានបង្កឲ្យមានហានិភ័យកាន់តែអាក្រក់ឡើងដល់ស្ត្រីជនជាតិដើមភាគតិច ដោយសារពួកគេរស់នៅដាច់ឆ្ងាយពីទំនោររបស់សង្គម ដែលជារឿយៗ ធ្វើឲ្យពួកគេក្លាយជាក្រុមគោលដៅនៃអំពើជួញដូរយ៉ាងងាយស្រួល។ កត្តាដែលបញ្ជាក់ឲ្យឃើញហានិភ័យនេះ កាន់តែច្បាស់ នោះគឺនៅខណៈដែលស្ត្រីកម្ពុជាទាំងអស់ងាយទទួលរងអំពើជួញដូរនៅក្រៅប្រទេសកម្ពុជា ស្ត្រីដែលមកពីតំបន់ដាច់ឆ្ងាយពីទំនោររបស់សង្គម ឆ្ងាយពីភាសាដែលគេប្រើយ៉ាងលើសលុប និងឆ្ងាយពីការអប់រំ គឺជាអ្នកទទួលរងនូវអំពើជួញដូរនៅក្នុងប្រទេសកម្ពុជា។

ការទម្លាក់ចំណាត់ថ្នាក់ ប្រទេសកម្ពុជានៅក្នុងរបាយការណ៍ជួញដូរមនុស្សរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ឆ្នាំ២០១៣ គឺជាការឆ្លុះបញ្ចាំងយ៉ាងទូទៅមួយទៅលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកាត់បន្ថយអំពើកេងប្រវ័ញ្ចលើស្ត្រីភេទ។ ចំណាត់ថ្នាក់ថ្មីនេះ មិនត្រឹមតែបង្ហាញពីកំហុសឆ្គងនៅក្នុងកិច្ចប្រឹងប្រែងបច្ចុប្បន្ន របស់ប្រទេសកម្ពុជាក្នុងការបង្ក្រាបអំពើជួញដូរ មនុស្សប៉ុណ្ណោះទេ ហើយក៏បង្ហាញនូវពេលវេលាមួយដែលចាំបាច់ត្រូវយកចិត្តទុកដាក់លើការបង្ក្រាបអំពើជួញដូរមនុស្សផងដែរ។ ប្រសិនបើកម្រិត នៃកិច្ចប្រឹងប្រែងមិនត្រូវបានផ្លាស់ប្តូរឲ្យបានខ្លាំងខ្លា នៅអំឡុងឆ្នាំក្រោយនោះទេ កម្ពុជានឹងត្រូវតម្លាក់ចំណាត់ថ្នាក់ទៅដល់កម្រិត Tier 3។ ការកំណត់ចំណាត់ថ្នាក់ កម្ពុជានៅក្នុងបញ្ជីឃ្លាំមើល Tier 2 បានបង្ហាញយ៉ាងច្បាស់ថាកិច្ចប្រឹងប្រែងក្នុងការបង្ក្រាបអំពើជួញដូរនៅក្នុងប្រទេសកម្ពុជា គួរតែជាចំណុចដ៏សំខាន់ ក្នុងកិច្ចពិភាក្សាជុំវិញការបង្កើតគោលនយោបាយនៅឆ្នាំក្រោយ។ នេះគឺជាការចំបាច់ណាស់ ក្នុងការទទួលស្គាល់ហានិភ័យដែលកើតចេញពីអំពើជួញដូរ និងទទួលស្គាល់ស្ថានភាពដែលកាន់តែអាក្រក់ឡើង ពិសេសផ្ទាល់តែម្តងដល់ស្ត្រីជនជាតិដើមភាគតិច។

យើងពុំបានដឹង ថាតើច្បាប់ណាមួយនៅកម្ពុជា ដែលការពារស្ត្រីបម្រើសេវាកំសាន្តពីការឆ្លងជម្ងឺនានា ដូចជា មេរោគអេដស៍/ជម្ងឺ អេដស៍ជាដើម។ ស្ត្រីមិនអាចទាមទារឲ្យបុរសប្រើប្រាស់ស្រោមអនាម័យបានទេ។ នៅពេលខ្លះ ស្ត្រីអាចនិយាយចរចារជាមួយបុរសឲ្យប្រើប្រាស់ស្រោមអនាម័យ តែការសម្រេចចិត្តជាចុងក្រោយគឺស្ថិតលើបុរស ហើយជាធម្មតាបុរសបដិសេធ មិនប្រើប្រាស់ស្រោមអនាម័យនោះទេ ជាពិសេសនៅពេលស្រវឹងស្រា។

យោងតាមប្រភពព័ត៌មាន របស់យើងមួយចំនួនបានឲ្យដឹងថា ផលវិបាកដែលកើតចេញពីគោលនយោបាយទីក្រុងស្អាត និងច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស គឺធ្វើឲ្យអ្នកបម្រើសេវាកំសាន្តប្រឈមនឹងផលលំបាកនៅក្នុងការការពារខ្លួន ពីការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ ដោយហេតុថា ប្រសិនបើមន្ត្រីប៉ូលិសឃើញពួកគេមានស្រោមអនាម័យដាក់តាមខ្លួន នោះពួកគេទំនងនឹងត្រូវបានចាប់ខ្លួន ដោយគ្រាន់តែពួកគេមានស្រោមអនាម័យតែប៉ុណ្ណោះ។ ការគំរាមកំហែងចាប់ខ្លួន ប្រព្រឹត្តទៅជាការរារាំងមិនឲ្យមានការទិញ និងប្រើប្រាស់ស្រោមអនាម័យ ហើយប្រព្រឹត្តទៅនៅក្នុងទម្រង់នៃការរើសអើងជាក់ស្តែងលើអ្នកបម្រើសេវាកំសាន្តក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍។

២៣ PEARSON, ELAINE. "អំពើហិង្សាលើអ្នកបម្រើសេវាកំសាន្ត នៅក្នុងប្រទេសកម្ពុជា។" អំពើហិង្សាលើអ្នកបម្រើសេវាកំសាន្ត នៅក្នុងប្រទេសកម្ពុជា អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០។ គេហទំព័រ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៤។

អ្នកបម្រើសេវាកំសាន្ត មិនតម្រូវឲ្យធ្វើតេស្ត រកជម្ងឺឆ្លងនោះទេ។ ដោយសារតែកំណើនថ្មីៗ នៃការកែប្រែមន្ទីរពេទ្យទៅជារបស់ឯកជននោះ ធ្វើឲ្យអ្នកបម្រើសេវាកំសាន្តជាច្រើន លែងមានលទ្ធភាពចំណាយលើសេវាថែទាំសុខភាពតទៅទៀត។ ក្រៅពីបញ្ហាហិរញ្ញវត្ថុ អ្នកបម្រើសេវាកំសាន្តក៏ប្រឈមនឹងការរើសអើងយ៉ាងខ្លាំងផងដែរនៅមន្ទីរពេទ្យ និងនៅមណ្ឌលសុខភាព។ នៅពេលដែលអ្នកបម្រើសេវាកំសាន្តទៅរកសេវាព្យាបាល ពួកគេមានអារម្មណ៍ថាទទួលរងការមាក់ងាយពីសំណាក់បុគ្គលិកពេទ្យ។

អំពើហិង្សាលើអ្នកបម្រើសេវាកំសាន្ត គឺជាបញ្ហា ដែលមានការរីករាលដាលមួយផ្សេងទៀតនៅក្នុងកម្ពុជា។ ទំនោរនៃអំពើហិង្សាដ៏ធ្ងន់ធរមួយ គឺការបង្ខំឲ្យរួមភេទជាមួយដៃគូច្រើន។ បុរសម្នាក់នាំស្ត្រីបម្រើសេវាកំសាន្តម្នាក់ទៅផ្ទះសំណាក់ ឬ ទៅសណ្ឋាគារ ហើយក្រោយមកបង្ខំឲ្យស្ត្រីនោះ រួមភេទជាមួយបុរសផ្សេងៗទៀតជាច្រើននាក់។

នាពេលកន្លងទៅ អ្នកបម្រើសេវាកំសាន្តអាចរកស្រោមអនាម័យបានដោយងាយស្រួល។ បច្ចុប្បន្ន មានការផ្លាស់ប្តូរដោយសារតែតម្លៃស្រោមអនាម័យបានកើនឡើង។ ជាលទ្ធផលធ្វើឲ្យអ្នកបម្រើសេវាកំសាន្តមិនអាចទិញស្រោមអនាម័យបានគ្រាប់គ្រាន់តាមចំនួនប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេតទៅទៀតបាន។

ចំពោះអ្នកបម្រើសេវាកំសាន្ត ដែលចង់ចាកចេញពីឧស្សាហកម្មនេះ ពួកគេជួបបញ្ហាលំបាក ដោយហេតុថា កម្មវិធីស្តារលទ្ធភាព ដែលផ្តល់ដោយរដ្ឋាភិបាលមានចំនួនតិចតួច ហើយអង្គការមិនមែនរដ្ឋាភិបាលនានា ក៏ពុំមានធនធានគ្រប់គ្រាន់ ដើម្បីជួយដល់ពួកគេផងដែរ។ ជារឿយៗអតីតអ្នកបម្រើសេវាកំសាន្ត ច្រើនតែប្រឈមនឹងកេរ្តិ៍ឈ្មោះអាក្រក់នៅក្នុងសង្គម ជាពិសេសទទួលរងការប្រមាថពីសំណាក់ស្ត្រីឯទៀតនៅក្នុងសហគមន៍។ នៅពេលខ្លះ ស្ត្រីត្រូវបង្ខំចិត្តត្រឡប់ទៅធ្វើការនៅផ្ទះបនវិញ ដោយសារកត្តាមួយចំនួន ដូចជាកង្វះនូវការទទួលស្គាល់ ព្រមទាំងការ គាំទ្រពីក្រុមគ្រួសារ និងពីមិត្តភ័ក្កជាដើម។

រដ្ឋាភិបាល ក៏បានគាំទ្រដល់អាជីវកម្មផ្លូវភេទដោយអចេតនា តាមរយៈការផ្តល់អាជ្ញាប័ណ្ណដល់ផ្ទះសំណាក់ ដែលបំរើសេវាកម្មស្នាក់នៅក្នុងរយៈពេលខ្លីៗ។ ផ្ទះបនបែបថ្មីនាពេលបច្ចុប្បន្នទាំងនេះ ផ្តល់សេវាកម្មជួលបន្ទប់ដោយគិតជាចំនួនម៉ោង។ ផ្ទះសំណាក់បែប នេះ គិតថ្លៃស្នាក់ នៅរយៈពេល ១ ម៉ោងតម្លៃ ៣ ដុល្លារសហរដ្ឋអាមេរិក និង ៥ ដុល្លារ



រូបថត Phnom Penh Post

សហរដ្ឋអាមេរិក សម្រាប់ការស្នាក់នៅរយៈពេល ៣ ម៉ោង។ នៅក្នុងបន្ទប់ពុំមានកំរាល ភួយ ឬខ្នើយនោះទេ គឺមានត្រឹមតែគ្រែមួយ និងកញ្ចាក់ធំមួយដាក់ជាប់ទៅនឹងជញ្ជាំងម្ខាងទៀតត្រឹមកម្ពស់គ្រែប៉ុណ្ណោះ។ បន្ទប់បែបនេះ ច្បាស់ណាស់ថាគឺមិនមែនជាកន្លែងសម្រាប់ភ្ញៀវស្នាក់នៅរយៈពេលមួយយប់នោះទេ ប៉ុន្តែជាកន្លែងសម្រាប់ប្រព្រឹត្តអំពើពេស្យាកម្ម ក្នុងរយៈពេលខ្លីៗច្រើនជាង។

ប្រទេសកម្ពុជា ក៏ទទួលបាននាមជាឋានសួគ៌សម្រាប់អ្នកស្វែងរកសេវាផ្លូវភេទ និងសម្រាប់ក្រុមមនុស្សដែលមានចំណង់ផ្លូវភេទជាមួយកុមារ។ ករណីមួយដ៏ល្បីល្បាញ ដែលទើបតែកើតឡើងថ្មីៗនេះ គឺករណី លោក អាឡិចសេនឌ័រ ទ្រីហ្វីម៉ូ ពាណិជ្ជករអ្នកមានជនជាតិរុស្ស៊ីម្នាក់ ដែលត្រូវបានផ្តន្ទាទោស ពីបទរំលោភផ្លូវភេទលើក្មេងស្រីកម្ពុជាចំនួន ១៩ នាក់ ដែលមានអាយុក្រោម ១៨ ឆ្នាំ ។ គាត់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១៧ ឆ្នាំ ប៉ុន្តែត្រូវបានបន្ថយមកត្រឹម ៨ ឆ្នាំ នៅសាលាឧទ្ធរណ៍ ហើយនៅខែធ្នូ ឆ្នាំ២០១១ លោក ទ្រីហ្វីម៉ូ បានទទួលព្រះរាជទានទោសពីព្រះមហាក្សត្រខ្មែរ។ នៅខណៈដែលរដ្ឋាភិបាលបានខិតខំប្រឹងប្រែង ដើម្បីចាប់ខ្លួន និងបណ្តេញ លោក ទ្រីហ្វីម៉ូ ចេញពីកម្ពុជា ក៏នៅមានករណីជាច្រើនទៀត ដែលពាក់ព័ន្ធនឹងក្រុមអ្នកស្វែងរកសេវាផ្លូវភេទ និងក្រុមអ្នកដែលមានចំណង់ផ្លូវភេទជាមួយកុមារ ដែលជាជនជាតិបរទេសនោះ កំពុងធ្វើដំណើរមកប្រទេសកម្ពុជា បញ្ហានេះបណ្តាលមកពីភាពមិនច្បាស់លាស់នៃការបកស្រាយច្បាប់ និង កង្វះនូវការអនុវត្តច្បាប់។ ពេលដែលជនបរទេសត្រូវបានចាប់ខ្លួន ដោយសារជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្លូវភេទ ពួកគេអាចទទួលបានការដោះលែងដោយគ្មានទោសយ៉ាងងាយតាមរយៈការសូកប៉ាន់។

# មាត្រា ៧:
# ជីវភាពនយោបាយ និងជីវភាពសាធារណៈ



រូបថត www.erikapineros.com

មាត្រា ៧ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគីនានាចាត់នូវ "វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈនៅក្នុងប្រទេស ហើយជាពិសេសនោះត្រូវធានាថា ស្ត្រីទទួលបានសមភាពជាមួយបុរសនូវសិទ្ធិ: (ក) បោះឆ្នោតនៅក្នុងការបោះឆ្នោតទាំងអស់ និងនៅក្នុងការធ្វើប្រជាមតិជាសាធារណៈ និងមានសិទ្ធិបោះឆ្នោតនៅក្នុងអង្គការសាធារណៈទាំងអស់ ដែលបង្កើតឡើងតាមការបោះឆ្នោត (ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋាភិបាល និងចូលរួមក្នុងការការអនុវត្តគោលនយោបាយ ព្រមទាំងមានសិទ្ធិកាន់មុខការសាធារណៈ និងបំពេញមុខងារសាធារណៈទាំងអស់នៅគ្រប់លំដាប់ថ្នាក់នៅក្នុងជួររដ្ឋាភិបាល និង (គ) ចូលរួមក្នុងសកម្មភាពអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាដែលពាក់ព័ន្ធនឹងជីវភាពសាធារណៈ និងនយោបាយរបស់ប្រទេសជាតិ។"

រាជរដ្ឋាភិបាល បានចាត់វិធានការវិជ្ជមានមួយចំនួនក្នុង ការបង្កើនចំនួនស្ត្រី ជាអ្នកដឹកនាំក្នុងតំណែងសាធារណៈ ឧទាហរណ៍ដូចជា តម្រូវឲ្យមានស្ត្រីយ៉ាងតិច ១ រូប ជាអភិបាលរង ក្រុង រាជធានី ខេត្ត ស្រុក និងខណ្ឌ។ ក៏ប៉ុន្តែនៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ កន្លងទៅនេះ មានបេក្ខជនឈរឈ្មោះជាស្ត្រី ត្រឹមតែ ១៨.៩៦ ភាគរយតែប៉ុណ្ណោះ។[២៥]

## អនុសាសន៍:

- បង្កើនចំនួនស្ត្រីក្នុងតំណែងថ្នាក់ដឹកនាំ ដើម្បីជំនះលើផ្នត់គំនិតដែលថា ស្ត្រីត្រូវស្តាប់បង្គាប់/ស្ថិតក្រោមអំណាចរបស់បុរស ដូចដែលមានចែងនៅក្នុងច្បាប់ស្ត្រីនោះ។
- កំណត់ និងអនុវត្ត តាមចំនួនកូតាសម្រាប់ស្ត្រីនៅក្នុងសភាជាតិ និងព្រឹទ្ធសភា ព្រមទាំងអនុវត្តចំនួនកូតាសម្រាប់ស្ត្រី នៅក្នុងមុខតំណែងជាអភិបាលផងដែរ មិនមែនគ្រាន់តែផ្តល់តំណែងត្រឹមជាអភិបាលរងនោះទេ។
- បង្កើតមូលនិធិសាធារណៈសម្រាប់ឲ្យស្ត្រីអាចប្រើប្រាស់បាន ដើម្បីធ្វើយុទ្ធនាការឃោសនារកសម្លេងឆ្នោតប្រកួតប្រជែងជាមួយបុរសឲ្យមានប្រសិទ្ធិភាព។

រាជរដ្ឋាភិបាល បានលើកពីបទប្បញ្ញត្តិបន្ថែមក្នុងរដ្ឋធម្មនុញ្ញ ដែលរដ្ឋាភិបាលបាននិយាយថា បទប្បញ្ញត្តិបន្ថែមនេះបានជួយសម្រួលឲ្យស្ត្រីមានលទ្ធភាពក្នុងការចូលរួម ដោយស្មើភាពនៅក្នុងជីវភាពនយោបាយរបស់ប្រទេសកម្ពុជា ឧទាហរណ៍ ដូចជា បទប្បញ្ញត្តិ ដែលបានលើកឡើងមានខ្លឹមសារថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ មានសិទ្ធិបោះឆ្នោត ឬមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ មានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតសភាជាតិ ឬមានអាយុចាប់ពី ៤០ ឆ្នាំឡើងទៅមានសិទ្ធិឈរឈ្មោះជាបេក្ខជន សមាជិកព្រឹទ្ធសភា។ ទោះបីជាមានបទប្បញ្ញត្តិទាំងនេះក៏ដោយ ក៏ស្ត្រីជាច្រើនដែលមានសិទ្ធិបោះឆ្នោតត្រូវបានដកសិទ្ធិបោះ ឆ្នោតដែរ។ ឧទាហរណ៍ដ៏ចាប់អារម្មណ៍មួយទាក់ទងនឹងស្ត្រីដែលត្រូវបានគេដកសិទ្ធិបោះឆ្នោតនោះ គឺស្ត្រីដែលទទួលរងការ បណ្តេញចេញដោយបង្ខំ។ ស្ត្រីជាច្រើនក្នុងចំណោមស្ត្រីដែលទទួលរងការបណ្តេញចេញ មិនត្រូវបានគេចុះឈ្មោះឲ្យបោះឆ្នោតដែលនេះជាលទ្ធផលកើតចេញពីការបណ្តេញចេញដោយបង្ខំ និងមកពីភាពគ្មានដីធ្លី មិនតែប៉ុណ្ណោះពួកគេត្រូវបានគេរារាំងមិនឲ្យបោះឆ្នោតនៅក្នុងការបោះឆ្នោតទើបតែកន្លងទៅថ្មីៗនេះ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ដូចបានលើកបញ្ជាក់ ដែលបានលើកទឹកចិត្តដល់ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលជាច្រើនក្តី ក៏ថ្នាក់ដឹកនាំអង្គការជាច្រើនបានលើកឡើងថា កិច្ចប្រឹងប្រែងទាំងនោះមិនទាន់គ្រប់គ្រាន់ទេ ព្រោះលទ្ធផលបង្ហាញថា ស្ត្រីនៅតែបន្តមានសម្លេងភាគតិចនៅក្នុងជួរថ្នាក់ដឹកនាំសា ធារណៈ បើទោះបីជាស្ត្រីមានចំនួនច្រើនជាងបុរសនៃចំនួនប្រជាពលរដ្ឋសរុបក៏ដោយ។

រដ្ឋធម្មនុញ្ញកម្ពុជាបានអនុញ្ញាតឲ្យស្ត្រីបង្កើត និងចូលរួមដោយសេរីនៅក្នុងសមាគម និងនៅក្នុងអង្គការឯកជននានា មានដូចជាសហជីពការងារជាដើម។ តាមការស្រាវជ្រាវរបស់យើង បានបង្ហាញថា ទោះបីជាមានសិទ្ធិធានាដោយរដ្ឋធម្មនុញ្ញក៏ដោយ ក៏ស្ត្រីជាច្រើនត្រូវបានបណ្តេញចេញពីការងារនៅពេលណាដែលពួកគេចូលរួមជាមួយសហជីពជាពិសេសនៅក្នុងវិស័យកាត់ដេរតែម្តង។ ករណីមួយ ដែលបានកើតឡើងថ្មីៗនេះ នៅចុងខែឧសភា និងដើមខែមិថុនា ឆ្នាំ២០១៣ ពេលដែលកម្មករបម្រើការងារនៅក្នុងរោងចក្រណាយគី បានចូលរួមធ្វើកូដកម្ម ដើម្បីទាមទារឲ្យមានការដំឡើងប្រាក់ឈ្នួល។ មានកម្មករប្រហែល ៣០០ នាក់ត្រូវបានបណ្តេញចេញ ពីការងារ។ ប្រធានសហជីពកម្មករសេរី កម្ពុជា លោក ជា មុន្នី បាននិយាយថា កូដកម្មនេះ ធ្វើឡើងដោយស្របច្បាប់ទាំងស្រុង។[២៦] ច្បាប់ ដែលធានាឲ្យស្ត្រីមានសិទ្ធិចូលរួមនៅក្នុងសមាគម និងអង្គការឯកជ ននា នាជារឿយៗ សិទ្ធិទាំងនេះ មិនត្រូវបាននយោជកផ្តល់ឲ្យនោះទេនេះមានន័យថាបទប្បញ្ញត្តិដែលធានាដោយរដ្ឋធម្មនុញ្ញទាំងនេះ

- ដាក់បេក្ខជនឈរឈ្មោះ ជាស្ត្រីនៅលេខរៀងខាងលើ ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីលើកទឹកចិត្តឲ្យអ្នកបោះឆ្នោត ជ្រើសរើសយកស្ត្រីនៅក្នុងវដ្តនៃការបោះឆ្នោតម្តងៗ។ ប្រសិនបើកម្ពុជា មិនទាន់សម្រេចបានចំនួនកូតា ៣០% នៅឡើយទេ ការដាក់ឈ្មោះបេក្ខជនតាមលំដាប់តួអក្សរ មិនមានការគោរពចំពោះយេនឌ័រទេ។
- បង្កើនចំនួនរដ្ឋមន្ត្រីជាស្ត្រីដោយស្ត្រី មិនគួរត្រូវបានជ្រើសរើសដើម្បីធ្វើជាប្រធាន នៅកន្លែងដែលប្រមូលផ្តុំទៅដោយស្ត្រី ឬក្រសួងណា ដែលធ្វើការងារសម្រាប់ស្ត្រីតែប៉ុណ្ណោះ នោះទេ ប៉ុន្តែស្ត្រីគួរតែ ត្រូវបានជ្រើសរើសជារដ្ឋមន្ត្រីគ្រប់ក្រសួងទាំងអស់ផងដែរ។
- អនុវត្តកម្ម វិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី (និងបុរស) ដែលមានបំណងចូលប្រឡូកក្នុងវិស័យនយោបាយ។

[២៥] Kaing, Menghun, and Colin Meyn. "អ្នកបោះឆ្នោត សួរបេក្ខជនឈរឈ្មោះបោះឆ្នោត អំពីសិទ្ធិស្ត្រីនៅប្រទេសកម្ពុជា" កាសែត ឌឹឃែមបូឌាដេលី. N.p., ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣

មិនមានឥទ្ធិពល និងទម្ងន់ពិត ប្រាកដនោះទេព្រម ទាំងមិនទទួលបានជោគ ជ័យក្នុងការលុបបំបាត់ទម្រង់នៃការរើសអើងលើស្ត្រី ផងដែរ។

បើទោះបីជាស្ត្រី ត្រូវបានជាប់ឆ្នោតនៅក្នុងជួររដ្ឋាភិបាលក៏ដោយ ក៏អ្នកទាំងនេះ មិនទទួលបាននូវការគោរពដូចបុរសនោះដែរ។ ពុំវគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រីនៅក្នុងវិស័យនយោបាយឡើយ។ ដូចដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ស្រមោលនេះ ស្ត្រីមិនទទួលបានកម្រិតនៃការអប់រំ ឬការអប់រំដែលមានគុណភាព ដូចនឹងបុរសភាគច្រើនបានទទួលនោះទេ ដោយសារតែការអនុវត្ត ប្រពៃណីវប្បធម៌បានបង្កជាមូលហេតុធ្វើឲ្យស្ត្រី ងាយនឹងបោះបង់ចោលការសិក្សា ហេតុដូច្នេះហើយស្ត្រីមិនអាចរៀបចំខ្លួនឲ្យបានគ្រ ប់គ្រាន់ ដើម្បីចាប់យកឱកាសជាអ្នកដឹកនាំបានទេ បញ្ហានេះមានលើកឡើងបន្ថែមទៀតនៅក្នុងមា ត្រាស្តីអំពីការអប់រំ។ ជារឿយៗ ស្ត្រីត្រូវបានជ្រើសតាំង ដើម្បីបំពេញកូតារបស់រដ្ឋាភិបាល ហេតុដូច្នេះហើយក្នុងការអនុវត្ត ជាក់ស្តែងអ្នកទាំងនេះ គ្រាន់តែមាននាមជាថ្នាក់ដឹកនាំតែមិនសូវមានសិ ទ្ធិអំណាចនោះទេ ។ ម្យ៉ាងវិញទៀត បុរសមានថវិកាសម្រាប់ធ្វើយុទ្ធនាការបោះឆ្នោតរបស់ខ្លួនផ្ទាល់ ប៉ុន្តែស្ត្រីវិញមិនអាចមានថវិកាសម្រាប់ធ្វើយុទ្ធនាការបាននោះទេ។ ជាធម្មតា ក្នុងអំឡុងពេលបោះឆ្នោត គណបក្សនយោបាយតែងតែដាក់បេក្ខជនជាស្ត្រីនៅលំដាប់លេខរៀងខាងក្រោម នៃបញ្ជីរាយនាមបេក្ខជន ដើម្បីធានាថា បេក្ខជនជាស្ត្រីទាំងនេះមិនត្រូវបានជ្រើសតាំងឲ្យកាន់តួនាទី ដែលមានអំណាចនោះទេ។[២៧]ក្នុងការបោះឆ្នោតឃុំ - សង្កាត់ចុងក្រោយកន្លងមកនេះ មានបេក្ខជនជាស្ត្រីឈរឈ្មោះចំនួន ២៥.៦៤% ប៉ុន្តែមានចំនួន១៧.៧៨%តែប៉ុណ្ណោះដែលបានជាប់ឆ្នោត។

សមាជិកសភា និងព្រឹទ្ធសភាមួយចំនួនមិនទាន់ស្គាល់ និងមិនទាន់បានដឹងថា មាន អនុសញ្ញាស៊ីដវ នោះទេ។នៅក្នុងកិច្ចប្រជុំមួយកាលពីប៉ុន្មានឆ្នាំមុន សមាជិកព្រឹទ្ធសភា មួយចំនួនត្រូវបានគេអង្កេតឃើញថា អ្នកទាំងនោះ មិនទាន់បានដឹងថាតើ អនុសញ្ញា ស៊ីដវ ជាអ្វីនោះដែរ ហើយបើទោះជានៅអំឡុងពេលកិច្ចប្រជុំនោះ បានធ្វើការផ្សព្វផ្សាយអំពីអនុ- សញ្ញា ស៊ី-ដវ ក៏ដោយ ក៏យើងជឿថា ការយល់ដឹងនេះនៅតែមានកម្រិតទាបខ្លាំង ដោយសារកង្វះកម្លាំង ជំរុញដែលគាំទ្រដល់ការ អនុវត្តច្បាប់បទប្បញ្ញត្តិ បទបញ្ញានានាដែលពាក់ព័ន្ធនឹងអនុសញ្ញាស៊ី-ដវ ។ សមាជិកអនុ- គណៈកម្មាធិការនៃ អ៊ិន ជី អូ ស៊ី-ដវ ជឿថា អនុសញ្ញានេះគួរត្រូវបានអនុវត្តប្រសើរជាងនេះ ប្រសិនបើសមាជិសភាសមាជិកព្រឹទ្ធសភា និងអាជ្ញាធរទាំងនោះ បានយល់ដឹងអំពីច្បាប់ ដែលពាក់ព័ន្ធនឹងអនុសញ្ញា ស៊ី-ដវ ពិតមែន។ ឧទាហរណ៍ នៅពេលអ្នកតំណាង មកពីរដ្ឋាភិបាលចូលរួមកិច្ចប្រជុំនានា ស្តីអំពីការបញ្ជ្រាបយេនឌ័រ និងអនុសញ្ញាស៊ី-ដវ ឃើញថា អ្នកទាំងនោះមិនសូវមានមតិយោបល់ និងខ្វះសមត្ថភាពក្នុងការបញ្ជូនបញ្ហាទាំងនេះ ទៅក្រសួងដែលពាក់ព័ន្ធនានា។ បើទោះជាអ្នកតំណាងមកពីរដ្ឋាភិបាល អាចពាំនាំបញ្ហាទាំងនេះទៅក្រសួងដែលពាក់ព័ន្ធក៏ដោយ ក៏ក្រសួងទាំងនោះភាគច្រើន មិនសូវយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ឬបញ្ហារបស់ស្ត្រីនោះដែរ។ ម្យ៉ាងវិញទៀតអ្នកទាំងនោះ ក៏ខ្វះជំនួយគាំទ្រផ្នែកថវិកា ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរផងដែរ។ រដ្ឋាភិបាលបានផ្តល់ថវិកាត្រឹមតែប្រមាណ 0.៦៦% ប៉ុណ្ណោះនៃចំនួនថវិកាជាតិសរុបសម្រាប់កិច្ចការងាររបស់ស្ត្រី។[២៨]

[២៦] Thul, Prak Chan. កម្មកររោងចក្រកាត់ដេរណាយគី ជិត ៣០០ នាក់ត្រូវបានបញ្ឈប់ពីការងារ បន្ទាប់ពីកូដកម្មធ្វើឡើងនៅកម្ពុជា ។ Ed. Alan Raybould. Reuters Huffington Post Business ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣. Web.

[២៧] នយោបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា: ការបង្កើនភាពជាតំណាងជាស្ត្រី ខែមីនា ឆ្នាំ២០១៣. vii

[២៦] នយោបាននៅព្រះរាជាណាចក្រកម្ពុជា ការកើនឡើងភាពជាតំណាងជាស្ត្រី។ ខែមីនា ឆ្នាំ២០១៣. ទំព័រ ៥៥.

# មាត្រា ៨៖
# ភាពជាតំណាង និងការចូលរួមនៅលើឆាកអន្តរជាតិ



មាត្រា៨ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី "ចាត់វិធានការសមស្របទាំងអស់ ក្នុងការធានាឲ្យស្ត្រីទទួលបាននូវលក្ខខណ្ឌស្មើគ្នានឹងបុរស គ្មានការរើសអើង ឱកាសធ្វើជាអ្នកតំណាងឲ្យរដ្ឋាភិបាលនៅលើឆាកអន្តរជាតិ និងចូលរួមក្នុងកិច្ចការងាររបស់អង្គការអន្តរជាតិនានា។"

យោងតាមការលើកឡើងរបស់រដ្ឋាភិបាល មានស្ត្រីចំនួន ២១.៨% នៃចំនួនសរុបនៃអ្នកធ្វើការនៅក្នុងស្ថានទូត បេសកជនអចិន្ត្រៃយ៍ និងអគ្គស្ថានកុងស៊ុល។[២៩] ការលើកឡើងនេះ គួរតែមានទិន្នន័យជាក់លាក់បន្ថែមទៀតស្ដីអំពីមុខតំណែង ដែលស្ត្រីបានកាន់ការនៅលើឆាកអន្តរជាតិ និងប្រភេទនៃមុខតំណែងជាថ្នាក់ដឹកនាំដែលស្ត្រីបានគ្រប់គ្រង។ ប្រសិនបើអ្នកតំណាងរបស់ប្រទេសកម្ពុជាជាស្ត្រី ស្ថិតក្នុងតួនាទីមិនសូវសំខាន់ដែលសិទ្ធិ និងអំណាចនៅមានកម្រិត នោះចំនួនស្ត្រីដែលមាន ២១.៨% នៃ ចំនួនអ្នកតំណាងទាំងសរុប បង្ហាញយ៉ាងច្បាស់ថាមិនសូវមានន័យប៉ុន្មានទេ។

## ២១.៨%

ជាស្ត្រីនៃចំនួនសរុបនៃអ្នកធ្វើការនៅក្នុងស្ថានទូត បេសកជនអចិន្ត្រៃយ៍ នឹងអគ្គស្ថានកុងស៊ុល បើយោងតាមការលើកឡើងរបស់រដ្ឋាភិបាល។

## អនុសាសន៍៖

- គួរកំណត់ចំនួនកូតាមួយ ដែលធ្វើឡើងដើម្បីតែងតាំងឯកអគ្គរាជទូតជាស្ត្រីបន្ថែមទៀត និងលើកទឹកចិត្តឲ្យមានការចូលរួមរបស់ស្ត្រី នៅក្នុងអង្គការអន្តរជាតិនានាផងដែរ។

[២៩] ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និងទី៥ អំពីអនុសញ្ញាអន្តរជាតិស្ដីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (អនុសញ្ញា ស៊ី-ដវ) ២៨. ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០

# មាត្រា ៩៖ សញ្ជាតិ



រូបថត លីកាដូ

មាត្រា៩ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី "ផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការផ្លាស់ប្តូរ ឬរក្សាទុកនូវសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគីត្រូវធានា ជាពិសេសចំពោះការរៀបការជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឲ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រព័ន្ធ មិនធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឲ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ...។ រដ្ឋភាគី ត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ។"

មាត្រា៣៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមកស្តីអំពីបត្យាប័ន។ ការទទួលបានសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។"

រដ្ឋាភិបាលមិនបានលើកឡើងពីបញ្ហាលំបាកដែលស្ត្រីជនជាតិដើមភាគតិចកំពុងប្រឈមក្នុងការទទួលបានសញ្ជាតិនោះទេ។ ស្ត្រីមកពីកម្ពុជាក្រោម គឺជាអ្នករងាយរងគ្រោះយ៉ាងខ្លាំងនៅក្នុងបញ្ហានេះ។ ម្យ៉ាងទៀតក៏មានការរិតត្បិតមួយចំនួនទៅលើការបោះឆ្នោតចំពោះពលរដ្ឋខ្មែរ ដែលកំពុងរស់នៅបរទេសផងដែរ។ ដើម្បីអាចមានសិទ្ធិបោះឆ្នោតបានប្រជា-ពលរដ្ឋខ្មែរដែលកំពុងរស់នៅបរទេស ត្រូវធ្វើដំណើរត្រឡប់មកប្រទេស

## អនុសាសន៍៖

- បង្កើតឲ្យមានយុទ្ធនាការអប់រំអំពីសារៈសំខាន់នៃការទទួលបានលិខិតអាពិពាហ៍ពិពាហ៍ បន្ថែមពីលើការរៀបការតាមលក្ខណៈប្រពៃណីតែម្យ៉ាងនោះ។
- អនុវត្ត និងជំរុញឲ្យប្រើប្រាស់ច្បាប់ដែលពាក់ព័ន្ធនានា ដើម្បីឲ្យស្ត្រីកម្ពុជាកាន់តែអាចទទួលបានសិទ្ធិជាអាទិភាពក្នុងការសម្រេចនូវសញ្ជាតិរបស់ខ្លួន។
- លុបបំបាត់បទប្បញ្ញត្តិ នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ ដែលមានលក្ខណៈរើសអើងលើការរៀបការជាមួយជនជាតិបរទេស និងស្វែងរកនូវជម្រើសផ្សេងៗទៀត ដើម្បីកាត់បន្ថយការជួញដូរផ្លូវភេទ។

កម្ពុជាចំនួនពីរដងម្តងគឺដើម្បីចុះឈ្មោះ និងម្តងទៀតគឺដើម្បីបោះឆ្នោត។ ការរិតត្បិតទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ប្រជាពល - រដ្ឋខ្មែរដែលកំពុងរស់នៅបរទេសជាង ១ លាននាក់។

យោងតាមច្បាប់ ស្ត្រីរៀបការរួច ឬក៏នៅលីវ មានសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួល ផ្លាស់ប្តូរ និងរក្សាទុកសញ្ជាតិ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ដោយសារអំពើពុករលួយ បានធ្វើឲ្យមានការរើសអើងផ្អែកលើយេនឌ័រក្នុងបញ្ហាសញ្ជាតិនេះ។ នៅកម្ពុជា ជារឿយៗ បុរសដែលមិនមែនជនជាតិខ្មែរមានភាពងាយស្រួលទទួលបានសញ្ជាតិជាងស្ត្រីដែលមិនមែនជាជនជាតិខ្មែរនោះ។

ស្ត្រីបរទេសរៀបការជាមួយបុរសជនជាតិខ្មែរ ប្រឈមនឹងបញ្ហាលំបាកជាច្រើន។ នៅកម្ពុជា ជនបរទេសមិនអាចទិញផ្ទះ ឬធ្វើជាម្ចាស់កម្មសិទ្ធិលើដីធ្លីបានទេ។ ស្ត្រីបរទេសដែលមានបំណងធ្វើជំនួញប្រឈមនឹងបញ្ហា ឧទាហរណ៍ដូចជា ពួកគេមិនអាចធ្វើជំនួញដោយឯករាជ្យបានទេដោយសារស្ថានភាពសញ្ជាតិរបស់ខ្លួន។ ប្រការនេះបានបង្កើតជាហានិភ័យដ៏ធ្ងន់ធ្ងរមួយដល់ស្ត្រីបរទេស ពីព្រោះថា នៅក្នុងករណីមានការលែងលះគ្នា នោះអ្វីគ្រប់យ៉ាងត្រូវប្រគល់ទៅឲ្យបុរសជាស្វាមីទៅវិញ ដោយសារស្ត្រីបរទេសជាភរិយាមិនមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើអ្វីមួយឡើយ។ គោលនយោបាយនេះ បានដាក់សម្ពាធយ៉ាងខ្លាំងលើស្ត្រីបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា និងត្រូវរៀបការជាមួយបុរសជនជាតិខ្មែរដើម្បីក្លាយជាជនជាតិខ្មែរ។

- លុបបំបាត់ការរិតត្បិតទាក់ទងនឹងការបោះឆ្នោតទៅលើប្រជាពលដ្ឋខ្មែរ ដែលកំពុងរស់នៅបរទេស ដោយអនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរទាំងនោះ មានសិទ្ធិបោះឆ្នោតពីក្រៅ ប្រទេសបាននៅតាមស្ថានកុងស៊ុល ឬស្ថានទូត កម្ពុជាដែលមាន មូលដ្ឋាននៅក្នុងប្រទេស ដែលពួកគេរស់នៅ។



រូបថត លីកាដូ

កន្លងមក មានសេចក្តីបង្គាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលមួយចំនួន បានបង្កើតឲ្យមានអនុភាព នៃការរើសអើងដោយប្រយោលលើស្ត្រីកម្ពុជាដែលរៀបការជាមួយបុរសជនជាតិបរទេស។ ស្ត្រីកម្ពុជាត្រូវបានរារាំងមិនឲ្យរៀបការជាមួយបុរសជនជាតិកូរ៉េ។ ជនជាតិកូរ៉េបានធ្វើការតវ៉ាទៅលើគោលនយោបាយនេះហើយបន្ទាប់មកគោលនយោ-បាយនេះត្រូវបានដកចេញវិញ។ ក៏ប៉ុន្តែ ប្រជាពល-រដ្ឋកម្ពុជានៅតែមិនទាន់បានអនុញ្ញាតឲ្យរៀបការជាមួយជនជាតិតៃវ៉ាន់ នៅក្នុងប្រទេសកម្ពុជានោះទេ។ កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ក្រសួងការបរទេសបានចេញនូវសេចក្តីបង្គាប់លើកទីបី ដែលកំណត់នូវលក្ខខណ្ឌនៃការរៀបការជាមួយស្ត្រីកម្ពុជា នៅក្នុងប្រទេសកម្ពុជា ដែលលក្ខខណ្ឌនោះមានដូចជា ជនជាតិបរទេសមិនអាចរៀបការជាមួយស្ត្រីកម្ពុជាបានទេ ប្រសិនបើជនជាតិបរទេសនោះមានអាយុលើសពី៥០ ឆ្នាំ ឬមានប្រាក់ចំណូលក្នុងមួយខែតិចជាង ២៥០០ ដុល្លារសហរដ្ឋអាមេរិក។ សេចក្តីបង្គាប់នេះត្រូវបានប្រើជាវិធានការទប់ស្កាត់ការជួញដូរ ក៏ប៉ុន្តែផ្ទុយមកវិញ សេចក្តីបង្គាប់នេះមានលក្ខណៈរើសអើងទាំងលើស្ត្រីកម្ពុជា និងជនជាតិបរទេស។

ជារឿយៗ ស្ត្រីកម្ពុជារៀបការជាមួយបុរសជនជាតិបរទេស ត្រឹមតែជាលក្ខណៈប្រពៃណីប៉ុណ្ណោះ។ មានករណីជាច្រើនដែលថា បុរសជនជាតិបរទេសនឹងយកស្ត្រីកម្ពុជាជាកូនក្រមុំ ទៅកាន់ប្រទេសរបស់ខ្លួន ដោយពុំមានលិខិតស្នាមបញ្ជាក់ពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេ ប្រការនេះធ្វើឲ្យស្ត្រីមិនទទួលបានសិទ្ធិអ្វីទាំងអស់ នៅក្នុងប្រទេសថ្មីរបស់ខ្លួននោះ។ មានករណីជាច្រើនដែលស្ត្រីទទួលរងអំពើបំពារបំពាន និងការមិនទទួលខុសត្រូវ មិនតែប៉ុណ្ណោះស្ត្រីក៏ត្រូវបានយកទៅបំបរបង់ចោលនៅបរទេស ដោយមិនមានឱកាសទទួលបានសញ្ជាតិ ឬមិនទទួលបានជំនួយហិរញ្ញវត្ថុដើម្បីអាចវិលត្រឡប់មករកក្រុមគ្រួសាររបស់ខ្លួន នៅប្រទេសកម្ពុជាវិញ។

# មាត្រា ១០: ការអប់រំ



រូបថត log.roomtoread.org

មាត្រា១០ នៃអនុសញ្ញា ស៊ីដ-ដវ មួយផ្នែកបាន ចែងថារដ្ឋភាគីមានកាតព្វកិច្ច"ក្នុងការចាត់វាល់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រី ក្នុងគោលបំណងធានាឲ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងវិស័យអប់រំ" ព្រមទាំងរាយឈ្មោះវិស័យខុសៗគ្នាចំនួន ៨ ដែលរដ្ឋភាគីត្រូវធានាឲ្យមានសមភាពក្នុងការអប់រំ រួមទាំងដាក់បញ្ចូលលក្ខខណ្ឌសម្រាប់គោលការណ៍ណែនាំ អំពីអាជីព ការទទួលបានការអប់រំអំពីកម្មវិធីសិក្សា និងការប្រឡង ដែលទាក់ទងនឹងការលុបបំបាត់ផ្នត់គំនិត លើតួនាទីរវាងបុរស និងស្ត្រី ឱកាសស្មើគ្នាក្នុងការទទួលបានអាហា-រូបករណ៍ ការទទួលបានការអប់រំ ការកាត់បន្ថយអត្រាបោះបង់ចោលការសិក្សារបស់សិស្សស្រី (និងបង្កើតកម្មវិធីនានាដើម្បីជួយដល់ស្ត្រី និងក្មេងស្រីដែលឆាប់បោះបង់ចោលការសិក្សា) ឆន្ទះខាងផ្នែកកីឡា និងអត្តពលកម្ម ការអប់រំសុខភាព និងការអប់រំគ្រួសារ (សូមមើលមាត្រា ១០ នៃអនុសញ្ញា ស៊ីដ-ដវ)។

រដ្ឋាភិបាលបានលើកឡើងថា ខ្លួនបានចាត់វិធានការតាមលទ្ធភាពទាំងអស់ ដើម្បីលើកកម្ពស់ការអប់រំនៅគ្រប់កម្រិត ក៏ប៉ុន្តែការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីអប់រំ ពិសេសសម្រាប់កុមារដែលលើកឡើងនេះ រដ្ឋាភិបាលមិនបានរៀបរាប់លំអិតអំពីចំណាត់ការជាវិជ្ជមានណាមួយ ដើម្បីជួយលើកស្ទួយការអប់រំនោះទេ ឬ បញ្ជាក់ឲ្យបានជាក់លាក់បន្ថែមទៀត ស្របទៅតាមលក្ខខណ្ឌនៃមាត្រា ១០ នៃអនុសញ្ញា ស៊ីដ-ដវ ដើម្បីលុបបំបាត់រាល់ទម្រង់នៃវិសមភាពខាងផ្នែកអប់រំ ឬដើម្បីលុបបំបាត់រនាំងដែលពិបាកនឹងមើល ឃើញនានាដែលស្ត្រី និងក្មេងស្រីកំពុងប្រឈមក្នុងការស្វះស្វែងរកការអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា។ ការអនុវត្ត និងរនាំងខាងផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា បានបង្កឲ្យមានគម្លាតដ៏ធំក្នុងឱកាស និងការទទួលបានការអប់រំសម្រាប់ស្ត្រី និងក្មេងស្រីដែលកត្តានេះ បានជំរុញឲ្យស្ត្រី និងក្មេងស្រីស្ថិតក្នុងការបាត់បង់ឱកាសយ៉ាងធ្ងន់ធ្ងរប្រៀបធៀបនឹងបុរស

**យោងតាមអង្គការ ILO មានស្ត្រីចំនួន ១.១៤ លាននាក់មិនធ្លាប់បានចូលរៀន**

និងក្មេងប្រុស។ យោងតាមអង្គការ ILO មាន ស្ត្រីចំនួន ១.១៤ លាន នាក់មិនធ្លាប់បានចូលរៀន។[៣១]

ក្នុងរយៈពេលសិក្សាថ្នាក់មតេយ្យ សមាមាត្រនៃការចូលរៀនរវាងកុមារា និងកុមារីមានចំនួនប្រហាក់ប្រហែលគ្នា។ ចំនួននេះត្រូវបានថយចុះនៅកម្រិតបឋមសិក្សា ដែលសមាមាត្រ សិស្សប្រុស និងសិស្សស្រីមានប្រហែល៩ (ក្មេងស្រី) និង ១០ (ក្មេងប្រុស)។ នៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យមានសិស្សស្រីកាន់តែតិចទៅៗ ធៀបនឹងសិស្សប្រុស ប៉ុន្តែសមាមាត្ររវាងបុរស និងស្ត្រីបែបនេះ ឃើញថាមានលក្ខណៈល្អប្រសើរជាងមុនក្នុងរយៈមួយទសវត្សកន្លងមកនេះ យ៉ាងណាក៏ដោយក៏នៅតែមានគម្លាតរវាងសិស្សប្រុស និងសិស្សស្រីនៅថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ។ នៅថ្នាក់វិទ្យាល័យក្នុងឆ្នាំ២០០៨ សមាមាត្រារវាងសិស្សប្រុស និងសិស្សស្រីគឺ ៧ (ក្មេងស្រី) និង១០ (ក្មេងប្រុស)។ រដ្ឋាភិបាលបានរៀបចំឲ្យមានកម្មវិធីអាហារូបករណ៍ សម្រាប់សិស្សឆ្នើមដែលមានបំណងចង់បន្តការសិក្សា ក៏ប៉ុន្តែកម្មវិធីនេះពុំមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តនោះទេ។ [៣២]

យោងតាមរបាយការណ៍មួយ ដែលមានចំណងជើងថា "ការលើកកម្ពស់សិទ្ធិនៅសាលា" បានបង្ហាញថា អត្រាចុះឈ្មោះចូលរៀនបានកើនឡើងពី ៩១.៣% ទៅ ៩៦.៤% គិតចាប់ពីខែ មិថុនា ឆ្នាំ២០០៥ ទៅដល់ខែធ្នូ ឆ្នាំ២០១១។[៣៣] ក៏ប៉ុន្តែការចូលរៀនជាក់ស្តែងមិនត្រូវបានលើកយកមកបញ្ជាក់នោះទេ ម្យ៉ាងវិញទៀតយោងតាមបទសម្ភាសន៍បានឲ្យដឹងផងដែរថា អត្រានៃការចូលរៀននៅមានកម្រិតទាបខ្លាំងជាងអត្រានៃការចុះឈ្មោះចូល រៀន។

នៅកម្ពុជា អត្រានៃការបោះបង់ចោលការសិក្សារបស់សិស្សស្រីមានកម្រិតខ្ពស់ជាងសិស្សប្រុស ដោយសារតែកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច។ មូលហេតុដំបូងបង្អស់ គឺថាការអប់រំរបស់ស្ត្រីត្រូវបានគេចាត់ទុកថាមិនសូវសំខាន់ ដូចការអប់រំរបស់បុរស បញ្ហានេះ ដោយសារតែការរំពឹងទុកលើតួនាទីយេនឌ័ររវាង បុរស និ ងស្ត្រី។ តួនាទីយេនឌ័រ ដែលមានជាយូរណាស់មកហើយ នៅកម្ពុជា បង្ហាញថា បុរស គឺជាអ្នកផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដ៏សំខាន់ដល់ប្រពន្ធ និងកូនៗ ហេតុដូច្នេះហើយក្រុមគ្រួសារទាំងឡាយផ្តោតការយកចិត្តទុកដាក់ ផ្តល់ការអប់រំ ដល់កូនប្រុសជាងកូនស្រី។ នេះជាបញ្ហាពិត ជាពិសេសចំពោះក្រុមគ្រួសារ ដែលមានប្រាក់ចំណូលទាប ដែលប្រឈមនឹងអសមត្ថភាព ផ្នែកហិរញ្ញវត្ថុក្នុងការបន្តការ

---

[៣១] ILO របាយការណ៍ស្តីអំពីកម្លាំងពលកម្មឆ្នាំ២០១២

[៣២] កម្ពុជា: រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និង ទី៥ ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា ៣១ -៣២ ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០។

[៣៣] នយោបាយនៅព្រះរាជាណាចក្រ: ការបង្កើនភាពជាតំណាងជាស្ត្រី ១៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិមនុស្ស ខែមីនា ឆ្នាំ២០១៣។

## អនុសាសន៍:

- ដាក់បញ្ចូលការសិក្សា និងការយល់ដឹងអំពីសិទ្ធិមនុស្សទៅក្នុងកម្មវិធីសិក្សា។
- ទស្សនៈទៅលើតួនាទីបុរស និងស្ត្រី ដែលមានជាយូរមកហើយគួរត្រូវដកចេញពីឯកសារសិក្សា និងកម្មវិធីអប់រំ រួមទាំងដកចេញនូវផ្នត់គំនិតទៅលើជនជាតិដើមភាគតិចផងដែរ។
- សាងសង់កន្លែងស្នាក់នៅ ដែលមានសុវត្ថិភាព សម្រាប់ស្ត្រីបន្ថែម នៅក្នុងទីប្រជុំជន ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេ អាចចាកចេញពីផ្ទះ និងទទួលបានការអប់រំនៅកម្រិតកាន់តែខ្ពស់បាន។
- វិនិយោគទុន នៅក្នុងវិស័យអប់រំសាធារណៈនៅកម្រិតវិទ្យាល័យ នៅតាមបណ្តាលខេត្ត និងនៅតាមតំបន់ជនបទ ពីព្រោះនៅតំបន់ជនបទ មានប្រជាពលរដ្ឋរស់នៅ៨០%នៃចំនួនប្រជាពលរដ្ឋសរុប។
- បញ្ញត្តិឲ្យការសិក្សា ស្ថិតក្នុងកាតព្វកិច្ចរហូតដល់អាយុ១៨ឆ្នាំ សម្រាប់ក្មេងស្រី និងក្មេងប្រុស ដោយធ្វើការដាក់ពិន័យ ឲ្យធ្ងន់ធ្ងរក្នុងរយៈពេលខ្លីចំពោះគ្រួសារណា ដែលអនុញ្ញាតិឲ្យកូនឈប់រៀនមុនអាយុកំណត់។
- បង្កើនប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនឲ្យបានខ្ពស់ជាងការចំណាយទៅលើជីវភាពប្រចាំថ្ងៃ និងចងរូបមន្តកែសម្រួលប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនឲ្យបានទៀតទាត់ដោយផ្អែកទៅតាមការចំណាយ ទៅលើជីវភាពប្រចាំថ្ងៃធ្វើបែបនេះ គឺដើម្បីកាត់បន្ថយការបង់ប្រាក់ក្រៅផ្លូវការ ដែលការបង់ប្រាក់នេះបង្កើតឲ្យមានជាឧបសគ្គដល់ស្ត្រី និងក្មេងស្រីក្នុងការចូលរៀននៅសាលា។

សិក្សារបស់កូន មូលហេតុនេះ ទើបឪពុកម្តាយសម្រេចបញ្ជូនកូនប្រុសទៅសាលារៀនជាជាងកូនស្រី។ ពេលដែលស្ត្រីមានផ្ទៃពោះ ឬរៀបអាពាហ៍ពិពាហ៍ ពួកគេតែងតែបោះបង់ចោលការសិក្សាដើម្បីជួយកិច្ចការផ្ទះ។

លើសពីនេះទៅទៀត ភូមិដែលនៅតាមជនបទនានាមានត្រឹមតែសាលាបឋមសិក្សាប៉ុណ្ណោះ កត្តានេះ បានធ្វើឲ្យសិស្សដែលចង់បន្តការសិក្សានៅកម្រិតខ្ពស់ជាងនេះ ត្រូវផ្លាស់ទៅនៅទីក្រុង។ សិស្សប្រុសមិនសូវចំណាយទៅលើការរស់នៅ និងការហូបចុកនោះទេ ដោយពួកគេអាចស្នាក់នៅក្នុងវត្តបាន។ ចំណែកឯសិស្សស្រីវិញមិនអាចធ្វើបែបនេះបានទេ ពួកគេត្រូវតែរកកន្លែងស្នាក់នៅ ដូច្នេះពួកគេត្រូវចំណាយយ៉ាងច្រើន។ ម្យ៉ាងវិញទៀត ឪពុកម្តាយក៏មានក្តីកង្វល់អំពីសុវត្ថិភាពកូនស្រីរបស់ពួកគេ ដែលត្រូវធ្វើដំណើរតែម្នាក់ឯងទៅទីក្រុង ដោយបារម្ភខ្លាចកូនស្រីត្រូវបាត់បង់ព្រហ្មចារី ឬមួយក្លាយជាជនរងគ្រោះពីអំពើរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ ឬអំពើឧក្រិដ្ឋផ្សេងៗ។ ជាលទ្ធផល មានសិស្សស្រីមកពីជនបទតិចតួចប៉ុណ្ណោះ នៅបន្តការសិក្សាកម្រិតខ្ពស់។ នៅកម្ពុជា ទីកន្លែងឆ្ងាយពីសាលាអាចជាឧបសគ្គ ក្នុងការចូលរៀនឲ្យបានទៀងទាត់ សម្រាប់សិស្សមួយចំនួន។ ថ្វីត្បិតតែពួកគេមានបំណងបន្តការសិក្សាក៏ដោយ ក៏ការធ្វើដំណើរទៅសាលាជាប្រចាំ មានចម្ងាយឆ្ងាយ និងមានតម្លៃខ្ពស់។

របាយការណ៍ជាតិពុំបានបញ្ចូលព័ត៌មាន អំពីប្រសិទ្ធិភាពនៃការសិក្សានៅកម្ពុជានោះទេ ហេតុដូច្នេះចាំបាច់ត្រូវមានទិន្នន័យបន្ថែមទៀត បញ្ជាក់អំពីទំហំថ្នាក់រៀន និងសំភារៈនានាជាដើម។ នៅក្នុងរបាយការណ៍ជាតិ ក៏ពុំបានដាក់បញ្ចូលព័ត៌មានលំអិត អំពីកិច្ចប្រឹងប្រែងណាមួយដែលកំពុងត្រូវបានអនុវត្តក្នុងការបន្តការសិក្សារបស់សិស្ស ជាពិសេសក្មេងស្រីនោះដែរ។ គម្លាតរវាងសិស្សប្រុស និងសិស្សស្រី នៅកម្រិតអប់រំកាន់តែខ្ពស់នៅតែបន្តកើតមានគួរឲ្យកត់សំគាល់។ សិស្សបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យមានចំនួន ៤៣% ជាស្ត្រី និងនិស្សិតបញ្ចប់ការសិក្សានៅសកលវិទ្យាល័យ មានចំនួន ៣២% ជា ស្ត្រី។

នៅកម្ពុជាគុណភាពនៃការអប់រំនៅតែជាបញ្ហាចោទ។ គ្រូបង្រៀនភាគច្រើនបានបញ្ចប់ការសិក្សាត្រឹមតែកម្រិតវិទ្យាល័យ និងមិនបានទទួលការបណ្តុះបណ្តាល ប្រកបដោយប្រសិទ្ធិភាពក្នុងនាមជាអ្នកផ្តល់ការអប់រំ។ លើសពីនេទៅទៀត ប្រាក់បៀវត្សជាមធ្យមរបស់គ្រូបង្រៀនមានចំនួនប្រហែល ៦៦ ដុល្លារសហរដ្ឋអាមេរិកក្នុង១ខែ ដែលចំនួននេះមិនអាចផ្គត់ផ្គង់ជីវភាពរស់នៅបានទេ។[៣៨] ផលវិបាកនៃប្រាក់បៀវត្សរ៍ទាបពេក ធ្វើឲ្យគ្រូបង្រៀនជាច្រើនបានទារប្រាក់ក្រៅផ្លូវការ ឬត្រូវធ្វើការងារ

[៣៩] "ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀនៈ ស្ថានភាពសិទ្ធិកុមារក្នុងសាលាបឋមសិក្សាកម្ពុជា" ២៦. អង្គការភាពជាដៃគូរក្នុងការអប់រំ Action Aid ២០១២។

នៅពេលដែលប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនបានកើនឡើង រដ្ឋាភិ-បាលត្រូវដាក់ទោសឲ្យបានតឹងរឹងចំពោះគ្រូ នាយកសាសា និងអាជ្ញាធរផ្នែកអប់រំណាដែលទាមទារ ឬទទួលប្រាក់ក្រៅផ្លូវការ ដែលទាក់ទងនឹងការបង្រៀន។

- ដើម្បីកែប្រែឥទ្ធិពល ដែលកើតចេញពីការបង្រៀនច្បាប់ស្រីនៅក្នុងសាលារៀនអស់រយៈពីរសតវត្សនេះ រដ្ឋាភិបាលគួរផ្តើមធ្វើយុទ្ធនាការ ដែលលើកស្ទួយគុណតម្លៃរបស់ស្ត្រី នៅក្នុងសង្គម ដើម្បីឲ្យស្ត្រីអាចសម្រេចដល់សមត្ថភាព និងសក្តានុពលពិតប្រាកដរបស់ខ្លួន ជាងនេះទៅទៀត នៅតំបន់ជនបទណាដែលនៅតែបន្តបង្រៀនច្បាប់ស្រីនេះទៀត គួរធ្វើការហាមឃាត់។

- រដ្ឋាភិបាល គួរធានាឲ្យមានការផ្តល់ការអប់រំប្រកបដោយភាពស្មើគ្នាក្នុងចំណោមប្រជាពលរដ្ឋដែលជាជន ជាតិដើមភាគតិច និងជាពិសេសគួរធ្វើការដោះស្រាយនូវបញ្ហាលំបាកនៅក្នុងការចុះឈ្មោះចូលរៀនរបស់ប្រជាពលរដ្ឋជាជនជាតិ ដើមភាគតិច។



ផ្សេងទៀតដើម្បីបង្កើនប្រាក់ចំណូល និងអាចផ្គត់ផ្គង់ដល់ជីវភាពរស់នៅ។ តាមរយៈការសម្ភាសន៍ និងករណីនានាដែលបានពីប្រភពជាច្រើន បានបង្ហាញថា គ្រូបង្រៀនដែលមិនចង់បង្រៀនក្នុងម៉ោងរដ្ឋ បានប្រាប់មាតាបិតាសិស្សថា ប្រសិនបើពួកគេបង់ថ្លៃបន្ថែមកូនរបស់ពួកគេនឹងបានរៀនក្នុង "ថ្នាក់ពិសេស" នៅផ្ទះរបស់គ្រូ។ គ្រូបង្រៀនផ្សេងទៀតត្រូវចាកចេញពីសាលាមុនម៉ោងដើម្បីប្រញាប់ទៅធ្វើការមួយផ្សេងទៀត បញ្ហានេះធ្វើឲ្យសិស្សបាត់បង់ម៉ោងរៀនសូត្រ និងការបង្ហាត់បង្រៀនក៏មានតម្លៃ។ នៅកម្ពុជា កុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំដោយឥតបង់ថ្លៃ និងជាកាតព្វកិច្ចរហូតដល់ថ្នាក់ទី៩ ដែលសិទ្ធិនេះធានាដោយរដ្ឋធម្មនុញ្ញ។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ការសិក្សាមិនមែនឥតបង់ថ្លៃទាំងស្រុងនោះទេ ពីព្រោះមានការបង់ប្រាក់ក្រៅផ្លូវការដែលគ្រួសារត្រូវតែចំណាយដើម្បីអាចបញ្ជូនកូនទៅសាលាបាន ដូចជា ថ្លៃឈ្នួលប្រចាំថ្ងៃរបស់គ្រូបង្រៀន ការប្រលង អំណោយជូនគ្រូ និងការរៀនគួបន្ថែម។[៣៥]

កម្មវិធីអាហារូបករណ៍ សម្រាប់សិស្សក្រីក្របានជួយបង្កើនចំនួនស្ត្រី និងក្មេងស្រីឲ្យបន្តការសិក្សាបានកាន់តែខ្ពស់ ក៏ប៉ុន្តែ ទោះបីជាមានកម្មវិធីអាហារូបករណ៍ និងកម្មវិធីកែលំអរដែលពាក់ព័ន្ធនានាក៏ដោយ ក៏ស្ត្រីមានចំនួនតិចតួចនៅក្នុងចំណោមសិស្សនិស្សិតនៅកម្រិតអប់រំកាន់តែខ្ពស់។ កម្មវិធីអាហារូបករណ៍ដែលផ្តល់ ដោយរាជរដ្ឋាភិបាលកម្ពុជា មិនទាន់គ្រប់គ្រាន់ដើម្បីជួយដល់កុមារីឲ្យបានចូលរៀននៅសាលាបានពេញលេញ នៅឡើយដោយជារឿយៗ ក្មេងស្រីទទួលបានត្រឹមតែចំនួនតិចតួចសំរាប់ម្ហូបអាហារ និងសម្លៀកបំពាក់ប៉ុណ្ណោះ។ ថ្វីត្បិតតែមានជំនួយពីរដ្ឋាភិបាលក្តី ក៏សិស្សស្រីមកពីគ្រួសារក្រីក្រមួយចំនួន នៅតែខ្វះជំនួយថវិកា ដែលត្រូវការជាចាំបាច់សម្រាប់ចំណាយទៅលើសំភារៈសិក្សា ឬទប់ស្កាត់មាតាបិតាមិនឲ្យបញ្ឈប់កូនពីសាលា ដើម្បីទុកឲ្យជួយរកប្រាក់មកផ្គត់

---

៣៥ "ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀនៈ ស្ថានភាពសិទ្ធិកុមារក្នុងសាលាបឋមសិក្សាកម្ពុជា" ។ អង្គការភាពជាដៃគូរក្នុងការអប់រំ Action Aid ២០១២។

ផ្តល់គ្រួសារ។ ថ្វីត្បិតតែចំនួនសិស្សស្រីបានកើនឡើងនៅកម្រិត អប់រំកាន់តែខ្ពស់ក៏ដោយ ក៏សមាមាត្រនៃចំនួនសិស្សស្រីនៅមានកម្រិតទាបនៅឡើយ។

ជាចុងក្រោយ យោងតាមមាត្រា ១០ នៃអនុសញ្ញា ស៊ី-ដវ និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីអំពីសិទ្ធិជនជាតិដើមភាគតិចក្នុងមាត្រា ១៣ និង១៤ បានចែងថា ស្ត្រីជនជាតិដើមភាគតិចមានសិទ្ធិទទួលបានការអប់រំនៅគ្រប់កម្រិត និងគ្រប់ទម្រង់ដោយមិនមានការរើសអើង។ ពួកគេមានសិទ្ធិទទួលបានការអប់រំអំពីភាសា និងវប្បធម៌របស់ខ្លួន។ កត្តាដែលប៉ះពាល់ដល់ការទទួលបានការអប់រំសំរាប់ស្ត្រី និងក្មេងស្រីជនជាតដើមភាគតិច មានដូចជាឪពុកម្តាយធ្វើការថ្លឹងថ្លែងពីផលប្រយោជន៍ ក្នុងការបញ្ជូនកូនទៅរៀន និងការទុកកូនឲ្យនៅជួយការងារគ្រួសារ ការចំណាយលើសៀវភៅ និងសម្ភារៈសិក្សាផ្សេងៗទៀត ការធ្វើដំណើរទៅសាលាមានចម្ងាយឆ្ងាយ និងភាសា ដែលប្រើក្នុងការបង្រៀននៅសាលាកង្វះការអប់រំអំពីវប្បធម៌ ចំនួនគ្រូបង្រៀនមិនគ្រប់គ្រាន់ និងបញ្ហាប្រឈមផ្សេងទៀត។[៣៦]

[៣៦] Asia Indigenous Peoples Pact 2006, ជនជាតិដើមភាគតិច និងសិទ្ធិមនុស្សនៅកម្ពុជា,<http://www.aippnet.org/home/images/stories/final_women_info.pdf>

# មាត្រា ១១៖ ការងារ



មាត្រា១១ នៃអនុសញ្ញានេះ ធានាឲ្យស្ត្រីនៅក្នុងប្រទេស ដែលជារដ្ឋភាគីនូវ សិទ្ធិក្នុងការងារ ឱកាសជម្រើស និងអត្ថប្រយោជន៍ស្មើគ្នានឹងបុរស ព្រមទាំងភ្ជាប់កាតព្វកិច្ចរដ្ឋភាគីឲ្យចាត់វិធានការសមស្របទាំងអស់ក្នុងការលុបបំបាត់ការរើសអើងលើស្ត្រីក្នុងការងារ។[៣៧]

រដ្ឋាភិបាលបានលើកឡើងពីមាត្រា៣៦ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ពលរដ្ឋខ្មែរទាំងពីរភេទមាន "សិទ្ធិជ្រើសរើសការងារអាស្រ័យតាមសមត្ថភាពរបស់ខ្លួន និងតម្រូវការរបស់សង្គម" និងបានលើកឡើងបន្ថែមទៀតពីមាត្រា៣ នៃច្បាប់ការងារកម្ពុជាឆ្នាំ១៩៩៧ (ច្បាប់និងបទបញ្ជាដែលពាក់ព័ន្ធ "ច្បាប់ការងារ") ដែលចែងថា កម្មករនយោជិក តាមន័យនៃច្បាប់នេះ គឺជនគ្រប់ភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃ...." រដ្ឋាភិបាលបានថ្លែងថា វិធានការទាំងពីរនេះគឺជាវិធានការផ្លូវច្បាប់ដែលសមស្រប ដើម្បីធានានូវសមភាពក្នុងការងារចំពោះស្ត្រី ប៉ុន្តែមិនបានធ្វើការវាយតម្លៃ ថាតើកិច្ចធានាតាមផ្លូវច្បាប់ ទាំងនេះ ពិតជាមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការរើសអើងក្នុងការងារ ឬវត្តមាននៃច្បាប់ និងបទ

## អនុសាសន៍៖

- កែលំអរការអប់រំ និងផ្តល់វគ្គបណ្តុះបណ្តាល អំពីជំនាញភាពជាអ្នកដឹកនាំដល់ស្ត្រី។ ការផ្តល់ការអប់រំ និងវគ្គបណ្តុះបណ្តាល អំពីជំនាញភាពជាអ្នកដឹកនាំប្រកបដោយគុណភាពកាន់តែប្រសើរដល់ស្ត្រី នោះនិងធ្វើឲ្យស្ត្រីឈានទៅរកឱកាសការងារបានកាន់តែប្រសើរផងដែរ។
- បង្កើនប្រាក់ឈ្នួលអប្បបរមា ជាពិសេសសម្រាប់កម្មកររោងចក្រកាត់ដេរ ។

[៣៧] "ការវាយតម្លៃអំពីស្ថានភាពរបស់ស្ត្រី:ការណែនាំក្នុងការសរសេររបាយការណ៍ក្នុងក្របខណ្ឌអនុសញ្ញា ស៊ី ដវ" ត្រូវបានធ្វើបច្ចុប្បន្នភាពដោយការិយាល័យដើម្បីវឌ្ឍនភាពរបស់ស្ត្រី និងនាយកដ្ឋានសេដ្ឋកិច្ច និងកិច្ចការសង្គម អង្គការសហប្រជាជាតិ ឆ្នាំ២០០០ ទំព័រ ២៩

បញ្ហាជាច្រើនក្នុងប្រទេសកម្ពុជាគ្រាន់តែជាពាក្យសំដីនៅក្នុងក្រដាស តែប៉ុណ្ណោះ ឬយ៉ាងណា។

ដោយសារមានវិសមភាពដ៏ធំនៅក្នុងការអប់រំ ធ្វើឲ្យស្ត្រី និងកុមារីមិនមានសិទ្ធិស្មើគ្នាក្នុងការងារនោះទេ។ ការដែលមិនមានការត្រៀមរៀបចំខ្លួនឲ្យបានគ្រប់គ្រាន់សម្រាប់ការសិក្សា ឬការអប់រំ សមត្ថភាពរបស់ពួកគេ មានលក្ខណៈមិនស្មើភាពគ្នារួចស្រាច់ទៅហើយ នោះធ្វើឲ្យបទប្បញ្ញត្តិដែលធានាដោយរដ្ឋធម្មនុញ្ញមានអនុភាពពិតប្រាកដនោះទេ។ ស្ត្រីជាធម្មតាតែងខ្វះជំនាញដែលចាំបាច់សម្រាប់ធ្វើការងារ ហើយប្រការនេះ ធ្វើឲ្យស្ត្រីមិនសូវមានភាពស្មើគ្នានឹងបុរស ហេតុដូច្នេះ ទើបគេមិនសូវជួលស្ត្រីឲ្យធ្វើការងារ។ អនុគណៈកម្មាធិការនៃ អ៊ិន ជី អូ ស៊ី-ដវបានលើកឡើងថា នៅក្នុងករណីដែលស្ត្រីមានការអប់រំ និងជំនាញខ្ពស់ជាងបុរស ស្ត្រីត្រូវបានជ្រើសរើសឲ្យចូលធ្វើការងារជំនួសបុរស ដែលចំណុចនេះជាការចង្អុលបង្ហាញឲ្យឃើញពីសារៈសំខាន់នៃការធ្វើវិនិយោគទៅលើការអប់រំ និងការបណ្តុះបណ្តាលសម្រាប់ស្ត្រីប្រកបដោយគុណភាពកាន់ តែប្រសើរ ដែលនេះ អាចជាឧបករណ៍ដ៏មាន សក្តានុពលមួយ នឹងធ្វើឲ្យមានសមភាពរវាងបុរស និង ស្ត្រីក្នុង កម្លាំងពលកម្មនៅកម្ពុជា។

**ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ត្រឹម ៤៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ដែលចំនួននេះមិនគ្រប់គ្រាន់សំរាប់ការរស់នៅនោះទេ ក៏ប៉ុន្តែនាពេលថ្មីៗនេះ រដ្ឋាភិបាលបានបង្កើនចំនួនប្រាក់ឈ្នួល អប្បបរមាដល់ ៨០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ**

លើសពីនេះទៅទៀត នៅក្នុងស្ថានភាពនៃប្រទេសមួយ ដែលមានអត្រាអនក្ខរភាពខ្ពស់ និងការអប់រំទាប វត្តមាននៃច្បាប់ តែឯងៗនោះ មិនមានន័យថា ប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់ ឬសិទ្ធិផ្សេងៗដែលមាននៅក្នុងច្បាប់ទាំងនេះនោះទេ។ ប្រជាពលរដ្ឋរស់នៅតំបន់ជនបទភាគច្រើនមិនបានដឹងអំពីច្បាប់ការងាររបស់ប្រទេស ឬមិនបានដឹងអំពីសិទ្ធិទាំងឡាយដែលពួកគេទទួលបាននៅក្នុងច្បាប់ទាំងនោះទេ។ បញ្ហានេះ បានផ្តល់ឱកាសឲ្យនិយោជកដែលជួលប្រជាពលរដ្ឋនៅជនបទឲ្យធ្វើការនោះ មិនយកចិត្តទុកដាក់ ក្នុងការអនុវត្តតាមច្បាប់ការងារ ហើយកត្តានេះ មានន័យថា ប្រជាពល រដ្ឋ នៅជនបទមិនសូវស្វះស្វែងជំរុញឲ្យមានការអនុវត្តនូវសិទ្ធិរបស់ខ្លួន ដោយសារពួកគេមិនទាន់មានការយល់ដឹងអំពីសិទ្ធិនានា ដែលពួកគេត្រូវទទួលបាន។

ស្ត្រី ជាកម្លាំងការងារភាគ ច្រើននៅក្នុងសហគ្រាសចំនួន ១,២៧៣ កន្លែ ងចំនួននេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវ ដោយរដ្ឋាភិបាលក៏ប៉ុន្តែ ចំនួននេះ មិនមែនមានន័យថា ស្ត្រីមានសមភាពក្នុងការងារនោះទេ ប្រសិនបើស្ត្រីនៅតែមិនមានឱកាសក្លាយជាអ្នកគ្រប់គ្រង អ្នកចាត់ការ

- កែលំអរលក្ខខណ្ឌការងារតាមរោងចក្រនានា ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តផ្សេងៗដល់ម្ចាស់រោងចក្រកាត់ដេរ ចំពោះឥរិយាបថ មនុស្ស ធម៌ទៅលើកម្មកររោងចក្រកាត់ដេរ។
- ចាត់វិធានការលុបបំបាត់ការរំលោភសិទ្ធិកម្មករចំណាកស្រុក។

ហើយ ប្រសិនបើស្ត្រីនៅតែទទួលរងការរើសអើងជាក់ស្តែង ទៅលើការឈប់សម្រាកលំហែមាតុភាព និងឬស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យឈប់សម្រាករយៈពេលខ្លីៗនៅអំឡុងពេលធ្វើការ។ ស្ត្រីប្រឈមនឹងលក្ខខណ្ឌបរិយាកាសការងារ ប្រកបទៅដោយសារធាតុពុល និងត្រូវបង្ខំចិត្តធ្វើដំណើរផ្លូវឆ្ងាយទៅធ្វើការ និង/ឬស្ត្រីត្រូវស្ថិតក្នុងស្ថានភាពរស់នៅមួយដែលគ្មានសុវត្ថិភាព ដើម្បីអាចនៅបន្តធ្វើការងារទៀតបាន។ នោះគ្មានអ្វី "ស្មើភាពគ្នា" ឬគ្មានអ្វីជាសេចក្តីថ្លៃថ្នូរនោះទេ នៅខណៈដែលស្ត្រីស្ថិតក្នុងលក្ខខណ្ឌការងារខាងលើទាំងនេះ ដែលមានសភាពរីករាលដាលនោះ។

រាជរដ្ឋាភិបាលកម្ពុជា បានសរសេរនៅក្នុងរបាយការណ៍ជាតិថា រដ្ឋាភិបាលបានចាត់វិធានការបន្ថែមមួយចំនួន ដើម្បីធានាឲ្យស្ត្រីទទួលបានសមភាពក្នុងកម្លាំងពលកម្ម។ ប៉ុន្តែជារឿយៗស្ត្រីត្រូវបានរារាំងមិនឲ្យធ្វើការ "ក្នុងប្រភេទការងារ ដែលមានបុរសលើសលប់" អស់រយៈពេលជាយូរណាស់មកហើយ ដោយផ្អែកលើវប្បធម៌ជំនឿ និងការអនុវត្តតាមទំនៀមទម្លាប់ ដូចជាច្បាប់ស្រី ជាដើម។ បើទោះជាមានការរារាំងបែបនេះក្តី ក៏ភាគរយនៃចំនួនស្ត្រីក្នុងកម្លាំងពលកម្ម ស្ទើរតែស្មើនឹងបុរស គឺស្ត្រីមានចំនួន ៤៩.៤% តួលេខនេះយោងតាមកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅកម្ពុជា។ នៅក្នុងមាត្រា១០៦ នៃ ច្បាប់ការងារ បានចែងថា ស្ត្រីត្រូវបានធានានូវការទទួលបានប្រាក់ឈ្នួលស្មើគ្នានឹងបុរសចំពោះការងារដូចគ្នា។ ក៏ប៉ុន្តែតាមការរៀបរាប់នៅខាងដើម នៃរបាយការណ៍ស្រមោលនេះចំនួនប្រាក់ឈ្នួលមានភាពខុស គ្នា សម្រាប់បុរស និងស្ត្រី។រាជរដ្ឋាភិបាលបានបង្កើត មូលនិធិមួយសម្រាប់ឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យកទៅប្រើប្រាស់ក្នុងការបើវគ្គបណ្តុះបណ្តាលរយៈពេលខ្លីៗ ដើម្បីឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក ក៏ប៉ុន្តែគេមិនទាន់ឃើញមានការសិក្សាណាមួយ ត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃអំពីប្រសិទ្ធិភាពនៃកិច្ចប្រឹងប្រែងនេះនៅឡើយទេ។

ក្រៅពីការផ្តល់វគ្គបណ្តុះបណ្តាល ដើម្បីជួយដល់កម្មករកម្ពុជាទាំងបុរស និងស្ត្រីនៅអំឡុងពេលជួបវិបត្តិសេដ្ឋកិច្ច កម្មវិធីនេះ ក៏បានកំណត់ចំនួនប្រាក់ឈ្នួលអប្បបរមា និងប្រាក់ឈ្នួលតាមបរិមាណផលិតផល ដែលផលិតបាន។ ប្រាក់ឈ្នួលអប្បបរមា ត្រូវបានកំណត់ត្រឹម ៤៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ដែលចំនួននេះមិនគ្រប់គ្រាន់សំរាប់ការរស់នៅនោះទេ ក៏ប៉ុន្តែនាពេលថ្មីៗនេះ រដ្ឋាភិបាល បានបង្កើនចំនួនប្រាក់ឈ្នួលអប្បបរមាដល់ ៨០ ដុល្លារសហរដ្ឋ អាមេរិកក្នុងមួយខែ។




រូបថត លីកាដូ

ច្បាប់ស្តីអំពីរបបសន្តិសុខសង្គមសំរាប់អនុវត្តលើជនទាំងឡាយណា ដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការងារ ក៏បានការ ពារនូវសិទ្ធិស្មើគ្នាក្នុងការទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម

រវាងបុរស និងស្ត្រីនៅកម្ពុជាផងដែរ។ យោងតាមរដ្ឋាភិបាល មូលនិធិរបបសន្តិសុខសង្គមធានាឲ្យមានការអនុវត្តនូវបទប្បញ្ញត្តិរបបសន្តិសុខសង្គម ដែលមានចែងក្នុងច្បាប់ការងារ។ មូលនិធិរបបសន្តិសុខសង្គមនេះ មិនទាន់ត្រូវបានអនុវត្តឲ្យមានប្រសិទ្ធិភាពនៅឡើយទេនៅក្នុងប្រទេសកម្ពុជាហើយក៏មិនដូចជាឧបករណ៍ ការពារសុវត្ថិភាពពិតប្រាកដនោះដែរ។ យោងតាមអង្គការអន្តរជាតិខាងផ្នែកការងារ ក៏បានឲ្យដឹងដែលថា ស្ត្រីមេម៉ាយនៅតែបន្តទទួលបានផលប្រយោជន៍ពីរបបសន្តិសុខសង្គម ក៏ប៉ុន្តែចំនួន ដែលផ្តល់ឲ្យមិនគ្រប់គ្រាន់ សម្រាប់ចិញ្ចឹមជីវិតនោះទេ ចំពោះស្ត្រីមេម៉ាយទទួល បាន ១.៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ និងកូនម្នាក់ៗក្រោមអាយុ ១៦ ឆ្នាំទទួលបាន ១.២៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។[៣៨]

បន្ថែមពីលើអត្ថប្រយោជន៍ ពីរបបសន្តិសុខសង្គម ច្បាប់ការងារក៏បានចែងដែលថា ស្ត្រីមានសិទ្ធិឈប់សម្រាកលំហែមាតុភាព ចំនួន ៩០ ថ្ងៃ (មាត្រា ១៦៩នៃច្បាប់ការងារ)។ ក៏ប៉ុន្តែយោងតាមអនុគណៈកម្មាធិការនៃ អ៊ិន ជី អូ ស៊ី-ដវ ទទួលបន្ទុកលើវិស័យការងារ និងសេដ្ឋកិច្ច បានឲ្យដឹងថា នៅក្នុងឧស្សាហកម្មកម្ពុជាជាច្រើនស្ត្រីត្រូវបានគេបញ្ឈប់ពីការងារនៅពេលមានផ្ទៃពោះចាប់ពី ៥-៦ ខែ ការធ្វើបែបនេះ គឺដោយសារតែគេមិនចង់ចំណាយប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកលំហែមាតុភាព។ ក្នុងមាត្រា១៦៩ នៃច្បាប់ការងារ បានចែងថា និយោជិតទាំងអស់ត្រូវទទួលបានប្រាក់ឈ្នួលផងដែរ នៅពេលមានជម្ងឺ និងថ្ងៃឈប់សម្រាក។

ទោះបីជារាជរដ្ឋាភិបាល ពិតជាបានលើកឡើងអំពីឧស្សាហកម្មកាត់ដេរថា វិស័យនេះ ជាឧស្សាហកម្មមួយដែលនាំមុខគេ ក្នុងការផ្តល់ការងារឲ្យស្ត្រីនៅកម្ពុជា ក៏ប៉ុន្តែមិនបានបង្ហាញពីការដោះស្រាយនូវបញ្ហារំលោភសិទ្ធិមនុស្ស ព្រមទាំងការធ្លាក់ចុះនៃសេចក្តីថ្លៃថ្នូរ ដែលកើតឡើងជាប្រចាំនៅក្នុងរោងចក្រកាត់ដេរជាច្រើន។ នៅកម្ពុជា មានរោងចក្រកាត់ដេរយ៉ាងតិចចំនួន ៥៥៨ កន្លែង[៣៩] មានកម្មករកាត់ដេរជាង ៤០០.០០០ និង៩០% ជាស្ត្រី។ កម្មការិនីរោងចក្រប្រឈមនឹងបញ្ហា មិនទទួលបានប្រាក់ឈ្នួលអប្បបរមា និងបញ្ហាផ្សេង ទៀត។គណបក្សសង្គ្រោះជាតិ (the "CNRP") ជាគណបក្សជំទាស់នាំមុខគេ នៅកម្ពុជា បានអំពាវនាវឲ្យមានការតំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករពី ៨០ ទៅ ១៦០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ បច្ចុប្បន្ននេះ ស្ត្រីមិនអាចរស់ពឹងលើប្រាក់ឈ្នួលទាប ដែលពួកគេទទួលបាននេះទេ ហេតុដូច្នេះពួកគេត្រូវបង្ខំចិត្តធ្វើការថែមម៉ោង ដើម្បីអាចរស់បាន។ លក្ខខណ្ឌការងារនៅក្នុងរោងចក្រមានសភាពពិបាក និងជារឿយៗមិនមានសុវត្ថិភាពនោះទេ។ កាលពីខែឧសភា ឆ្នាំ២០១៣ មានរោងចក្រ ២ កន្លែងបានដួលរលំបង្កឲ្យមានមនុស្សពីរនាក់បានបាត់បង់ជីវិត និងមួយចំនួនទៀតបានរងរបួស។[៤០] ឧបទ្ទវហេតុនេះ បានធ្វើឲ្យមានការអំពាវនាវសូមឲ្យមានការយកចិត្តទុកដាក់ទៅលើបញ្ហានេះ។ ស្ត្រីត្រូវបានជ្រើសរើសឲ្យធ្វើការក្រោមកិច្ចសន្យាខ្លី ដើម្បីងាយស្រួលក្នុងការបញ្ឈប់ពួកគេពីការងារ ដោយគ្រាន់តែជូនដំណឹង ក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ ប្រសិនបើពួកគេចូលរួមនៅក្នុងសហជីព ឬក៏មានផ្ទៃពោះ។ ថ្វីត្បិតតែ ៩០% នៃចំនួនកម្មករកាត់ដេរសរុបជាស្ត្រីក៏ដោយ ក៏តំណែងដែលមានអំណាចទាំងឡាយ ដូចជា ម្ចាស់រោងចក្រ និងអ្នកគ្រប់គ្រងជាដើមសុទ្ធតែជាបុរស។[៤១] បើទោះបីជាជំពូក ៨ នៃច្បាប់ការងារបានការពារសុខភាព និងសុវត្ថិភាពរបស់កម្មករ ព្រមទាំង បានចែងនូវបទប្បញ្ញត្តិ និងការត្រួតពិនិត្យមួយចំនួនក៏ដោយ ក៏ការអនុវត្តនៅមានភាពខ្វះ ខាតដែរ។

ស្ត្រីម្នាក់ បានធ្វើការកត់សំគាល់ថា "ពេលដែលខ្ញុំត្រូវធ្វើការថែមម៉ោងពេលយប់ ខ្ញុំតែងតែមានអារម្មណ៍ភ័យខ្លាចនឹងអំពើប្លន់ការរំលោភសេព

---

[៣៨] ប្រទេសកម្ពុជា: ការត្រួតពិនិត្យអំពីការចំណាយ និងការអនុវត្តិលើកិច្ចគាំពារសង្គម អង្គការអន្តរជាតិខាងផ្នែកការងារ ឆ្នាំ២០១២ ទំព័រ. ៦៧ ។
[៣៩] ផែនទីរោងចក្រកម្ពុជា –សម្លេងពិភពលោក ខែកក្កដា ឆ្នាំ២០១៣។
[៤០] Fuller, Thomas, and Keith Bradsher. "Deadly Collapse in Cambodia Renews Safety Concerns." New York Times. N.p., 16 May 2013.
ស្ត្រី និងទីក្រុង: ការត្រួតពិនិត្យនូវផលប៉ះពាល់នៃអំពើហិង្សាលើយេនឌ័រ និងនគរភាវូបនីយកម្ម Actionaid

សន្ទរៈ និងការបៀតបៀន ពីព្រោះផ្លូវទៅផ្ទះមានសភាពងងឹតខ្លាំង។" ស្ត្រីម្នាក់ទៀតនិយាយថា "ពេលយើងចេញពីរោងចក្រមានមនុស្សច្រើនកុះករ ហើយពួកជនទំនើងតែងតែបន្លំប៉ះគូថស្ត្រី ហើយពួកគេនាំគ្នាសើចលេង ព្រមទាំងគិតថា វាជារឿងធម្មតាទៅវិញ។"[៤២] កម្មកររោងចក្រស្ទើរតែទាំងអស់និយាយថា ក្រោយពីធ្វើការក្នុងរោងចក្របាន ១ ឆ្នាំពួកគេកត់សំគាល់ឃើញថា មានការផ្លាស់ប្តូរក្នុងរាង្គកាយ។[៤៣] កម្មកររោងចក្រជាច្រើន បានជួបប្រទះបញ្ហាសុខភាព ប៉ុន្តែពួកគាត់ពិបាកក្នុងការទទួលបានការថែទាំសុខភាពឲ្យបានត្រឹមត្រូវ ដោយសារតែផ្លូវឆ្ងាយ និងតម្លៃនៃការព្យាបាល (ទំព័រ ២៩)។

រដ្ឋលេខាធិការក្រសួងការងារកម្ពុជា លោក អ៊ុំ មាន បានមានប្រសាសន៍ថា ប្រទេសកម្ពុជាមិនមានបញ្ហានឹងរោងចក្រកាត់ដេរទេ ដោយសារកម្ពុជាមានបទប្បញ្ញត្តិត្រឹម ត្រូវគ្រប់គ្រាន់ដើម្បីគ្រប់គ្រងរោងចក្រទាំងនោះ ឲ្យគោរពទៅតាមច្បាប់។[៤៤] ក៏ប៉ុន្តែ តាមការស្រាវជ្រាវជាអន្តរជាតិ ដែលធ្វើឡើងនៅឆ្នាំ ២០១២ និងឆ្នាំ២០១៣ ដោយអង្គការយុទ្ធនាការសំលៀកបំពាក់ស្អាតស្អំ ដែលមានមូលដ្ឋាននៅប្រទេសហូឡង់ បានសហការជាមួយមហាវិទ្យាល័យច្បាប់ Stanford និ ងសហគមសិទ្ធិកម្មករ ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក បានរកឃើញបញ្ហាមួយចំនួន ដូចជា ប្រាក់ឈ្នួលទាបកង្វះសហជីពឯករាជ្យ និងមានការរំលោភសិទ្ធិកម្មករក្នុងការចូលរួមសហជីព និងអះអាងថា ផលប្រយោជន៍ជាឧបសគ្គចំបងក្នុងការទទួលបានសិទ្ធិស្មើគ្នានៅក្នុងឧស្សាហកម្មកាត់ដេរ ។

មានអំពើរំលោភសិទ្ធិការងារយ៉ាងធ្ងន់ធ្ងរផងដែរទៅលើកម្មករចំណាកស្រុក។ មានកម្មករចំណាកស្រុកកម្ពុជាជិត ៤00.000 នាក់ បានធ្វើចំណាកស្រុកទៅប្រទេសថៃ។ ក៏ប៉ុន្តែមានកម្មករចំណាកស្រុកច្រើននាក់ទៀត ដែលត្រូវបានបញ្ជូនទៅធ្វើការខុសច្បាប់នៅ ប្រទេសផ្សេងៗទៀត និងធ្វើការនៅតាមទូកនេសាទជាដើម។ កម្ពុជាបានអនុញ្ញាតឲ្យភ្នាក់ងារជ្រើសរើសពលករបញ្ជូនពលករទៅប្រទេសថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន គុយវ៉ែត និងកាតាជាដើម។ ពាក់ព័ន្ធនឹងបញ្ហានេះ មានការរាយការណ៍មកថា មានពេលខ្លះ ភ្នាក់ងារទាំងនេះ បានលួចបញ្ជូនពលករដោយសម្ងាត់ទៅប្រទេសផ្សេងទៀតផងដែរ។ ជារឿយៗ កម្មករចំណាកស្រុកទទួលបានប្រាក់ឈ្នួលទាប ធ្វើការច្រើនម៉ោង ម្ហូបអាហារមិនគ្រប់គ្រាន់ រងការវាយដំ និងទារុណកម្ម ហើយពួកគេមិនបានទទួលការថែទាំសុខភាពបានល្អនោះទេ។ អង្គការនៅក្នុងស្រុកមួយបានរាយ ការណ៍ថា នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១០ កម្មករជាស្ត្រីម្នាក់ ដែលមានអាយុ ២៣ ឆ្នាំ ឈ្មោះ ម៉ៅ ស្រីមុំ បានទៅធ្វើការជាអ្នកបំរើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី។ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ រូបគាត់បានទូរស័ព្ទមកម្តាយ ហើយប្រាប់ម្តាយថា គាត់ត្រូវបានគេចាប់ចង និងទុកចោលនៅក្នុងវាលស្រែពេញមួយយប់។ គេបានទុកគាត់ចោលដោយឥតមានផ្តល់ម្ហូបអាហារ និងនៅពេលដែលគេមកទាន់ឃើញគាត់កំពុងហូបបាយជាមួយទឹកស៊ីអ៊ីវ គេបានទាត់ ធាក់ និងវាយដំគាត់រហូតដល់សន្លប់។

អ្នកបម្រើសេវាកំសាន្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងត្រូវចាប់ខ្លួនប្រសិនបើអាជ្ញាធរតាមទាន់ពួកគេ។ ដោយសារតែចំណាត់ការនេះ ធ្វើឲ្យអ្នកបម្រើសេវាកំសាន្តជាច្រើន បានប្រកបរបរដោយលួចលាក់ និងបង្កជាការលំបាកសម្រាប់អង្គការនានាក្នុងចុះជួបពួកគេ។ ស្ត្រីធ្វើការនៅក្នុងឧស្សាហកម្មផ្តល់សេវាកំសាន្តខ្វះខាតទាំងសិទ្ធិ ដែលមានចែងនៅក្នុងច្បាប់ និងការគាំទ្រ។មានការរើសអើងលើស្ត្រីផ្សព្វផ្សាយស្រាបៀរ និងស្ត្រីធ្វើការនៅក្នុងក្លឹបខារ៉ាអូខេផងដែរ។ ជារឿយៗ នយោជកបានបង្ខំឲ្យពួកគាត់ធ្វើទៅតាមអ្វីៗ ដែលជាសុំណូមពររបស់អតិថិជន។ ស្ត្រីជាច្រើនត្រូវធ្លាក់ខ្លួនធ្វើការនៅក្នុងឧស្សាហកម្មផ្តល់សេវាកំសាន្ត ឬធ្វើជាកម្មកររោងចក្រដោយសារខ្វះនូវជំនាញនានាដែលមិនអាចឲ្យពួកគេមានលទ្ធភាពធ្វើការងារដទៃទៀតបាន។

---

[៤២] ស្ត្រី និងទីក្រុង: ការត្រួតពិនិត្យទៅផលប៉ះពាល់នៃអំពើហិង្សាលើយែនឌ័រ និងតំបន់ទីក្រុង។ ២៧
[៤៣] ស្ត្រី និងទីក្រុង: ការត្រួតពិនិត្យទៅផលប៉ះពាល់នៃអំពើហិង្សាលើយែនឌ័រ និងតំបន់ទីក្រុង។ ២៩
[៤៤] កម្ពុជាខ្វះខាតនូវគំរូឧស្សាហកម្មកាត់ដេរ ។ Wall Street Journal

ស្ត្រីជាច្រើននៅកម្ពុជា ត្រូវបានជ្រើសរើសឲ្យចូលធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយភាគច្រើននៅក្នុងវិស័យកសិកម្ម នេសាទ និងវិស័យព្រៃឈើ ព្រមទាំងក្នុងសហគ្រាសខ្នាតតូចនានាផងដែរ ហេតុដូច្នេះពួកគាត់មិនត្រូវបានការពារ ដោយច្បាប់ការងារនោះទេ។ យោងតាមអង្គការអន្តរជាតិខាងផ្នែកការងារបានឲ្យដឹងថា ចំនួនការងារនៅវិស័យក្រៅប្រព័ន្ធមានដល់ទៅ ៨៥% នៃកម្លាំងពលកម្មសរុប។

# មាត្រា ១២៖ សមភាពក្នុងការទទួលបានការថែទាំសុខភាព



រូបថត លីកាដូ

មាត្រា ១២ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគីនៃអនុសញ្ញានេះ ចាត់វិធានការសមស្របនានា ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រី ក្នុងផ្នែកថែទាំសុខភាព និងជាពិសេសធានាឲ្យ ស្ត្រីទទួលបាននូវ "សេវាថែទាំសុខភាពសមរម្យអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាលកូន ដោយផ្តល់សេវាដល់ស្ត្រីដោយឥតបង់ថ្លៃ ទៅតាមករណីចាំបាច់ ព្រមទាំងផ្តល់ម្ហូបអាហារគ្រប់គ្រាន់ក្នុងអំឡុងពេលមានផ្ទៃពោះ និងអំឡុងពេលបំបៅដោះកូន។"

រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងពីមាត្រា ៧២ នៃរដ្ឋធម្មនុញ្ញដែលចែងថា "សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ" ដែលរដ្ឋអះអាងថា ខ្លួនបានបង្កើតនូវអាជ្ញាធរស្របច្បាប់ ដើម្បីសម្រួលឲ្យស្ត្រីមានសិទ្ធិស្មើគ្នា ក្នុងការទទួលបានសេវាថែទាំសុខភាពនៅកម្ពុជា ហើយបានអះអាងដោយខ្លួនឯងថា សិទ្ធិស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាពសម្រាប់ស្ត្រី នៅកម្ពុជា គឺជាបញ្ហាអាទិភាពរបស់រដ្ឋាភិបាល។ ជាការពិតដែលថា រដ្ឋាភិបាលមានកម្មវិធីជំនួយនានា ដូចជា កិច្ចសហការជាមួយ USAID បានទទួលជោគជ័យក្នុងការកែលំអប្រព័ន្ធសុខាភិបាល របស់ប្រទេសកម្ពុជា ហើយបានផ្តល់សេវាកម្មថែទាំសុខភាពនៅ

ទូទាំងប្រទេសកម្ពុជា ដោយធ្វើការកសាងមន្ទីរពេទ្យថែមទៀតនៅថ្នាក់ជាតិ ខេត្ត ស្រុក និងមណ្ឌលសុខភាពនៅថ្នាក់ឃុំជាដើម។[៩៥] មិនមានភាពច្បាស់លាស់នោះទេ ថាតើកិច្ចប្រឹងប្រែងទាំងនេះបានបង្កើតឲ្យមានភាពស្មើគ្នាកាន់តែប្រសើរ ក្នុងការទទួលបានសេវាថែទាំសុខភាពសម្រាប់ស្ត្រីនៅកម្ពុជាដែរឬទេ និងថាតើស្ត្រីនៅទូទាំងប្រទេសកម្ពុជាទទួលបានសេវាក្នុងការរៀបចំផែនការគ្រួសារដូច ដែលបានកំណត់ដោយមាត្រា១២ នៃអនុសញ្ញានេះ ដែរឬទេ។[៩៦] ក៏ប៉ុន្តែ យោងតាមអ្នកសង្កេតការណ៍កម្ពុជាបានឲ្យដឹងថានៅក្នុងការអនុវត្តជាក់ស្តែងសុខភាពរបស់ស្ត្រីកម្ពុជាជាច្រើនមិនត្រូវបានធានាពិតប្រាដកនោះទេ មិនតែប៉ុណ្ណោះស្ត្រីនៅកម្ពុជាមិនទទួលបានសេវាថែទាំសុខភាព និងការព្យាបាលជម្ងឺឲ្យបានពេញលេញ ឬឥតបង់ថ្លៃនោះឡើយ។

ក្រៅពីការលើកឡើងអំពីចំនួនមន្ទីរពេទ្យដែលបានកសាងរួច រដ្ឋាភិបាល ក៏បានលើកពីកិច្ចប្រឹងប្រែងក្នុងការបែងចែកបន្ថែមទៀតនូវចំនួនបុគ្គលិកសុខាភិបាល ដែលមានសមត្ថភាពទៅធ្វើការនៅតាមមន្ទីរពេទ្យបង្អែកនានា។[៩៧] រាជរដ្ឋាភិបាលបានលើកឡើងនៅក្នុងកថាខណ្ឌទី១៦៣ នៃរបាយការណ៍ជាតិ ថារដ្ឋាភិបាលក៏បានគិតគូរអំពីការរៀបចំផែនការគ្រួសារផងដែរ និងក្រៅពីការគិតគូរនេះ រដ្ឋាភិបាលបានថ្លែងថា ក្រសួងសុខាភិបាលបានដំណើរការកម្មវិធីអប់រំជាច្រើនផ្សេងគ្នា ក៏ប៉ុន្តែមិនមានភាពច្បាស់លាស់នោះទេ ថាតើការគិតគូររបស់រដ្ឋាភិបាលត្រូវបានបកស្រាយជាការធានាដល់ស្ត្រីនូវការទទួលបានសេវាទាំងនេះ ដោយរបៀប

[៩៥] សូមអាន ″ការពង្រឹងប្រព័ន្ធសុខាភិបាល″ http://cambodia.usaid.gov/node/154, បច្ចុប្បន្នភាពចុងក្រោយ ២១ ឧសភា ២០១៣។

[៩៦] យោងតាម USAID កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកសាងមន្ទីរពេទ្យ និងមណ្ឌលសុខភាពបន្ថែម ដោយមានកិច្ចប្រតិបត្តិការ និងសហការជាមួយ USAIDនិងធនាគារពិភពលោក ភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ Deustche Geselllschaft fur Internationale Zusammenarbeit, ភ្នាក់ងារអភិវឌ្ឍន៍បែលហ្សិក Group Agence Francaise De Development រួមជាមួយនឹងភ្នាក់ងារ អ.ស.ប.ជាច្រើនទៀត បានបង្កើតជាលទ្ធផល: (១) ធានាបាននូវប្រជាជនជាង ១.១ លាននាក់ទទួលបានសេវាថែទាំសុខភាព (២)បានបង្កើនចំនួនប្រជាពលរដ្ឋកម្ពុជាដែលទំនងជាស្វែងរកការព្យាបាលពីផ្នែកសាធារណៈ នៅក្នុងតំបន់ណាដែលមូលនិធិសមធម៌សុខភាពមានវត្តមាននោះ (៣) បានជួយឲ្យដំណើរការនូវប្រព័ន្ធព័ត៌មានសុខភាព ជាតិដែលត្រូវបានធ្វើបច្ចុប្បន្នភាព នៅក្នុងមណ្ឌលសុខភាពចំនួន ៩៩០ កន្លែង មន្ទីរពេទ្យបង្អែកចំនួន ៧៨ កន្លែង និង មន្ទីរពេទ្យថ្នាក់ជាតិចំនួន ៨ កន្លែង និង (៤) បានពង្រឹងសមត្ថភាពរបស់ក្រសួងសុខាភិបាល ដើម្បីកំចាត់ និងលុបបំបាត់នូវថ្នាំពេទ្យដែលមានគុណភាពអន់ ទន្ទឹមនឹងនោះ បានជួយលើកកម្ពស់ការយល់ដឹងអំពីបញ្ហាគុណភាពថ្នាំពេទ្យ ក្នុងចំណោមអ្នកធ្វើបទបញ្ញត្តិ អ្នកជំនាញផ្នែកសុខាភិបាល និងសាធារណៈជនជាដើម។

[៩៧] មន្ទីរពេទ្យបង្អែកកម្ពុជា ត្រូវបានគេរំពឹងថាអាចជួយដល់ការព្យាបាលបឋម ថែមទាំងមានធនធាន និងអ្នកជំនាញសម្រាប់បម្រើសេវាថែទាំសុខភាពនៅថ្នាក់ស្រុក។ មន្ទីរពេទ្យថ្នាក់ជាតិទាំង ៨ គឺជាមន្ទីរពេទ្យបង្អែក ហើយមន្ទីរពេទ្យខេត្តចំនួន ២១ ក្នុងចំណោម ២៤ មន្ទីរពេទ្យបង្អែកខេត្តបានផ្តល់នូវ សេវាថាទាំសុខភាពកម្រិត CPA 3 ឧទាហរណ៍ ការវះកាត់ធំៗ (ដោយមានការវះកាត់ ទូទៅ) សេវាព្យាបាលតាមឯកទេស សេវាបន្ទប់សង្គ្រោះបន្ទាន់ រួមមាន ICU ការបញ្ចូលឈាម និង សេវាព្យាបាលត្រចៀក ច្រមុះ បំពង់ក ជាដើម។ (សូមអាន "ស្ថានភាពនៃផ្តល់សេវាថែទាំសុខភាព នៅកម្ពុជា ២០១២″ http://ww.wpro.who.int/health_services/services_delivery _profile _cambodia.pdf)។ ប៉ុន្តែ នៅមិនទាន់ច្បាស់ទេថា តើមានសេវាបង្កើតកូន និងសម្ភារៈពេទ្យអ្វីខ្លះនៅតាមមន្ទីរពេទ្យទាំងនោះ។

## អនុសាសន៍:

- រដ្ឋាភិបាល គួរផ្តល់សេវាពិនិត្យសុដន់ និងមហារីកកស្បូនដោយឥតគិតថ្លៃឲ្យបានទៀងទាត់។
- រដ្ឋាភិបាល គួរផ្តល់ការចាក់ថ្នាំបង្ការរោគមហារីកកស្បូន ដោយឥតគិតថ្លៃដល់ស្ត្រី ។
- ក្រសួងព័ត៌មានគួរជំរុញឲ្យមានការផ្សព្វផ្សាយកម្មវិធីសុខភាពដោយធ្វើការផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ដោយឥតគិតថ្លៃ។
- និយោជកគួរចេញថ្លៃ សម្រាប់ការពិនិត្យសុខភាព ដល់ស្ត្រីជាទៀងទាត់។
- ពង្រឹងសមត្ថភាពបុគ្គលិកពេទ្យឆ្មបក្នុងការផ្តល់ប្រឹក្សាដល់ស្ត្រី និងជួយដល់ការរៀបចំផែនការគ្រួសារ។
- ចេញនូវបទប្បញ្ញត្តិច្បាប់នានាសម្រាប់វិស័យឧស្សាហកម្ម និងសហគ្រាសខ្នាតតូច ដើម្បីអនុញ្ញាតឲ្យបុគ្គលិក ជាស្ត្រីចូលរួមក្នុងកម្មវិធីអប់រំសុខភាពយ៉ាងតិច ២ ម៉ោង រៀងរាល់៣ខែម្តង។
- រាជរដ្ឋាភិបាល ត្រូវធ្វើការកែទម្រង់គោលនយោបាយ និងច្បាប់ទាំងអស់ដែលទាក់ទងនឹងការព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងអ្នកមើលថែទាំពួកគេ ដើម្បីធានាថាក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ ដូចជា ក្រុមអ្នកប្រើប្រាស់ថ្នាំញៀន ស្ត្រីមានផ្ទៃពោះ និងក្រុមមនុស្សផ្សេងទៀត មិនត្រូវបានរារាំងពិតប្រាកដ ពីការទទួលបានទាំសុខភាព ដែលចាំបាច់នានា។

ណា និងក៏មិនច្បាស់ផងដែរ ថាតើកម្មវិធីអប់រំទាំងនេះ គ្រប់គ្រាន់ ឬមានប្រសិទ្ធិភាពដែរឬទេ ក្នុងការផ្សព្វផ្សាយព័ត៌មានដែលចាំបាច់នានា។ ផ្អែកតាមការស្រាវជ្រាវ ការសម្ភាសន៍ និងការយល់ដឹងរបស់យើង បង្ហាញថាក្នុងចំណោមស្ត្រីកម្ពុជា ចំណេះដឹង ឬការយល់ដឹងអំពីសេវារៀបចំផែនការគ្រួសារនៅមានកម្រិតទាបខ្លាំងនៅឡើយ។

ជាក់ស្តែង សមភាពក្នុងការទទួលបានសេវាថែទាំសុខាភិបាល និងសេវាផែនការគ្រួសារនៅក្នុងកម្រិតមួយគ្រប់គ្រាន់ត្រូវបានរារាំងមួយផ្នែក ដោយសារការអសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្សព្វផ្សាយព័ត៌មានឲ្យមានប្រសិទ្ធិភាពអំការផ្តល់សេវាថែទាំសុខភាព និងសេវារៀបចំផែនការគ្រួសារដល់ស្ត្រី។ ឧទាហរណ៍ ព័ត៌មានអំពីជម្ងឺឆ្លងតាមការរួមភេទ (STIs) មិនត្រូវបានផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ ឬឲ្យបានជាប្រចាំដល់ប្រជាពលរដ្ឋនោះទេ ជាលទ្ធផល ស្ត្រីកម្ពុជាទទួលបានព័ត៌មានតិចតួច និងការអប់រំតិចតួចអំពីហានិភ័យដល់សុខភាព ដែលបណ្តាលមកពីការព្រឹត្តការណ៍រួមភេទណាមួយ រោគសញ្ញាជម្ងឺ និងការព្យាបាល ឬកិច្ចការពារត្រឹមត្រូវ (រួមមាន ទីកន្លែងដែលពួកគេអាចទទួលការព្យាបាល)។ ជាពិសេសស្ត្រីកម្ពុជា ជាទូទៅមិនបានដឹងអំពីសេវាព្យាបាលសុខភាពដែលអាចរកបាន ពិសេសនោះ សេវារៀបចំផែនការគ្រួសារ។កង្វះព័ត៌មានអំពីផែនការគ្រួសារ មានន័យថារដ្ឋាភិបាលមិនកំពុងបំពេញតាមកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាឲ្យស្ត្រីទទួលបានសេវាទាំងនេះ ដូចដែលមានចែងនៅក្នុងមាត្រា ១២ នោះទេ។ ក្រៅពីនេះ សមត្ថភាពបុគ្គលិកសុខា ភិបាលរបស់កម្ពុជាចាំបាច់ត្រូវធ្វើការពង្រឹងឲ្យបានច្រើនថែម ទៀត។ ដោយសារប្រាក់បៀវត្សទាបគួបផ្សំនឹងការបណ្តុះបណ្តាលនៅមានកម្រិត បានបណ្តាលឲ្យគុណភាពផ្នែកវេជ្ជ សា ស្ត្រនៅកម្ពុជា មានកម្រិតទាប។

មហារីកសុដុន និងមហារីកស្បូន ជាជម្ងឺដែលគ្រោះថ្នាក់ខ្លាំងណាស់ដល់ស្ត្រីកម្ពុជា។ បច្ចុប្បន្ន មិនមានកម្មវិធីពិនត្យឆ្លុះមើលស្ថានភាពជម្ងឺដល់ស្ត្រីចំនួនប្រមាណ ១៥០០ នាក់ ដែលជាអ្នកឆ្លងមហារីកស្បូនថ្មីនៅកម្ពុជាក្នុងមួយឆ្នាំៗ។ នៅកម្ពុជាមិនមានការផ្តល់ការព្យាបាលទេ ក្រៅតែពីការផ្តល់ថ្នាំបំបាត់ការឈឺចាប់ដល់ស្ត្រីចំនួនជាង ៩០០ នាក់ ដែលបានស្លាប់ដោយសារជម្ងឺមហារីកកស្បូនជារៀងរាល់ឆ្នាំ។ [៤៨]

រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល មិន បានបង្ហាញពីកិច្ចប្រឹងប្រែងគួរឲ្យកត់សំគាល់ណាមួយក្នុងការបង្កើតយុទ្ធសា ស្ត្រ ដើម្បីជួយស្ត្រីរងគ្រោះដោយសារជម្ងឺមហារីកនោះទេ។ ការអប់រំអំពីការថែទាំសុខភាពបន្តពូជនៅមានកម្រិត ជាកត្តារួមចំណែកបង្កឲ្យមានបញ្ហានេះ។ កំណើននៃការកែប្រែមន្ទីរពេទ្យឲ្យទៅជាមន្ទីរពេទ្យឯកជន បានបង្កើនតម្លៃសេវាព្យាបាល

- រដ្ឋាភិបាល ត្រូវផ្តល់វគ្គបណ្តុះបណ្តាលឡើងវិញដល់ក្រុមមន្ត្រីនគរបាល និងក្រុមអាជ្ញាធរស្របច្បាប់ ដើម្បីបញ្ឈប់ការចាប់ខ្លួនអ្នក ដែលដាក់ស្រោមអនាម័យតាមខ្លួន ដោយសារតែកត្តានេះ បានធ្វើឲ្យអ្នកបម្រើសេវាកំសាន្ត ជាពិសេសជៀសវាងមិនប្រើស្រោមអនាម័យ និងបានធ្វើឲ្យមានការរីករាលដាលមេរោគអេដស៍/ ជម្ងឺអេដស៍បន្ថែមទៀត។
- បង្កើនការយល់ដឹង អំពីមេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងចំណោមអ្នកបង្កើតគោលនយោបាយ អាជ្ញាធរមូលដ្ឋាន មន្ត្រីនគរបាល និងប្រជាពលរដ្ឋ នៅក្នុងសហគមន៍។
- ជំរុញឲ្យអនុវត្ត ព្រមទាំងពង្រឹងសិទ្ធិ និងច្បាប់ពាក់ព័ន្ធនឹងសុខភាពបន្តពូជ ពិសេសក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។
- ផ្តល់សេវាថែទាំសុខភាព ដល់ប្រជាពលរដ្ឋ ដែលប្រឈមនឹងព្រគ្រោះថ្នាក់ខ្លាំងជាងគេ រួមមានស្ត្រីដែលស្រលាញ់ភេទដូចគ្នា បុរសស្រី ដែលកែភេទ អ្នកប្រើប្រាស់ថ្នាំញៀន និងអ្នកបម្រើសេវាកំសាន្តធ្វើការក្នុងឧស្សាហកម្មផ្តល់សេវាកំសាន្តដោយមិនផាត់ពួកគាត់ចេញពីសង្គម។
- បង្កើនគោលនយោបាយ ផ្តល់កិច្ចអន្តរាគមន៍ និងផែនការផ្សេងៗក្នុងយុទ្ធសាស្ត្រថ្នាក់ជាតិដែលទាក់ ទងនឹងក្មេងកំព្រា និងកុមារងាយ រងគ្រោះ។

[៤៨] Parry, Jane "See and Treat Approach Can Rein វិធីសាស្ត្រមើល និងព្យាបាលអាចគ្រប់គ្រងនៅក្នុងចំនួនស្លាប់ដោយសារមហារីក ស្បូន នៅកម្ពុជា។" បណ្តាញអ្នកវិជ្ជាជីវៈអភិវឌ្ឍន៍ពិភពលោក ។ The Guardian ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣។ Web ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។

ដែលធ្វើឲ្យស្ត្រីភាគច្រើនមិនមានលទ្ធភាពបង់ថ្លៃសេវា។ ក្នុងករណីខ្លះ បើទោះបីជាស្ត្រីបានយល់ដឹងអំពីសារសំខាន់នៃការថែទាំសុខភាព និងមានលទ្ធភាពបង់ថ្លៃសេវាព្យាបាលក៏ដោយ ក៏កម្ពុជានៅខ្វះវេជ្ជបណ្ឌិតដែលមានជំនាញ និងខ្វះបរិក្ខាពេទ្យ ជាពិសេសនៅតាមមណ្ឌលសុខភាព។

ក្នុងចំណោមក្រុមមនុស្សភាគតិច ជាច្រើននៅកម្ពុជាដែលខ្វះនូវឱកាស ក្នុងនោះមានក្រុមអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ (PLHIV)។ ជាការពិតដែលថា រាជរដ្ឋាភិបាលបានអនុវត្ត ដោយជោគជ័យនូវគំនិតផ្តួចផ្តើមក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់មិនឲ្យមានការរីករាលដាលបន្តទៀតនៃមេរោគអេដស៍/ជម្ងឺអេដស៍ ប៉ុន្តែ នេះក៏ជាការពិតដែលថា ស្ត្រីកាន់តែប្រឈមនឹងការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ ដោយសារស្ត្រីមិនសូវបានទទួល ព័ត៌មានអំពីជម្ងឺប្រភេទនេះ ដូចជា វិធីបង្ការរបៀបនៃការឆ្លងជម្ងឺ និងវិធីព្យាបាលឲ្យមានប្រសិទ្ធិភាពជាដើម។ កម្រិតនៃការយល់ដឹងអំពីមេរោគអេដស៍/ជម្ងឺអេដស៍ក្នុងចំណោម ស្ត្រីមេផ្ទះនៅមានកម្រិតទាបខ្លាំង ដែលជាផលវិបាកកើតចេញពីផ្នត់គំនិតយេនឌ័រ ដែលបន្តកើតមានគ្រប់ទីកន្លែង និងការអនុវត្តទំនៀមទម្លាប់វប្បធម៌កម្ពុជាមួយចំនួន។

ការអនុម័តច្បាប់ស្តីពីការបង្ការ និងគ្រប់គ្រងជម្ងឺអេដស៍ឆ្នាំ២០០២ ទទួលបានការកោតសរសើរ នៅក្នុងរបាយការណ៍ថ្មីៗដល់សមាជិករដ្ឋសភាស្តីអំពីមេរោគអេដស៍/ជម្ងឺអេដស៍ពីសំណាក់សហភាពអន្តរសភា។ ក៏ប៉ុន្តែជាក់ស្តែង ការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ជម្ងឺអេដស៍នៅតែកើតមានពាសពេញ និងលេចធ្លោដដែលនៅកម្ពុជា។

មានករណីជាច្រើនត្រូវបានរាយការណ៍មកថា អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ម្នាក់បានទៅមន្ទីរពេទ្យ តែគាត់ត្រូវបានគេទុកឲ្យចាំអស់រយៈពេលយ៉ាងយូរ មុននឹងត្រូវបានគ្រូពេទ្យពិនិត្យ ឬសូម្បីតែត្រូវបានគេបដិសេធមិនផ្តល់ការព្យាបាល។ លើសពីនេះ អ្នកបម្រើសេវាកំសាន្តត្រូវបានគេរើសអើង ដោយអចេតនាក្នុងកិច្ចទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ដោយសារច្បាប់មួយចំនួនបានអនុញ្ញាតឲ្យមន្ត្រីនគរបាលចាប់ខ្លួនអ្នកបម្រើសេវាកំសាន្ត ចំពោះករណីមានស្រោមអនាម័យតាមខ្លួន។ កត្តានេះ បានរារាំងអ្នកបម្រើសេវាកំសាន្តពីការទិញស្រោមអនាម័យហើយធ្វើឲ្យពួកគេកាន់តែងាយរងគ្រោះពីការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍។ ក្រសួងសុខាភិបាលបានផ្តល់កិច្ចអន្តរាគមន៍ពីកម្រិតតិចតួច រហូតដល់គ្មានទាល់តែសោះក្នុងការដើរតួជំនួសជនរងគ្រោះពីការរំលោភសេពសន្ថវៈ ដែលបានឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍។ ស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគ អេដស៍/មេរោគអេដស៍ ក៏ត្រូវបានគេរាយការណ៍មកថា ពួកគាត់ប្រឈមនឹងការរើស អើងពីសំណាក់បុគ្គលិកពេទ្យនៅអំឡុងពេលសម្រាលកូន ដែលកត្តានេះធ្វើឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ម្តាយ និងទារក។ ជាក់ស្តែង យោងតាមរបាយការណ៍ឆ្នាំ២០១០ ស្តីអំពីការទទួលរងនូវការប្រមាថ ដែលធ្វើឲ្យស្ត្រីភាគច្រើនមិន

- ក្រោមកិច្ចសហការ ជាមួយក្រសួងសុខាភិបាលជាតិ ការបណ្តុះបណ្តាលបុគ្គលិកពេទ្យឆ្មប និងឆ្មបតាមក្បួនបុរាណអំពីបញ្ហាអនាម័យ ជាមូលដ្ឋាន និងអំពីការកំណត់សម្គាល់ នូវសញ្ញាគ្រោះថ្នាក់នៅអំឡុងពេលមានផ្ទៃពោះចាស់ខែ និងនៅមុនពេលសម្រាល និងការផ្តល់គ្រឿងបរិក្ខាដែលមានតម្លៃថោក ប៉ុន្តែមានគុណភាពល្អគ្រប់គ្រាន់ (ដូចជា ផ្តល់សម្ភារៈជំនួយសម្រាប់បង្កើតកូនដោយឥតគិតថ្លៃដល់បុគ្គលិកពេទ្យឆ្មប និងឆ្មបតាមក្បួនបុរាណ) គួរដាក់ឲ្យក្លាយជាកម្មវិធីថ្នាក់ជាតិ ដោយមានផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីភ្នាក់ងារម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការទាក់ទងនឹងសុខភាព។

មានលទ្ធភាពបង់ថ្លៃសេវា។ ក្នុងករណីខ្លះ បើទោះបីជាស្ត្រីបានយល់ដឹងអំពីសារសំខាន់ នៃការថែទាំសុខភាព និងមានលទ្ធភាពបង់ថ្លៃសេវាព្យាបាលក៏ដោយក៏កម្ពុជានៅខ្វះវេជ្ជបណ្ឌិតដែលមានជំនាញ និងខ្វះបរិក្ខាពេទ្យ ជាពិសេស នៅតាមមណ្ឌលសុខភាព។

ក្នុងចំណោមក្រុមមនុស្សភាគតិច ជាច្រើននៅកម្ពុជាដែលខ្វះនូវឱកាស ក្នុងនោះមានក្រុមអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ (PLHIV)។ ជាការពិតដែលថារាជរដ្ឋាភិបាលបានអនុវត្ត ដោយជោគជ័យនូវគំនិតផ្តួចផ្តើមក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់មិនឲ្យមានការរីករាលដាលបន្តទៀត នៃមេរោគអេដស៍/ជម្ងឺអេដស៍ ប៉ុន្តែ នេះក៏ជាការពិតដែលថាស្ត្រីកាន់តែប្រឈមនឹងការឆ្លងមេរោគអេដស៍/ ជម្ងឺអេដស៍ ដោយសារស្ត្រីមិនសូវបានទទួលព័ត៌មានអំពីជម្ងឺប្រភេទនេះ ដូចជា វិធីបង្ការរបៀបនៃការឆ្លងជម្ងឺ និងវិធីព្យាបាលឲ្យមានប្រសិទ្ធិភាពជាដើម។ កម្រិតនៃការយល់ដឹង អំពីមេរោគអេដស៍ជម្ងឺអេដស៍ក្នុងចំណោមស្ត្រីមេផ្ទះនៅមានកម្រិតទាបខ្លាំង ដែលជាផលវិបាកកើតចេញពីផ្នត់គំនិតយេនឌ័រ ដែលបន្តកើតមានគ្រប់ទីកន្លែង និងការអនុវត្តទំនៀមទម្លាប់វប្បធម៌កម្ពុជាមួយចំនួន។

ការអនុម័តច្បាប់ស្តីពីការបង្ការ និងគ្រប់គ្រងជម្ងឺអេដស៍ឆ្នាំ២០០២ ទទួលបានការកោតសរសើរនៅក្នុងរបាយការណ៍ថ្មីៗដល់សមាជិករដ្ឋសភា ស្តីអំពីមេរោគអេដស៍/ ជម្ងឺអេដស៍ពីសំណាក់សហភាពអន្តរសភា។ ក៏ប៉ុន្តែជាក់ស្តែងការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ជម្ងឺអេដស៍នៅតែកើតមានពាសពេញ និងលេចធ្លោដដែលនៅកម្ពុជា។

មានករណីជាច្រើនត្រូវបានរាយការណ៍មកថា អ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ម្នាក់បានទៅមន្ទីរពេទ្យ តែគាត់ត្រូវបានគេទុកឲ្យចាំអស់រយៈពេលយ៉ាងយូរ មុននឹងត្រូវបានគ្រូពេទ្យពិនិត្យ ឬសូម្បីតែត្រូវបានគេបដិសេធមិនផ្តល់ការព្យាបាល។ លើសពីនេះ អ្នកបម្រើសេវាកំសាន្តត្រូវបានគេរើសអើង ដោយអចេតនាក្នុងកិច្ចទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ដោយសារច្បាប់មួយចំនួន បានអនុញ្ញាតឲ្យមន្ត្រីនគរបាលចាប់ខ្លួនអ្នកបម្រើសេវាកំសាន្ត ចំពោះករណីមានស្រោមអនាម័យតាមខ្លួន។ កត្តានេះបានរារាំងអ្នកបម្រើសេវាកំសាន្តពីការទិញស្រោមអនាម័យ ហើយធ្វើឲ្យពួកគេកាន់តែងាយរងគ្រោះពីការឆ្លងមេរោគ អេដស៍ /ជម្ងឺអេដស៍។ ក្រសួងសុខាភិបា លបានផ្តល់កិច្ចអន្តរាគមន៍ពីកម្រិតតិចតួច រហូតដល់គ្មានទាល់តែសោះក្នុងការដើរតួជំនួសជនរងគ្រោះ ពីការរំលោភសេពសន្ថវៈ ដែលបានឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍។ ស្ត្រីមាន ផ្ទៃពោះ ដែលផ្ទុកមេរោគអេដស៍/មេរោគអេដស៍ ក៏ត្រូវបានគេរាយការណ៍មកថាពួកគាត់ប្រឈមនឹងការរើសអើង ពីសំណាក់បុគ្គលិកពេទ្យ នៅអំឡុងពេលសម្រាលកូន ដែលកត្តានេះធ្វើឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ម្តាយ និងទារក។ ជាក់ស្តែងយោងតាមការរបាយការណ៍ ឆ្នាំ ២០១០ ស្តីអំពីការទទួលរងនូវការប្រមាថ បានបង្ហាញថា មានអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ចំនួន ១៤.៣% បានរាយការណ៍ថាពួកគាត់ត្រូវបានណែនាំយ៉ាងហ្មត់ចត់ឲ្យបញ្ឈប់ការមានផ្ទៃពោះ ដោយសារស្ថានភាព ដែលពួកគាត់មានផ្ទុកមេរោគអេដស៍ ជម្ងឺអេដស៍។ មនុស្សចាស់នៅក្នុងសហគមន៍ត្រូវទទួលបន្ទុកចិញ្ចឹមបីបាច់កុមារកំព្រា ដែលឪពុកម្តាយស្លាប់ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ និងត្រូវចិញ្ចឹមបីបាច់កុមារ ដែលងាយរងគ្រោះដែលមានផ្ទុកជម្ងឺអេដស៍/មេរោគអេដស៍ ពួកគាត់ទទួលបានជំនួយពីកម្រិតតិចតួចរហូតគ្មានទាល់តែសោះពីសំណាក់រដ្ឋាភិបាល។ នៅតំបន់ណាដែលធ្លាប់ទទួលបានជំនួយម្ហូបអាហារសម្រាប់កុមារទាំងនេះ ប៉ុន្តែបច្ចុប្បន្ននេះមិនមានការផ្តល់ជំនួយនេះទៀតទេ។

អ្នកប្រើប្រាស់ថ្នាំញៀន ក៏ប្រឈមនឹងការរើសអើងក្នុងការផ្តល់សេវាសុខភាពផងដែរ ព្រោះថាក្នុងករណី ដែលពួកគេចង់ទទួលបានសេវាថែទាំសុខភាព និងចង់ចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងប្រវត្តិនៃការប្រើប្រាស់ថ្នាំញៀន នោះគោលនយោបាយភូមិឃុំមានសុវត្ថិភាព នឹងអនុញ្ញាតឲ្យមន្ត្រីនគរបាលចាប់ខ្លួនពួកគេចំពោះការផ្តល់ព័ត៌មានទាំងនេះ។ ជាលទ្ធផល អ្នកប្រើប្រាស់ថ្នាំញៀនត្រូវតែគិតគូរយ៉ាងប្រុងប្រយ័ត្នមុននឹងប្រាប់ព័ត៌មានរបស់ពួកគេ ដោយសារមូលហេតុនេះ ពួកគេមិនទទួលបានការព្យាបាលឲ្យបានគ្រប់គ្រាន់នោះទេ។

បុរស និងស្ត្រីដែលស្រលាញ់ភេទដូចគ្នា ក៏ប្រឈមនឹងការរើសអើងផងដែរក្នុងការផ្តល់សេវាថែទាំសុខភាព។ ដោយហេតុថា នៅកម្ពុជា បុរស និងស្ត្រីដែលស្រលាញ់ភេទដូចគ្នា អាចនឹងត្រូវបានចាប់ខ្លួន ចំពោះចំណង់ភេទរបស់ពួកគេ ដូច្នេះពួកគេមិនសូវស្វែងរកសេវាថែទាំសុខភាពនោះទេ។ម្យ៉ាងវិញទៀត នៅពេលដែលពួកគេស្វែងរកសេវាថែទាំសុខភាព ពួកគេអាចនឹងត្រូវបានបុគ្គលិកពេទ្យនៅក្នុងសហគមន៍ និងនៅក្នុងមណ្ឌលសុខភាពគេចវៀសមិនចង់ព្យាបាលពួកគេ។

នៅកម្ពុជា ឆ្មបតាមក្បួនបុរាណ (TBAs) នៅក្នុងសហគមន៍ភាគច្រើន នៃជនជាតិដើមភាគតិច បានបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម វប្បធម៌ និងសុខភាព ក្នុងការថែទាំស្ត្រីនៅអំឡុងពេលសម្រាល និងថែទាំទារកនៅក្រោយពេលសម្រាល។ ការបង្កើនវគ្គបណ្តុះបណ្តាលដល់ពេទ្យឆ្មប និងឆ្មបតាមក្បួនបុរាណ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកាត់បន្ថយអត្រាមរណភាពរបស់មាតា និងទារកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។ បើទោះបីជាមានវគ្គបណ្តុះបណ្តាលបែបនេះ នៅក្នុងខេត្តរតនគិរី ដោយសារមានកិច្ចសហការរវាងអង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរសុខាភិបាលខេត្តបានសម្រេចនូវសមិទ្ធិផលសំខាន់ៗមួយចំនួន ពីវគ្គការបណ្តុះបណ្តាលនេះក៏ដោយ ក៏នៅមានកិច្ចការចាំបាច់ជាច្រើនទៀតដែលត្រូវយកមកអនុវត្ត ទាំងនៅក្នុងខេត្តរតនគិរី និងខេត្តដទៃទៀតដែលមានជនជាតិដើមភាគតិចរស់នៅ ហើយកម្មវិធីបណ្តុះបណ្តាលនេះ មិនទាន់បានចាប់ផ្តើមដំណើរការនៅក្នុងខេត្តទាំងនេះនៅឡើយទេ។ គួរកត់សំគាល់ផងដែរថា ការផ្តល់សេវាបន្ទាន់ខាងផ្នែកថែទាំសុខភាពដល់ម្តាយនៅអំឡុងពេលសម្រាល និងក្រោយពេលសម្រាល និងការផ្តល់សេវាថែទាំសុខភាពដល់ទារក មានសារៈសំខាន់ ក៏ប៉ុន្តែការផ្តល់សេវាទាំងនេះអាចធ្វើទៅបាន គឺទាមទារឲ្យមានវគ្គបណ្តុះបណ្តាលដល់អ្នកឯកទេសផ្នែកសុខាភិបាល ដែលវគ្គបណ្តុះបណាលនេះត្រូវចំណាយថវិកាខ្ពស់ និងត្រូវការសម្ភារៈបរិក្ខាដើម្បីបង្កើនសមត្ថភាព នៃប្រព័ន្ធសេវាសុខាភិបាលនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង។[៤៩] សេដ្ឋកិច្ច និងវប្បធម៌ ក៏ជាកត្តាដ៏ចំបងផងដែរទាក់ទងនឹងលទ្ធ-ភាពរបស់ស្ត្រីជនជាតិដើមភាគតិចក្នុងការទទួលបានសេវាទាំងនេះ។

រដ្ឋាភិបាល បានទទួលស្គាល់ថា បញ្ហាប្រឈមទាក់ទងនឹងការថែទាំសុខភាពរបស់ស្ត្រី នៅតែបន្តកើតមាន និងជាពិសេសនោះសុខភាពបន្តពូជរបស់ស្ត្រីនៅកម្ពុជា។ ការទទួលស្គាល់នូវកង្វះខាតទាំងនេះមិនមានន័យថា កម្ពុជាត្រូវកាត់បន្ថយកាតព្វកិច្ចរបស់ខ្លួនក្នុងក្របខណ្ឌអនុសញ្ញា ស៊ី-ដវ ក្នុងការដោះស្រាយបញ្ហាវិសមភាពដ៏ធ្ងន់ធ្ងរទាំងនេះនោះទេ។ បើទោះ ជាមានការយកចិត្តទុកដាក់ទៅលើការសាងសង់មន្ទីរពេទ្យ និងការបែងចែកឲ្យបានកាន់តែប្រសើរនូវអ្នកឯកទេសផ្នែកថែទាំសុខភាពក៏ដោយ ក៏កម្ពុជាចាំបាច់ត្រូវសាងសង់បរិក្ខាថែទាំសុខភាពផងដែរជាពិសេសសម្រាប់ឆ្លើយតបទៅនឹងតម្រូវការថែទាំសុខភាពរបស់ស្ត្រី និងត្រូវជ្រើសរើសអ្នកឯកទេសខាងផ្នែកសុខាភិបាលដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការព្យាបាលស្ត្រីនៅកម្ពុជា ដោយមិនមានវិសមភាព ឬភាពលំអៀងឡើយ។

៤៩ NGO Forum on Cambodia 2006, ជនជាតិដើមភាគតិចនៅកម្ពុជា, http://www.ngoforum.org.kh/docs/publications/IMRP_INDIGENOUSPEOPLESINCAMBODIAfinal(3).pdf

៥០ Ibid.

# មាត្រា ១៣៖
# ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម



មាត្រា១៣ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី "ចាត់វាល់វិធានការសមស្របទាំងអស់ក្នុងការលុបបំបាត់ការរើសអើងលើ ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងជីវិតសង្គម ដើម្បីធានានូវសិទ្ធិស្មើគ្នាដោយផ្អែកលើគោល-ការណ៍សមភាពរវាងបុរស និងស្ត្រី"។ ពិសេសសិទ្ធិទទួលបានផលប្រយោជន៍គ្រួសារ សិទ្ធិខ្ចីប្រាក់ពី ធនាគារ សិទ្ធិបង់រំលួស និងសិទ្ធិក្នុងទម្រង់ផ្សេងទៀតនៃឥណទានហិរញ្ញវត្ថុ ព្រមទាំងសិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្តនានា ក៏ដូចជាសិទ្ធិចូលរួមគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតវប្បធម៌។ ដើម្បីឲ្យកាន់តែច្បាស់ មាត្រានេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែលុបបំបាត់ការរើសអើង ដែលកើតចេញពីរដ្ឋាភិបាលផ្ទាល់ ប៉ុណ្ណោះទេ ហើយក៏ត្រូវចាត់វិធានការនានាដើម្បធានាឲ្យផ្អែក ឯកជនឈប់រើសអើងស្ត្រីក្នុងវិស័យទាំងនេះ។

រាជរដ្ឋាភិបាល បានសង្ខេបមាត្រា ២៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលចែងថា "ក្នុងគ្រួសារមួយ ប្តី និងប្រពន្ធមានសិទ្ធិស្មើគ្នាគ្រប់ផ្នែកទាំងអស់" មុននឹងបន្តលើកឡើងនូវបទប្បញ្ញត្តិផ្សេងៗជាច្រើនទៀតក្នុងក្រមរដ្ឋប្បវេណី មានសញ្ញាបង្ហាញពីភាពចាំបាច់ក្នុងការបង្កើតអាជ្ញាធរស្របច្បាប់នាថ្ងៃខាងមុខ ដើម្បីសម្រួលឲ្យមានសមភាពរវាបុរស និងស្ត្រី នៅក្នុងគ្រួសារ។ជាថ្មីម្តងទៀត ដូចដែលបានលើកឡើងជាច្រើនដង ក្នុងរបាយការណ៍ស្រមោលនេះហើយថា ពេលមានតែច្បាប់ បទបញ្ជា និងបញ្ញត្តិផ្សេងៗដោយឥតមានធ្វើអ្វីបន្ថែមដើម្បីជំរុញឲ្យអនុវត្ត នោះរដ្ឋា-

## អនុសាសន៍៖

- កែសម្រួលច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីឲ្យបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការ រំលាយចំណងអាពាហ៍ពិពាហ៍។
- បង្កើនវគ្គបណ្តុះបណ្តាល អំពីជំនាញអ្នកដឹកនាំដល់ស្ត្រី ដើម្បីឲ្យស្ត្រីមានលទ្ធភាព ទទួលបានតួនាទីកាន់តែខ្ពស់ នៅក្នុងសង្គម ដែលធ្វើឲ្យមានការផ្លាស់ប្តូរ នូវទស្សនៈសង្គមទៅលើស្ត្រី ដែលទស្សនៈសង្គមនេះ បានឲ្យតម្លៃស្ត្រីទាបជាងបុរស។
- ធ្វើការពិនិត្យសើរើឲ្យបានហ្មត់ចត់ទៅលើច្បាប់ បញ្ញត្តិ បទបញ្ជា និងគោលនយោបាយទាំងអស់ និងលុបបំបាត់ការរើសអើងទាំងនៅក្នុងច្បាប់ ឬការរើសអើងជាក់ស្តែងលើស្ត្រី ក្នុងច្បាប់ទាំងនោះ។

ភិបាលផ្ទាល់តែម្តងមិនអនុវត្ត ដើម្បីដកចេញនូវប្រភេទនៃការរើសអើង ដែលអនុសញ្ញានេះប្រឹងប្រែងបង្ការនោះ។

ស្ត្រីនៅកម្ពុជា នឹងបន្តប្រឈមនឹងការប្រព្រឹត្តមកលើខ្លួនដោយវិសមភាព និងប្រឈមនឹងការរំលោភសិទ្ធិមនុស្សផ្សេងទៀត ប្រសិនណាច្បាប់ទាំងនេះ មិនត្រូវបានអនុវត្ត ឬយកទៅប្រើប្រាស់ និងប្រសិនណាមិនមាន កម្មវិធីជាវិជ្ជមានណាមួយត្រូវបានបង្កើតឡើង ដើម្បីកែប្រែនូវការអនុវត្តប្រពៃណីវប្បធម៌ពីអតីត ដែលបង្កឲ្យមានឥទ្ធិពលអវិជ្ជមានទៅលើស្ត្រី។ នៅដរាបណាតុលាការខ្វះឯករាជ្យភាព និងមានការបង់ប្រាក់ក្រៅប្រព័ន្ធតុលាការ នោះនឹងធ្វើឲ្យជនល្មើសរួចផុតពីការកាត់ទោសឬទោសទណ្ឌចំពោះអំពើរំលោភបំពាន។

ច្បាប់ បញ្ញត្តិ បទបញ្ជា និងគោល នយោបាយនានាដែលបានលើកឡើង ដោយរដ្ឋាភិបាលនោះមិនត្រូវបានយកមកអនុវត្តឲ្យបានត្រឹមត្រូវនោះទេ។ បុរសជាច្រើនស្ទើរគ្រប់ពេលតែងតែមានអំណាចខ្លាំងជាងស្ត្រីនៅក្នុងតុលាការ។ ការអនុវត្តប្រពៃណីវប្បធម៌ ក៏ណែនាំស្ត្រីឲ្យស្តាប់បង្គាប់ស្វាមីរបស់ខ្លួន។ ជារឿយៗ ស្ត្រីត្រូវទទួលរងឥទ្ធិពលពីស្វាមីរបស់ពួកគេ ក្នុងការព្រមព្រៀងជាមួយស្វាមីនៅមុខអាជ្ញាធរ។

មិនត្រឹមតែច្បាប់មិនត្រូវបានគេយកទៅអនុវត្តប៉ុណ្ណោះទេ ថែមទាំងខ្លឹមសារជាក់ស្តែងនៅក្នុងច្បាប់កម្ពុជាជាច្រើនបានប្រតិបត្តិទៅ ដើម្បីមិនផ្តល់សិទ្ធិ និងឱកាសស្មើគ្នារវាងស្ត្រី និងបុរស។ ជាឧទាហរណ៍ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ក្រោយពីការរំលាយចំណងអាពាហ៍ពិពាហ៍ ស្ត្រីត្រូវរងចាំរយៈពេល ៣០០ ថ្ងៃ[៥១] មុននឹងស្ត្រីអាចរៀបអាពាហ៍ពិពាហ៍សារជាថ្មីបាន ក៏ប៉ុន្តែពុំមានការកំណត់រយៈពេលរងចាំដូចគ្នានេះ សម្រាប់ភាគីបុរសនោះទេ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារក៏ដាក់កំណត់ថា បុគ្គលណាអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលណាបាន ដោយបានបញ្ញត្តិថាអាពាហ៍ពិពាហ៍ជាមួយភេទដូចគ្នា មិនត្រូវបានអនុញ្ញាតឡើយ និងបុគ្គលណា ដែលមានជម្ងឺមួយចំនួនមិនត្រូវបានអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍។

នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ស្ត្រី និងបុរសមានភាពស្មើគ្នាក្នុងផ្នែកសេដ្ឋកិច្ច។ ពួកគេមានសិទ្ធិស្មើគ្នាក្នុងការខ្ចីប្រាក់ពីធនាគារ និងសិទ្ធិក្នុងការទទួលបានឥណទានហិរញ្ញវត្ថុផ្សេងទៀតផងដែរ។ សកម្មភាពកំសាន្តកីឡា និងជីវិតវប្បធម៌ត្រូវបានបើកទូលាយ សម្រាប់ពលរដ្ឋគ្រប់រូបនៅកម្ពុជានៅក្នុងច្បាប់នេះ។ ទោះបីជាស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរស ក្នុងផ្នែកហិរញ្ញវត្ថុក៏ដោយ ក៏ក្នុងចំណងអាពាហ៍ពិពាហ៍ បុរសច្រើនតែគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិគ្រួសារ ដោយពុំបានផ្តល់សិទ្ធិក្នុងការសំរេចចិត្តឲ្យស្ត្រីឡើយ។

## អនុសាសន៍: (ត)

- បង្កើនការអនុវត្តទោសទណ្ឌ និងការដាក់ពិន័យចំពោះអំពើពុករលួយក្នុងប្រព័ន្ធតុលាការ និងនៅក្នុងចំណោមអាជ្ញាធរស្របច្បាប់ ដើម្បីធ្វើឲ្យមានការអនុវត្ត និងការប្រើប្រាស់ច្បាប់ផ្សេងៗរបស់ប្រទេសកម្ពុជា។

[៥១] បច្ចុប្បន្នរយៈពេលរងចាំសម្រាប់ស្ត្រីត្រូវបានកាត់បន្ថយមកត្រឹមរយៈពេល ១២០ ថ្ងៃ នៅក្នុងក្រមរដ្ឋប្បវេណី

# មាត្រា ១៤៖ ស្ត្រីរស់នៅជនបទ



រូបថត លីកាដូ

មាត្រា១៤ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី (១) គិតគូរពីបញ្ហាដែលស្ត្រីនៅជនបទកំពុងប្រឈម និងតួនាទីសំខាន់របស់ស្ត្រីជនបទក្នុងការរក្សាភាពគង់វង្សនៃសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន។(២) ធានានូវការអនុវត្តគ្រប់បទប្បញ្ញត្តិទាំងអស់ក្នុងអនុសញ្ញា ស៊ី-ដវ ដែលសំដៅលើស្ត្រីនៅតំបន់ជនបទ (៣) ចាត់គ្រប់វិធានការទាំងអស់ក្នុងការលុបបំបាត់ការរើសអើងលើស្ត្រីនៅតំបន់ជនបទ ដោយយធានាថា ស្ត្រីទាំងឡាយអាចចូលរួមដោយស្មើភាពគ្នានឹងបុរសក្នុងការអភិវឌ្ឍន៍ និងផែនការអភិវឌ្ឍន៍ជនបទ ដោយធានាថា ស្ត្រីអាចទទួលបានសេវាថែទាំសុខភាពគ្រប់គ្រាន់ និងព័ត៌មានអំពីផែនការគ្រួសារ ការពិគ្រោះយោបល់សេវាផលប្រយោជន៍ពីសន្តិសុខសង្គម ការទទួលបានការបណ្តុះបណ្តា ល និងការអប់រំគ្រប់ប្រភេទទាំងអស់បង្កើតក្រុមជួយខ្លួន ឯ ង ដើម្បី អាចទទួលបានឱកាសក្នុងផ្នែកសេដ្ឋកិច្ច ឬផ្តល់ការងារឲ្យខ្លួនឯងការប្រព្រឹត្តមកលើខ្លួនដោយស្មើភាពក្នុងការកែទម្រង់ដីធ្លី និងគម្រោងតាំងទីលំនៅថ្មី និងលក្ខខណ្ឌរស់នៅសមរម្យ ជាពិសេសនោះពាក់ព័ន្ធនឹងការទទួលបានទីលំនៅអនាម័យ ភ្លើងអគ្គីសនី និងការផ្គត់ផ្គង់ទឹក មធ្យោបាយដឹកជញ្ជូន និងទូរគមនាគមន៍ជាដើម។

រដ្ឋាភិបាលបានលើកឡើងថា "កិច្ចប្រឹងប្រែងរួម" ត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជា ហើយថាភាពរីកចម្រើនក្នុងគ្រប់វិស័យក្នុងការធ្វើឲ្យមានកម្រិតស្មើគ្នានៃជីវភាពរស់នៅ និងសេវានានារវាង

## អនុសាសន៍៖

- រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើតផែនការហិរញ្ញវត្ថុជាមួយគ្រួសារទាំងឡាយ មុននឹងផ្តល់ប្រាក់កម្ចី។
- រដ្ឋាភិបាល គួរផ្តល់ឥណទានដោយមានអត្រាការប្រាក់ទាបបំផុតដល់ស្ត្រីនៅជនបទ។
- រដ្ឋាភិបាល គួរបង្កើនចំនួនអាហារូបករណ៍ដល់កុមារ ដែលនៅតាមជនបទ។
- រដ្ឋាភិបាល គួរកែលំអរសេវាថែទាំសុខភាព ដោយឥតមានបង់ថ្លៃនៅជនបទ។ រដ្ឋាភិបាលគួរផ្តល់សេវា ដឹកជញ្ជូនដែលអាចទុកចិត្តបានដល់កុមារ ដែលត្រូវធ្វើដំណើរទៅសាលារៀន។

តំបន់ជនបទ និងទីក្រុង។ ជាភស្តុតាងនៃ "កិច្ចប្រឹងប្រែងរួម" នេះរាជរដ្ឋាភិបាល បានផ្តល់គំរូអំពីវិធានការដែលរដ្ឋាភិបាលបានអនុវត្តដើម្បី "លើកកម្ពស់សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី នៅតំបន់ជនបទ" និងដើម្បីកែលំអរជីវភាពរស់នៅនៅជនបទ។ គំរូទាំងនោះ រួមមាន ការស្ថាបនាផ្លូវថ្មីៗ ដែលតភ្ជាប់ពីទីក្រុងទៅតំបន់ជនបទតាមបណ្តាខេត្តនានា ការស្តារផ្លូវរថភ្លើង ការស្ថាបនាស្ពាន និងគម្រោងធារាសាស្ត្រ ព្រមទាំងការផ្តួចផ្តើមគម្រោងសាងសង់ មួយចំនួនផ្សេងទៀត។

លទ្ធផលជាក់ស្តែងគឺថា គំនិតផ្តួចផ្តើមនានាដូចបានសង្ខេបខាងលើ ក៏ដូចជាចំណុចផ្សេងទៀតដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា មានប្រសិទ្ធិភាពតិចតួចក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅជាក់ស្តែងដល់ប្រជា-ពលរដ្ឋនៅជនបទ ក្នុងការបញ្ឈប់ការដណ្តើមយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ ឬក្នុងការប្រយុទ្ធប្រឆាំងនឹងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ ដែលកើតចេញពីការអនុវត្តសកម្មភាពទាំងនេះលើប្រជាពល - រដ្ឋនៅជនបទ (និងទីប្រជុំជន) ឬ ក្នុងការលើកកម្ពស់ពិតប្រាកដនូវសមភាពរវាងស្ត្រី និងបុរស។ នៅពេលមានការសាងសង់ផ្លូវថ្មីក្តី ឬមានស្ពានថ្មីក្តីនៅតំបន់ណា ដែលមិនទាន់មានផ្លូវ ស្ពាន ពីមុនមក ឃើញថាមានការជួយតិចតួចដល់ក្រុមគ្រួសារ ដែលត្រូវផ្លាស់ចេញពីទីលំនៅរបស់ខ្លួនទាំងបង្ខំ ឬពួកគាត់ក៏មិនមានលទ្ធភាពទិញម៉ូតូ ឬរថយន្តជិះឆ្លងកាត់ផ្លូវទាំងនេះបាននោះដែរ។ គំនិតផ្តួចផ្តើមនានាដែលត្រូវបានអនុវត្តកន្លងមក អាចផ្តល់អត្ថប្រយោជន៍នាពេលក្រោយ ក៏ដោយ ក៏មានលទ្ធផលតិចតួចប៉ុណ្ណោះ ប្រសិនណាមិនមានសាលារៀន សេវាថែទាំសុខភាព និងសេវាដទៃទៀត ឬឱកាសការងារឲ្យបានគ្រប់គ្រាន់នៅទីជនបទនោះទេ។

ប្រភពព័ត៌មានរបស់យើង បានប្រាប់ឲ្យដឹងថា សូម្បីតែតំបន់ដែលមានការស្ថាបនាផ្លូវថ្មីៗ ក៏ដោយ ក៏ផ្លូវទាំងនោះ ពុំបានជួយបង្កើតឲ្យមានឱកាសសេដ្ឋកិច្ចកើនឡើងសម្រាប់ស្ត្រីនៅជនបទនោះដែរ ដោយសារការទទួលខុសត្រូវរបស់ពួកគាត់ ទៅលើកិច្ចការក្នុងផ្ទះ រួមទាំងកង្វះមធ្យោបាយធ្វើដំណើរផងដែរ។ លើសពីនេះទៀត យើងបានកត់សំគាល់ឃើញថា រដ្ឋាភិបាលក៏យល់ស្របថា រដ្ឋាភិបាលមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវា ដែលចាំបាច់នានាសម្រាប់ស្ត្រីនៅជនបទនៅឡើយទេ នៅត្រង់ចំណុចនេះ យើងសូមគូសបញ្ជាក់ថា ចំណុចជាក់ស្តែងនៅក្នុងមាត្រា១៤ នៃអនុសញ្ញា ស៊ី-ដរ គឺសំដៅផ្តល់សេវាចាំបាច់នានាដោយស្មើភាពដល់ស្ត្រីនៅជនបទ។ ដូចគ្នានេះដែរ បើទោះបីជាមានការសាងសង់ស្ពាន និងផ្លូវក៏ដោយ ដូចគ្នានេះដែរ បើទោះបីជាមានការសាងសង់ស្ពាន និងផ្លូវក៏ដោយ តែបើគ្មានកិច្ចប្រឹងប្រែងពិតប្រាកដក្នុងការធ្វើឲ្យមានសមភាព នូវស្ថានភាពរស់នៅដល់ស្ត្រីនៅតំបន់ជនបទ នោះមានន័យថា មិនបានបំពេញតាមលក្ខខណ្ឌនានានៃមាត្រានេះទេ។ ថ្វីត្បិតតែមានការរីកចម្រើនទាំងនេះក៏ដោយ ក៏ការស្រាវជ្រាវរបស់យើង បានបង្ហាញថា តំបន់ជនបទនៅអន់ខ្សោយជាងតំបន់ទីក្រុងលើគ្រប់វិស័យទាំងអស់ និងនៅមិនទាន់មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅឡើយទេ។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានទទួលស្គាល់សារៈសំខាន់នៃតួនាទីរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ច ដោយមិនទទួលបានប្រាក់ឈ្នួល។[៩២] យើងមានការសោកស្តាយ ចំពោះការទទួលស្គាល់របស់រដ្ឋាភិបាល ទៅលើការងារដែលមិនទទួលបានប្រាក់កម្រៃ ព្រោះថា ការទទួលស្គាល់បែបនេះ មានអត្ថន័យតិចតួច ដោយហេតុថា អត្ថប្រយោជន៍សេដ្ឋកិច្ច និងសង្គម មិនត្រូវបានផ្តល់ទៅឲ្យអ្នកធ្វើការ ដែលឥតទទួលបានប្រាក់កម្រៃទាំងនេះទេ នេះបើយោងតាមក្រុមអ្នកអង្កេតការណ៍នៅកម្ពុជា។ ប្រការនេះ មានន័យថា ស្ត្រីដែលធ្វើការនៅក្នុងវិស័យ ដែលមិនទទួលបានប្រាក់កម្រៃ មិនទទួលបានផលប្រយោជន៍នានាដូចជា ការថែទាំសុខភាព ការឈប់សម្រាកលំហែមាតុភាព និងសិទ្ធិមូលដ្ឋាននៅក្នុងច្បាប់ការងារជាដើម។ យោងតាមកថាខណ្ឌទី ១៨៣ នៃរបាយការណ៍ជាតិ រដ្ឋា-

[៩២] កម្ពុជា: រាជរដ្ឋភាបិលាកម្ពុជា. របាយការណ៍ជាតិគួបលើកទី ៤ និងទី ៥ ស្តីពីការអនុវត្តិអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចលើស្ត្រី នៅកម្ពុជា ។ ៥៤-៥៥. ភ្នពេញ កម្ពុជា ឧសភា ២០១០ ។

ភិបាលបានសន្យាថានឹង "លើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងគ្រប់វិស័យ និងនៅតាមតំបន់ដាច់ស្រយាលផងដែរ" ក៏ប៉ុន្តែមានស្ត្រីជាច្រើនរស់នៅតំបន់ដាច់ស្រយាល ដែលពួកគាត់មានឱកាសតិចតួចរហូតគ្មានឱកាសសោះ ក្នុងការធ្វើឲ្យប្រសើរឡើងនូវភាពមាំទាំផ្នែកសេដ្ឋកិច្ចរបស់ខ្លួន ដោយសារការកម្រិតពីក្រុមគ្រួសារ និងកង្វះការបណ្តុះបណ្តាល ការអប់រំ និងជំនាញនានា។[៥៣]

រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងបន្ថែមទៀតថា រដ្ឋាភិបាលបាន "ពង្រីកប្រព័ន្ធថែទាំសុខភាពតាមរយៈការកសាងអគារមន្ទីរពេទ្យ ព្រមទាំងបញ្ជូនបុគ្គលិកសុខាភិបាល ទៅតាមសហគមន៍នៅជនបទនានាដើម្បីជួយស្ត្រីអាចមានលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងការព្យាបាលកាន់តែល្អប្រសើរជាងមុន។" ថ្វីត្បិតនេះជាការពិតដែលថា ក្រោមកិច្ចសហការជាមួយរដ្ឋាភិបាលបរទេសមួយចំនួន រដ្ឋាភិបាលកម្ពុជាបានសាងសង់អគារមន្ទីរពេទ្យបន្ថែម ប៉ុន្តែតាមការត្រួតពិនិត្យមើលពីប្រភពព័ត៌មាន របស់យើងលើមណ្ឌលសុខភាពទាំងនេះ បានរកឃើញថា មានចំណុចអវិជ្ជមាន ដោយសារស្ត្រីត្រូវធ្វើដំណើរឆ្ងាយដើម្បីទទួលបានការថែទាំសុខភាព ប៉ុន្តែអ្វីដែលពួកគេទទួលបាន គឺត្រឹមដឹងថា នៅមណ្ឌលសុខភាពមិនមានការព្យាបាលសមរម្យសម្រាប់ពួកគេ មិនមានថ្នាំគ្រប់គ្រាន់ ឬបុគ្គលិកពេទ្យខ្លះផ្តល់ថ្នាំឲ្យពួកគេមិនត្រឹមត្រូវទៀតផង។ គ្រឿងបរិក្ខារនៅមណ្ឌលសុខភាពមិនមានអនាម័យ និងបុគ្គលិកពេទ្យមិនស្ម័គ្រចិត្តជួយពួកគេនោះទេ។ ទោះបីជាការថែទាំសុខភាពមិនមានការបង់ប្រាក់ក៏ដោយ ក៏ការព្យាបាលពិតជាត្រូវការចំណាយថវិកា ហើយស្ត្រីជាច្រើននៅជនបទមិនអាចមានលទ្ធភាពបង់ថវិកានេះបានទេ ដូច្នេះការធ្វើដំណើរដើម្បីស្វែងរកការពិគ្រោះយោបល់សុខភាពហាក់ដូចជាបានជួយតិចតួចប៉ុណ្ណោះ។ យើងក៏ទទួលបានរបាយការណ៍នានាដែលបានប្រាប់ឲ្យដឹងថា វេជ្ជបណ្ឌិតមួយចំនួននៅពេលម៉ោងធ្វើការរបស់ខ្លួន បានស្នើឲ្យអ្នកជម្ងឺ បង់ប្រាក់លើសេវាដែលមិនត្រូវបង់ថ្លៃ និងបដិសេធមិនផ្តល់ការព្យាបាល ប្រសិនមិនបង់ប្រាក់ក្រៅផ្លូវការទាំងនេះនោះទេ។ ទីបំផុត នៅមិនទាន់មានភាពច្បាស់លាស់អំពីអគារថ្មីៗដែលត្រូវបានសាងសង់ និងត្រូវ


រូបថត លីកាដូ

បានបង្កើតឡើងសម្រាប់ផ្តល់សេវា ដែលជាតម្រូវការរបស់ស្ត្រី ជាពិសេសសម្រាប់ផ្តល់ការព្យាបាល និងផ្តល់ការថែទាំសុខភាពដល់ស្ត្រីនោះទេ។

បន្ថែមពីការផ្តល់ព័ត៌មានអំពីការរីកចម្រើនដែលមិនមានភាពច្បាស់លាស់នេះ ហើយត្រូវបានចាត់ទុកថាជាការធ្វើឲ្យមានសមភាព រវាងស្ថានភាពស្ត្រីដែលរស់នៅតំបន់ជនបទ និងស្ថានភាពស្ត្រីដែលរស់នៅទីប្រជុំជន រដ្ឋាភិបាលក៏បានលើកឡើងពីមាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានចែងថា រដ្ឋាភិបាលកម្ពុជា និងសង្គម "ត្រូវផ្តល់ឱកាសដល់ស្ត្រីពិសេសដល់ស្ត្រីរស់នៅតាមទីជនបទ ដែលមិនទទួលបានជំនួយគាំទ្រពីសង្គមគ្រប់គ្រាន់នោះ ដើម្បីឲ្យពួកគាត់ទទួលបានការងារធ្វើ និងការថែទាំសុខភាព បញ្ជូនកូនទៅសាលារៀន និងទទួលបានជីវភាពរស់នៅសមរម្យ។" ប៉ុន្តែពាក្យសម្តីទាំងនេះ មិនត្រូវបានយកទៅអនុវត្ត និងមិនត្រូវបានយកទៅប្រើប្រាស់

[៥៣] អ៊ិន ជី អូ ស៊ី-ដវ ការសម្ភាសន៍ជាលក្ខណបុគ្គល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣

យកទៅអនុវត្ត និងមិនត្រូវបានយកទៅប្រើប្រាស់នោះទេ ហើយមិនតែប៉ុណ្ណោះ វិធានការនានាដែលបានអនុវត្តកន្លងមក គឺមិនទាន់បានគ្រប់គ្រាន់នៅឡើយទេទាក់ទងនឹងកាតព្វកិច្ចក្នុងការធ្វើឲ្យប្រជាពលរដ្ឋទទួលបានសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញនោះ។

រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងថា រដ្ឋាភិបាលបានផ្តល់ថវិកា ៦៥% នៃកញ្ចប់ថវិកាសម្រាប់កាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងបានផ្តល់ ៣៥% នៃកញ្ចប់ថវិកានេះ សម្រាប់តំបន់ប្រជុំជន ការផ្តល់ថវិកានេះ គឺសំដៅដោះស្រាយបញ្ហាវិសមភាពដែលប្រជាពលរដ្ឋកម្ពុជា នៅជនបទកំពុងប្រឈម។[៥៤] ទោះជាយ៉ាងនេះក្តី ក៏ចំនួនមូលនិធិដែលផ្តល់ឲ្យតំបន់ជនបទនេះ នៅតែជាការបែងចែកមួយដែលមានលក្ខណៈវិសមាមាត្រនៅឡើយ ដោយសារចំនួនប្រជាពលរដ្ឋជនបទនៅកម្ពុជា សរុបប្រមាណ ៨០% នៃចំនួនប្រជាពលរដ្ឋសរុប។[៥៥] ប្រការនេះបានបង្ហាញថា ចំនួនមូលនិធិទាំងនេះ មិនទាន់ធ្វើឲ្យមានការផ្លាស់ប្តូរស្ថានភាពរបស់ស្ត្រីនៅជនបទទេ ហើយក៏មិនច្បាស់ដែរថា តើមូលនិធិទាំងអស់នោះយកទៅប្រើប្រាស់របៀបណាដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា ឃុំ/សង្កាត់នីមួយៗយ៉ាងតិចគួរមានស្ត្រីម្នាក់ទទួលបន្ទុកការងារស្ត្រី និងកុមារតាមរយៈគណកម្មាធិការដើម្បីស្ត្រី និងកុមារ។ ស្ត្រីគួរធ្វើការតស៊ូមតិទៅលើគោលនយោបាយទាំងឡាយណា ដែលធ្វើឡើងសម្រាប់សហគមន៍របស់ខ្លួន។ មិនមានព័ត៌មានណាត្រូវបានធ្វើការផ្សព្វផ្សាយ ថាតើអ្វីដែលបានលើកឡើងនេះត្រូវបានអនុវត្តឬយ៉ាងណាឬថាតើការលើកឡើងនេះមានប្រសិទ្ធិភាព ដែលអាចជំរុញឲ្យស្ត្រីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្ត ឬយ៉ាងណា។ ក៏ប៉ុន្តែ គេក៏ទទួលស្គាល់ជាទូទៅដែលថា ស្ត្រីនៅជនបទខ្វះការអប់រំ ហើយនេះជាការលំបាកក្នុងការស្វែងរកស្ត្រីដែលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើសេចក្តីសំរេចចិត្តបែបនេះ។ លើសពីនេះទៀត ដោយសារតែស្ត្រីនៅជនបទមិនដឹងពីសិទ្ធិរបស់ខ្លួន ហើយពួកគាត់ភាគច្រើនមិនបានដឹងថា រដ្ឋាភិបាលបានផ្តល់អំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដល់ពួកគាត់នោះដែរ ហេតុដូច្នេះទើបធ្វើឲ្យគោលនយោបាយនេះពិបាកអនុវត្តទៅបាន។

រដ្ឋាភិបាល បានលើកឡើងថា ស្ត្រីមានលទ្ធភាពបញ្ចេញមតិយោបល់ និងចូលរួមចំណែកក្នុងដំណើរការ នៃការធ្វើសេក្តីសម្រេចចិត្តតាមរយៈតំណាងរបស់ខ្លួនដែលបានជាប់ឆ្នោត។ ក៏ប៉ុន្តែ ក្នុងចំណោមមេដឹកនាំដែលបានជាប់ឆ្នោតទាំងនេះ ភាគច្រើនលើសលប់ គឺជាបុរស ហើយជារឿយៗ បញ្ហាគឺនៅត្រង់ថា នៅដែលពេលស្ត្រីលើកឡើងពីក្តីកង្វល់របស់ខ្លួន ប៉ុន្តែក្តីកង្វល់របស់ពួកគេមិនត្រូវបានយកចិត្តទុកដាក់នោះទេ ក្រោមការដោះសារថា គេត្រូវផ្តល់អាទិភាពទៅលើបញ្ហាផ្សេងៗវិញ ដែលកត្តានេះធ្វើឲ្យស្ត្រីឃ្លាតចេញពីតួនាទីធ្វើសេក្តីសម្រេចចិត្ត។ ដូចដែលបានលើកពីខាងដើមស្ត្រីនៅជនបទរៀនសូត្របានតិចតួច និងមានអារម្មណ៍មិនមានសុវត្ថិភាពនៅពេលបង្ហាញពីក្តីកង្វល់ទៅដល់អ្នកនយោបាយ ដែលមានសិទ្ធិអំណាចនោះ។

រាជរដ្ឋាភិបាល បានអនុវត្តកម្មវិធីផ្តល់ "ប័ណ្ណក្រីក្រ" ឬ "ប័ណ្ណសម្គាល់គ្រួសារក្រីក្រ"កម្មវិធីនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់សេវាថែទាំសុខភាពដល់គ្រួសារក្រីក្រនៅជនបទដែលរដ្ឋាភិបាលបានកំណត់ពីមុនមក។ ក៏ប៉ុន្តែវិសាលភាព និងសេវានៃវិធីកម្មនេះនៅមានកម្រិតនៅឡើយ។

រាជរដ្ឋាភិបាលបានលើកឡើងថា រដ្ឋាភិបាលបាន "ពង្រីកវិសាលភាព សមត្ថភាព និងប្រសិទ្ធិភាពនៃប្រព័ន្ធផ្សព្វផ្សាយ" ទៅដល់ប្រជាពរដ្ឋទាំងអស់ ជាពិសេសប្រជាពលរដ្ឋនៅជនបទ។ រដ្ឋាភិបាលជឿថាកិច្ចប្រឹងប្រែងនេះ អាចជួយធ្វើការអប់រំអំពីសិទ្ធិមនុស្ស និងបញ្ហាផ្សេងៗដែលកើតមានក្នុងពេលបច្ចុប្បន្ន។[៥៦] ក៏ប៉ុន្តែ នៅតាមតំបន់ជនបទជាច្រើន

[៥៤] កម្ពុជា: រាជរដ្ឋភាបិលាកម្ពុជា. របាយការណ៍ជាតិគួបលើកទី ៤ និង ទី ៥ ស្តីពីការអនុវត្តិអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី នៅកម្ពុជា. ៤៥. ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០ ។

[៥៥] http://www.un.org.kh/undp/what-we-do/poverty-reduction/poverty-reduction

[៥៦] កម្ពុជា: រាជរដ្ឋាភិបាលកម្ពុជា. របាយការណ៍ជាតិគួបលើកទី ៤ និងទី ៥ ស្តីពីការអនុវត្តិអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី នៅកម្ពុជា. ៤៦. ភ្នំពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០ ។

ឡើយ ដោយសារប្រជាពលរដ្ឋខ្វះខាតថវិកាទិញឧបករណ៍ចាប់យកការផ្សាយ ដូចជា ទូរទស្សន៍ និងវិទ្យុជាដើម។ ម្យ៉ាងវិញទៀត ក៏តម្រូវឲ្យមានទិន្នន័យបន្ថែមទៀតអំពីឧបករណ៍ចល័ត ព្រោះថាឧបករណ៍ទាំងនេះទាក់ទិនទៅនឹងបញ្ហានេះ។

យោងតាមរបាយការណ៍ របស់រដ្ឋាភិបាល ដោយបានលើកឡើងថា រដ្ឋាភិបាលបានបង្កើតមណ្ឌលចំនួន១១ កន្លែងសម្រាប់ស្ត្រីនៅទូទាំងប្រទេសកម្ពុជា ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងព័ត៌មានអំពីធុរកិច្ច។ គ្មានការផ្ដល់ព័ត៌មានអំពីប្រសិទ្ធិភាពនៃកម្មវិធីនេះ ឬអំពីការចូលរួមរបស់ស្ត្រីឡើយ។ លើសពីនេះទៀត ក៏គ្មានព័ត៌មានអំពីចំនួនស្ត្រីដែលអាចចូលរួម ឬនីតិវិធីនៃការជ្រើសរើសប្រជាពលរដ្ឋឲ្យចូលរួមនៅក្នុងកម្មវិធីនេះដែរ។[៥៧]

រាជរដ្ឋាភិបាលមិនបានលើកយកបញ្ហាសន្តិសុខស្បៀង និងកង្វះម្ហូបអាហារក្នុងចំណោមប្រជាពលរដ្ឋនៅជនបទនោះទេ។ យោងតាមការសិក្សាស្រាវជ្រាវថ្នាក់ជាតិរបស់កម្ពុជាអំពីសុខភាព និងប្រជាសាស្ត្របានបង្ហាញថា ស្ត្រីនៅជនបទតែងតែខ្វះសារធាតុចិញ្ចឹមជាងស្ត្រីនៅទីក្រុង ដោយសារកង្វះម្ហូបអាហារ និងជីវជាតិបំប៉នសំខាន់ៗ។[៥៨]

រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងអំពីកម្មវិធីកម្ចីខ្នាតតូច ដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ជួយដល់ប្រជាពលរដ្ឋនៅតាមជនបទក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ កម្មវិធីនេះ បានផ្ដល់ "កម្ចីសរុប ៥,៥៦ ពាន់លានរៀល ដល់ប្រជាពលរដ្ឋចំនួន ១១៦៦១ នាក់ ក្នុងនោះមានស្ត្រីចំនួន ៨៨៤២ នាក់ នៅក្នុងភូមិគោលដៅចំនួន ២៩៨។"[៥៩] ក៏ប៉ុន្តែមានការព្រួយបារម្ភអំពីនីតិវិធីនៃការអនុវត្តប្រាក់កម្ចីខ្នាតតូច នៅក្នុងប្រទេសកម្ពុជា៖ ជារឿយៗមានកម្រិតតិចតួចចំពោះការរៀបចំផែនការ ឬការអប់រំអំពីហិរញ្ញវត្ថុឥណទាន សេដ្ឋកិច្ច និងអំពីការចំណាយឲ្យមានប្រសិទ្ធភាពមុននឹងផ្ដល់ប្រាក់កម្ចី ដូច្នេះគ្រួសារជាច្រើនបានធ្លាក់ក្នុងស្ថានភាពកាន់តែពិបាកក្រោយពីបានទទួលប្រាក់កម្ចី ពីព្រោះពួកគាត់ចំណាយលុយទាំងនោះយ៉ាងឆាប់រហ័ស និងគ្មានប្រសិទ្ធិភាព ហើយការបង់ការប្រាក់ក៏ជំរុញឲ្យក្រុមគ្រួសារធ្លាក់ក្នុងបំណុលកាន់តែច្រើនឡើង។

រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្ត "កម្មវិធីកំណែទម្រង់ការគ្រប់គ្រងដីធ្លី" ដែលបង្កើតឡើងដើម្បី "ពង្រឹងភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋដែលត្រូវការដីសម្រាប់សាងសង់ទីលំនៅ និងធ្វើកសិកម្មចិញ្ចឹមជីវិត។" អ្វីដែលចម្លែកខ្លាំងនោះ គឺថារដ្ឋាភិបាលកម្ពុជាច្រើនតែដកយកដីធ្លីពីប្រជាពលរដ្ឋ ដោយគ្មានផ្ដល់សំណងសម្រាប់ផ្ទះសម្បែងរបស់ពួកគេ ឬជួយពួកគេក្នុងការស្វែងរកការងារថ្មីនោះទេ ថែមទាំងបញ្ជូនពួកគេឲ្យទៅតបន់ឆ្ងាយ ដើម្បីស្វែងរកទីកន្លែងថ្មីសម្រាប់រស់នៅ។ ការអនុវត្តផ្ទុយគ្នានោះគឺថា រដ្ឋាភិបាលមើលទៅហាក់ដូចជាកំពុងប្រឹងប្រែងជួយដល់ប្រជាពលរដ្ឋឲ្យទទួលបានដីធ្លី ក៏ប៉ុន្តែការពិតនោះគឺថាមានការបណ្ដេញចេញដោយបង្ខំ ដែលកើតមានឡើងជាញឹកញាប់ ហើយទង្វើនេះបានប៉ះពាល់ដល់ប្រជាពលរដ្ឋជាច្រើននាក់ ជាពិសេសនោះបានប៉ះពាល់ដល់ស្ត្រីនៅជនបទ ដោយសារជីវិតរបស់ពួកគេរស់ពឹងអាស្រ័យលើដីធ្លីរបស់ពួកគេ។ ក្ដីសង្ឃឹមនៅក្នុងជីវិតរបស់ស្ត្រីនៅជនបទ គឺការមើលថែកូន ដីធ្លី និងផ្ទះសម្បែង ហើយប្រសិនក្ដីសង្ឃឹមត្រូវដកហូតពីពួកគេ នោះពួកគេនឹងបាត់បង់អ្វីៗជាច្រើនទៀត ក្រៅពីបាត់បង់ផ្ទះសម្បែង ពួកគេក៏នឹងបាត់បង់ជីវភាពរស់នៅថែមទៀត។[៦០,៦១]

ទីជំរករបស់អ្នកត្រូវបានគេបណ្ដេញចេញដោយ

[៥៧] កម្ពុជា: រាជរដ្ឋភាបិលាកម្ពុជា. របាយការណ៍ជាតិគួបលើកទី ៤ និងទី ៥ ស្តីពីការអនុវត្តិអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី នៅកម្ពុជា. ៤៧. ភ្នពេំញ កម្ពុជា ខែឧសភា ២០១០ ។

[៥៨] វិទ្យស្ថានជាតិស្ថិតិ៖ អគ្គនាយកដ្ឋាន សុខភាព ប្រជាសាស្ត្រ និង ICF Macro ២០១១. កម្ពុជា. ការសិក្សាស្រាវជ្រាវអំពីប្រជាសាស្ត្រ និងសុខភាព ២០១០. ១៦៧. ភ្នពេញ កម្ពុជា និង Calverton and Maryland, USA: វិទ្យាស្ថានជាតិស្ថិតិកម្ពុជា: អគ្គនាយកដ្ឋានសុខភាព និង ICF Macro។

[៥៩] កម្ពុជា: រាជរដ្ឋភាបិលាកម្ពុជា របាយការណ៍ជាតិគួបលើកទី៤ និងទី៥ ស្តីពីការអនុវត្តិអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី នៅកម្ពុជា៤៨. ភ្នពេញ កម្ពុជា ខែឧសភា ឆ្នាំ២០១០ ។

[៦០] ការរំលោភយកដីធ្លី និងភាពក្រីក្រ នៅកម្ពុជា: "រឿងដើមពាក់ព័ន្ធនឹងការអភិវឌ្ឍន៍." លីកាដូ. ខែឧសភា ឆ្នាំ ២០០៩។

[៦១] "ចំណុចសំខាន់នាំឱ្យមានការផ្លាស់ប្តូរ? ដីធ្លី ទីលំនៅ និងធនធានធម្មជាតិ ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១២" ។ សមាគមសិទ្ធិមនុស្សកម្ពុជា និងការអភិវឌ្ឍន៍ ខែកុម្ភៈ ឆ្នាំ២០១៣។

បង្ខំ ដែលស្ថិតនៅក្នុងតំបន់តាំងទីលំនៅថ្មីរបស់រដ្ឋាភិបាលនោះ គឺជាតំបន់មានលក្ខណៈពិបាកខ្លាំង និងមិនអំណោយផលនោះទេ។ តម្រូវការជាមូលដ្ឋានសំខាន់បំផុតនានា (ជម្រក ទឹកស្អាត និងម្ហូបអាហារដែលមានជីវជាតិគ្រប់គ្រាន់ មិនអាចបំពេញបាននោះទេ ដោយសារអត្រានៃជម្ងឺ និងកង្វះអាហារូបត្ថម្ភមានកម្រិតខ្ពស់។

បញ្ហារំលោភយកដីធ្លីនាពេលបច្ចុប្បន្ន បានផ្តល់ផលប៉ះពាល់ជាអវិជ្ជមាន ប្រកបដោយភាពមិនស្មើគ្នាដល់ស្ត្រីនៅកម្ពុជា។ ជារឿយៗ នៅពេលដែលគ្រួសារមួយបានបាត់បង់ដីធ្លីរបស់ពួកគាត់ បុរសជាស្វាមីនឹងទៅស្នាក់នៅទីក្រុងដើម្បីស្វែងរកការងារធ្វើ នៅខណៈដែលគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនទៅតំបន់តាំងទីលំនៅថ្មី។ បញ្ហានេះបានដាក់បន្ទុកយ៉ាងធ្ងន់ទៅលើស្ត្រី ពីព្រោះពួកគាត់ត្រូវនៅមើលថែទាំរាល់សម្ភារៈរបស់ខ្លួននៅក្នុងតំបន់ថ្មីនោះ ដោយសង្ឃឹមថានឹងទទួលបានដីមួយប្លង់តូច និងជំនួយគាំទ្រមួយចំនួនពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានា។ ពួកគាត់ត្រូវស្នាក់នៅជាមួយកូនៗ ហើយមើលថែទាំសុខភាព និងផ្តត់ផ្គង់តម្រូវការនៃការអប់រំរបស់កូនៗ ដែលស្ត្រីតែម្នាក់ឯងត្រូវដើរតួរជាម្តាយផង និងជាឪពុកផង។ ចំណែកឯស្វាមីវិញ នៅគ្រាដំបូងបានមកលេងប្រពន្ធ និងកូនរបស់ខ្លួនជាញឹកញាប់ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន គ្រួសារជាច្រើនត្រូវបែកបាក់គ្នា ដោយសារតែរងសម្ពាពពីស្ថានភាពដ៏លំបាកនេះ។ នៅក្នុងស្ថានភាពបែបនេះ ស្ត្រីត្រូវទទួលរងគ្រោះពីរលើកដោយមួយលើកត្រូវបាត់បង់ផ្ទះសម្បែង និងដីរបស់ខ្លួន ហើយមួយលើកទៀត ត្រូវបាត់បង់ស្វាមី និងអ្នកផ្គត់ផ្គង់ក្នុងគ្រួសារ។ នៅក្នុងស្ថានភាពនេះ ម្ហូបអាហារក៏មានតិចតួច ហើយការងារក៏មិនសូវសម្បូរផងដែរនៅក្បែរតំបន់តាំងទីលំនៅថ្មីនេះ។ ស្ត្រីត្រូវក្លាយជាជនងាយរងគ្រោះទៅនឹងកំណើនអត្រា នៃរោគញៀនស្រា និងអំពើហិង្សាផ្លូវភេទ។

រាជរដ្ឋាភិបាលបានធ្វើសេក្តីសន្និដ្ឋាន ដែលផ្អែកទៅលើកម្មវិធីនានារបស់រដ្ឋាភិបាល ដោយលើកឡើងថាស្ថានភាពរបស់ស្ត្រីនៅជនបទនឹងមានការរីកចម្រើនមួយតំណាក់កាលម្តងៗ។ ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានកំណត់នូវគោលដៅ ក៏ដូចជាកាលបរិច្ឆេទដែលត្រូវធ្វើឲ្យសម្រេចបាននូវការរីកចម្រើន ព្រមទាំងមិនបានកំណត់នីតិវិធី នៃការវាយតម្លៃទៅលើការរីកចម្រើនមួយតំណាក់កាលម្តងៗនេះនោះទេ។ ដោយសារមិនមានការកំណត់នូវក្រុមគោលដៅ ឬមិនមានវិធីសាស្ត្រត្រួតពិនិត្យនោះ បានបង្ហាញឲ្យឃើញច្បាស់ថាមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ ទៅលើស្ថានភាពរបស់ស្ត្រីរស់នៅជនបទ នៅប្រទេសកម្ពុជា។ មានការតាក់តែងច្បាប់មួយដែលសំដៅដោះស្រាយបញ្ហានានា ដែលទាក់ទងទៅនឹងស្ត្រីនៅជនបទ ក៏ប៉ុន្តែច្បាប់នេះខ្វះទាំងភាពច្បាស់លាស់ ព្រមទាំងខ្វះការជំរុញឲ្យអនុវត្ត ដែលអាចឲ្យជឿទុកចិត្តបាន។

ចំពោះស្ត្រីជនជាតិដើមភាគតិច បញ្ហាធំបំផុតដែលពួកគាត់ត្រូវប្រឈម គឺការបង្ខំឲ្យជនជាតិដើមភាគតិចផ្លាស់ទីកន្លែងពីដីធ្លី និងដែនអាណាចក្ររបស់ពួកគាត់ ដែលនាំឲ្យមានការធ្លាក់ចុះនូវបរិស្ថានធម្មជាតិ និងធនធានធម្មជាតិរបស់ពួកគាត់ ដោយសារមានការរីករាលដាលយ៉ាងធំ នូវការឈ្លានពាន ក្រោមលេះធ្វើការអភិវឌ្ឍន៍។ ការបាត់បង់ទឹកដីការបញ្ជូនកងទ័ព និងការផ្លាស់ប្តូរពីទីកន្លែងដោយបង្ខំ ដែលអាចនាំឲ្យមានការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ភាពក្រីក្រ និងការបដិសេធក្នុងការផ្តល់នូវសេវាសង្គមវប្បធម៌ដែលមានលក្ខណសមរម្យនានា។

សម្រាប់ជនជាតិដើមភាគតិច ដីធ្លីគឺជាមូលដ្ឋានសំខាន់ចាំបាច់ និងជាមូលដ្ឋាននៃជំនឿសាសនាដែលផ្គត់ផ្គង់ម្ហូបអាហារ និងសុខភាព សុវត្ថិភាព និងការបន្តនូវប្រពៃណីវប្បធម៌របស់ពួកគាត់ ដែលនាំឲ្យបង្កើតនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលមានសារៈសំខាន់ ចំពោះការរស់រានបន្តទៀតរបស់ពួកគាត់។ នៅក្នុងសហគមន៍ជាច្រើនរបស់ជនជាតិដើមភាគតិច ស្ត្រីគឺជាអ្នកផលិតម្ហូបអាហារដ៏សំខាន់ អ្នកមានចំណេះដឹង អ្នកព្យាបាល អ្នកថែរក្សា និងជាអ្នកផ្ទេរវប្បធម៌។ អនុផលព្រៃឈើមិនត្រឹមតែជាប្រភពបង្កើតម្ហូបអាហារ ដល់ពួកគាត់ប៉ុណ្ណោះទេ ថែមទាំងជាប្រភពចំណូលដ៏សំខាន់សម្រាប់ស្ត្រីជនជាតិដើមភាគតិចផងដែរ។ ជនជាតិដើមភាគតិចធ្វើការ

ប្រមូលផលិត និងលក់ភោគផលទាំងនេះ ដោយមិនពឹងអាស្រ័យលើស្វាមីរបស់គាត់នោះទេ កត្តានេះបានផ្តល់នូវកម្រិតឯករាជ្យភាព ខាងផ្នែកសេដ្ឋកិច្ចដល់ពួកគាត់ ហើយដូច្នេះស្ត្រីជនជាតិដើមភាគតិចមានតួនាទីកាន់តែប្រសើរនិងមានឋានៈកាន់តែរឹងមាំនៅក្នុងសង្គម។ នៅពេលដែលការទទួលបានផលប្រយោជន៍ពីដីធ្លី សមុទ្រ និងព្រៃឈើមិនអនុញ្ញាតតទៅទៀត នោះធ្វើឲ្យស្ត្រីកាន់តែពឹងផ្អែកលើបុរស។ ដោយមានការបំផ្លិចបំផ្លាញបរិស្ថាន ជនជាតិដើមភាគតិចក៏នឹងអាចបាត់បង់នូវតួនាទីក្នុងការបង្រៀនអំពីប្រពៃណីរបស់ខ្លួន បាត់បង់លទ្ធភាពក្នុងការប្រើប្រាស់ និងរក្សាទុកនូវចំណេះដឹងប្រពៃណី ព្រមទាំងបាត់បង់លទ្ធភាព ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើបរិស្ថានរបស់ពួកគាត់។

គម្រោងជាច្រើន នៃការធ្វើសម្បទានដីធ្លីដ៏ធំល្វឹងល្វើយកំពុងត្រូវបានអនុវត្ត ក្នុងសហគមន៍ជនជាតិដើមភាគតិចនៅទូទាំងប្រទេសកម្ពុជា។ ចំការកៅស៊ូ ចំការកសិឧស្សាហកម្មដែលមានទំហំធំៗ និងដីសម្បទាននៅតំបន់ជីកយករ៉ែ ដែលស្ថិតក្នុងចំណោមគម្រោងបង្កការបំផ្លិចបំផ្លាញ កំពុងត្រូវបានអនុវត្ត។ គម្រោងទាំងនេះ បាននាំទៅរកការរំលោភបំពានជាលក្ខណៈប្រព័ន្ធទៅលើសិទ្ធិបុគ្គល និងសិទ្ធិសមូហភាពនៃសហគមន៍ដែលរងផលប៉ះពាល់ ដូចជា ការផ្លាស់ទៅនៅតំបន់ថ្មីទាំងបង្ខំ ការគំរាមកំហែង ការធ្វើទុក្ខបុកម្នេញ លើក្រុមជនជាតិដើមភាគតិចដែលចេញមកតវ៉ា ព្រមទាំងនាំទៅរកការបាត់បង់ជីវភាពរស់នៅ និងបញ្ហាផ្សេងទៀត។ ស្ត្រីជនជាតិដើមភាគតិច បានកំពុងប្រឹងប្រែងតស៊ូជាមួយសហគមន៍របស់ពួកគាត់ក្នុងការការពារដីធ្លី និងជីវភាពរស់នៅរបស់ពួកគាត់ពីគម្រោង ដែលបង្កការបំផ្លិចបំផ្លាញ ក៏ប៉ុន្តែពួកគាត់គេចមិនផុតពីការធ្វើទុក្ខបុកម្នេញ ការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវភេទ។


រូបថត លីកាដូ

# មាត្រា ១៥៖
# ភាពស្មើគ្នាចំពោះមុខច្បាប់ និងក្នុងបញ្ហារដ្ឋប្បវេណី



រូបថត លីកាដូ

មាត្រា១៥ នៃអនុសញ្ញា ស៊ី-ដវ តម្រូវឲ្យរដ្ឋភាគី (១) រដ្ឋភាគី ត្រូវផ្តល់ឲ្យស្ត្រីនូវសមភាពជាមួយបុរសនៅចំពោះមុខច្បាប់។ (២) រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រី ក្នុងបញ្ហារដ្ឋប្បវេណីនូវឋានៈនីត្យានុកូល ដូចគ្នានឹងបុរស និងមានឱកាសដូចគ្នា ដើម្បីប្រើប្រាស់ឋានៈនេះ។ (៣) រដ្ឋភាគីត្រូវផ្តល់ឲ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និង ការគ្រប់គ្រងទ្រព្យសម្បត្តិ និងត្រូវឲ្យមានការប្រព្រឹត្តមកលើស្ត្រី ដូចគ្នាក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការនិងសាលាជំរះក្តី។(៤)រដ្ឋភាគីព្រមព្រៀងគ្នាថា កិច្ចសន្យាទាំងអស់ និងលិខិតុបករណ៍ឯកជនដទៃទៀតគ្រប់ប្រភេទ ដែលមានអានុភាពនីត្យានុកូល សំដៅរឹតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រីត្រូវទុកជាមោឃៈ។ (៥) រដ្ឋភាគីត្រូវឲ្យបុរស និងស្ត្រីមានសិទ្ធិដូចគ្នាចំពោះ ច្បាប់ ដែលទាក់ទងដល់សិទ្ធិដើរហើររបស់បុគ្គល និងសេរីភាពជ្រើសរើសនិវេសនដ្ឋាន និងលំនៅដ្ឋាន។

រាជរដ្ឋាភិបាល បានលើកឡើងថា "រដ្ឋាភិបាលបានផ្តល់នូវសិទ្ធិស្មើគ្នាដល់ស្ត្រីលើគ្រប់ផ្នែកនៃជីវិតទាំងអស់" ហើយបានលើកឡើងពីមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ការរើសអើងរាល់គ្រប់ទម្រង់លើស្ត្រីភេទត្រូវបំបាត់ចោល។ ការធ្វើអាជីវ កម្មលើការងារ ស្ត្រីត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធ

## អនុសាសន៍៖

- ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារីត្រូវរួមសហការ ជាមួយអាជ្ញាធមូលដ្ឋាន ដើម្បីពង្រឹងនូវការឆ្លើយតបរបស់រដ្ឋាភិបាល និងយន្តការផ្នែកច្បាប់នានា សំដៅដោះស្រាយអំពើហិង្សាលើយេនឌ័រ រួមមាន អំពើរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរ ។ល។
- រាជរដ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធនានា គួរធ្វើការផ្សព្វផ្សាយព័ត៌មាន អំពីសេវាកម្មផ្សេងៗដែលជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ អាចប្រើប្រាស់បាន។
- រាជរដ្ឋាភិបាល គួរបង្កើតបទប្បញ្ញត្តិ ដែលអនុញ្ញាតឲ្យស្ត្រីអាចធ្វើការសម្រេចចិត្ត ដោយឯកតោភាគី ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់ឆ្លងកាត់ការផ្សះផ្សាជាមុន។

មួយ។” រាជរដ្ឋាភិបាលកម្ពុជា បានធ្វើសេចក្តីសន្និដ្ឋានថា ស្ត្រីពិតជាទទួលបានសិទ្ធិស្មើនឹងបុរស ដូចមានចែងក្នុងច្បាប់ ហើយថា ស្ត្រីអាចប្រើប្រាស់នីតិវិធីប្តឹងសារទុក្ខ នៅពេលស្ត្រីមានជំនឿថាសិទ្ធិរបស់ខ្លួនត្រូវបានគេរំលោភបំពាន ដែលសិទ្ធិនេះ ត្រូវបានការពារដោយមាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ។[៦២] រាជរដ្ឋាភិបាលក៏បានលើកឡើងពីមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា “ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។”


រូបថត លីកាដូ

ផ្អែកតាមការសន្និដ្ឋានរបស់រដ្ឋាភិបាលតែម្នាក់ឯងបានបង្ហាញថាមានអាជ្ញាធរស្របច្បាប់គ្រប់គ្រាន់ដើម្បីផ្តល់ការការពារ ដោយស្មើភាព និងមិនឲ្យមានការរើសអើងលើស្ត្រីនៅចំពោះមុខច្បាប់ ក៏ប៉ុន្តែមិនខុសពីផ្នែកជា ច្រើនផ្សេងទៀតទេ អត្ថិភាពនៃបទប្បញ្ញត្តិ និង បទបញ្ជា ដែលលើកស្ទួយសមភាពនោះមិនមានន័យថា សមភាពត្រូវបានផ្តល់ទៅឲ្យឬក៏ធានា ដល់ស្ត្រីនូវសមភាពពិតប្រាកដនោះទេ។ ឧទាហរណ៍ នៅក្នុងការអនុវត្តជាក់ស្តែង ការធ្វើសាក្សីកម្មរប ស់ស្ត្រីនៅក្នុងតុលាការ ជារឿយៗ មិនមានភាពស្មើគ្នានឹងការធ្វើសាក្សីកម្មរបស់បុរសនោះទេ។ ស្ត្រី ដែលជាជនរង គ្រោះពីអំពើហិង្សាក្នុងគ្រួសារ ជារឿយៗបានបង្ហាញភាពខ្វះជំនឿទុកចិត្តលើមន្ត្រីនគរបាល និងតុលាការ ដែលទទួលរ៉ាប់រងក្នុងការអនុវត្តច្បាប់ទាំងនេះ។ ស្ត្រីជាជនរងគ្រោះ ត្រូវមានឯកសារជាច្រើនពាក់ព័ន្ធនឹងការទទួលរងរបួស ដើម្បីបង្ហាញជាភស្តុតាងពីករណីបណ្តឹងរបស់ខ្លួន។ ក្នុងករណីជាច្រើន ជនរងគ្រោះនឹងមិនស្វែងរកយុត្តិធម៌ទេដោយសារពួកគាត់ខ្វះជំនឿលើប្រព័ន្ធតុលាការ ឬដោយសារតែមានការចំណាយខ្ពស់ លើនីតិវិធីបញ្ជូនរឿងក្តីទៅតុលាការ។[៦៣] អារម្មណ៍ដែលមានភាពមិន ប្រាកដប្រជាទាំងនេះមិនមែនគ្មានមូលហេតុមកសំអាងនោះទេ មូលហេតុនោះ គឺថាស្ត្រីជាជនរងគ្រោះ ទទួលរងបញ្ហាប្រឈមជាច្រើនផ្សេងគ្នានៅក្នុងតុលាការ។ នៅក្នុងករណីដែលជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ឬអំពើបៀតបៀនផ្លូវភេទមិនត្រូវបានបញ្ជូនទៅតុលាការភ្លាមៗនោះទេ បន្ទាប់ពីករណីនេះបានកើតឡើង។ ជនរងគ្រោះមិនអាច

[៦២] មាត្រា ៣៩ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជូសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិក នៃអង្គការទាំងនេះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជូសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

[៦៣] បញ្ហាសិទ្ធិស្ត្រី សិទ្ធិកុមារ និង សិទ្ធិកម្មករចំណាកស្រុក នៅកម្ពុជា. Rep.Np.: n.p ២០១២. បញ្ហាសិទ្ធិស្ត្រី សិទ្ធិកុមារ និង សិទ្ធិកម្មករចំណាកស្រុក នៅកម្ពុជា. សមាគមសិទ្ធិមនុស្ស និង អភិវឌ្ឍន៍ កម្ពុជា អាដហុក ២០១២. Web. ០៩ សីហា ២០១៣.

ទទួលបានលិខិតកោសល្យវិច្ច័យ ដែលធ្វើការវាយតម្លៃលើការរងរបួសរបស់ខ្លួនបានទេ។ ការដែលខ្វះសមត្ថភាពក្នុងការប្រមូលភស្តុតាង ដែលចាំបាច់តាមកោសល្យវិច្ច័យរបស់ជនរងគ្រោះ នៃអំពើរំលោភសេពសន្ថវៈ ឬដោយសារការរើសអើងពីបុគ្គលិកនៅមន្ទីរពេទ្យបង្អែក ប្រការនេះ ក៏ធ្វើឲ្យប៉ះពាល់ដល់ដំណើរការផ្លូវច្បាប់ផងដែរ។ បន្ទាប់មកតុលាការនឹងសន្មត់ថា គ្មានភស្តុតាងណាមួយបង្ហាញពីអំពើហិង្សា ដូច្នេះត្រូវចាត់ទុកថា គ្មានការរំលោភសេពសន្ថវៈនោះទេ។ ប្រសិនបើគ្មានសញ្ញាណាមួយបង្ហាញពីអំពើហិង្សា នោះតុលាការនឹងបង្វែរអំពើរំលោភសេពសន្ថវៈ ទៅជាអំពើបៀតបៀនផ្លូវភេទ ហើយធ្វើការផ្តន្ទាសទោសដល់ជនល្មើសត្រឹមកម្រិតទោសស្រាលបំផុត។ នៅក្នុងករណី ដែលមិនមានរបួសលើរាងកាយណាមួយ បង្ហាញឲ្យឃើញជាក់ស្តែងនោះតុលាការនឹងសម្មត់ថាជនរងគ្រោះស្ម័គ្រចិត្តដោយខ្លួនឯង បើទោះជាការពិតនោះ គឺថាជនរងគ្រោះជាច្រើនមិនហ៊ានព្យាយាមរើបម្រះ ពីព្រោះពួកគាត់ ត្រូវបានជនល្មើសគំរាមកំហែងសម្លាប់ប្រសិនបើព្យាយាមរើបម្រះនោះ។

ចំពោះ បញ្ហារំលាយចំណងអាពាហ៍ពិពាហ៍ ស្ត្រីត្រូវឆ្លងកាត់ដំណាក់កាលនៃការ ផ្សះផ្សារ ២ ទៅ ៣ ដង សិននៅចំពោះមុខចៅក្រម។ ជារឿយៗតុលាការតែងតែដាក់សម្ពាធឲ្យស្ត្រី ត្រឡប់ទៅរកស្វាមីរបស់គាត់វិញ ដោយណែនាំឲ្យស្ត្រីជាម្ចាស់បណ្តឹងមានភាពអត់ធ្មត់ និងមានចិត្តប្រណីអនុគ្រោះ។ ករណីជាច្រើននៃអំពើហិង្សាក្នុងគ្រួសារ តុលាការតែងតែសន្មត់ថា ស្ត្រីជាអ្នកខុស ព្រោះថាជាអ្នកផ្តើមធ្វើឲ្យស្វាមីមានកំហឹង។ ការយល់ឃើញពីបញ្ហាប្រឈមនឹងភាពស្មុគស្មាញនេះហើយ ធ្វើឲ្យស្ត្រីមិនដាក់ពាក្យប្តឹងលែងលះនោះទេ។ លើសពីនេះ យោងតាមក្រមរដ្ឋប្បវេណីនៅជំពូក ៣ ក្នុងមាត្រា ៩៥០ បានចែងថា ស្ត្រី ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ចំណែកឯបុរសវិញ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ថ្មីបានភ្លាមបន្ទាប់ពីអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ប្រការនេះ គឺជាការរើសអើងលើស្ត្រី ដោយសារបញ្ញត្តិនេះ ដកនូវសិទ្ធិស្មើភាពគ្នារបស់ស្ត្រីចំពោះមុខច្បាប់ ហើយបែរជាផ្តល់ផលប្រយោជន៍ឲ្យបុរសដែលស្ត្រីមិនមានសិទ្ធិទទួលបាននោះឡើយ។

# មាត្រា ១៦៖ ភាពស្មើគ្នាក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ



មាត្រា១៦ នៃអនុសញ្ញា ស៊ី-ដរ តម្រូវឲ្យរដ្ឋភាគី "ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់រាល់ការរើសអើងលើស្ត្រី ក្នុងគ្រប់បញ្ហាទាំងអស់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ។" អនុសញ្ញា ស៊ី-ដរ តម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រីក្នុងអាពាហ៍ពិពាហ៍ ការលែងលះ កម្មសិទ្ធិ និងជីវិតគ្រួសារ។

មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញបានចែងថា ការរើសអើងក្នុងគ្រប់វិស័យលើស្ត្រីត្រូវលុបបំបាត់ចោល ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ ការសិក្សាស្រាវជ្រាវរបស់យើងបានបង្ហាញថា ការអនុវត្តជាក់ស្តែង គឺមិនដូចអ្វីដែលមានចែងនៅក្នុងមាត្រានេះឡើយ។ ច្បាប់កម្ពុជាស្តីអំពីអាពាហ៍ពិពាហ៍ និងគ្រួសារ មានខចែងជាច្រើនដែលប្រកបដោយលក្ខណៈរើសអើងដែលចាត់ទុកស្ត្រីមិនមានភាពស្មើគ្នានឹងបុរស។ នៅកម្ពុជា ស្ត្រីមិនមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នានឹងបុរសនោះទេ។ ថ្វីត្បិតតែមាត្រា ៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានចែងថា ស្ត្រីត្រូវបានអនុញ្ញាតឲ្យទទួលបានទ្រព្យសម្បត្តិនៅបន្ទាប់ពីការលែងលះ ក៏ប៉ុន្តែបញ្ហាដែលកើតមានជាធម្មតានោះ គឺថាកម្មសិទ្ធិលើដីធ្លីរួមគ្នា នៅពេលខ្លះឈ្មោះស្វាមីត្រូវបានបញ្ចូលក្នុងប័ណ្ណកម្មសិទ្ធិដីធ្លី ដោយមិនមានការដឹងលឺពីប្រពន្ធ ហើយបុរសជាប្តីអះអាងថា ខ្លួនមានកម្មសិទ្ធិលើដីធ្លីតាំងពីដំបូងក្រោយពីការរំលាយចំណងអាពាហ៍ពិពាហ៍។[៦៤] យោងតាមច្បាប់ នេះ ស្ត្រី

## អនុសាសន៍៖

- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី ដើម្បីជំរុញឲ្យមានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ និងកាត់បន្ថយចំនួនជនរងគ្រោះ ដែលត្រូវបង្ខំចិត្តរស់ នៅក្នុងទំនាក់ទំនងពេញទៅ ដោយការបៀតបៀន ជាពិសេសផ្តល់ការបណ្តុះបណ្តាលនេះ ដល់ស្ត្រីដែលត្រូវទទួលបន្ទុកចិញ្ចឹមគ្រួសារ តែម្នាក់ឯង ដោយសារស្វាមីជាប់ពន្ធនាគារ ពីបទប្រើអំពើហិង្សាក្នុងគ្រួសារ។
- ធ្វើការកាត់បន្ថយ ឬមិនទាមទារថ្លៃឈ្នួលលើសេវាផ្លូវច្បាប់ពីជនទាំងឡាយណា ដែលមានបំណងដាក់ពាក្យសុំប្តឹងលែងលះ ដោយបញ្ហាអំពើហិង្សាក្នុងគ្រួសារ។

[៦៤] កម្ពុជា: សិទ្ធិលើទ្រព្យសម្បត្តិ និងការគ្រប់គ្រងលើធនធាន ។ USAID

និងបុរសមានកាតព្វកិច្ចស្មើគ្នាក្នុងការថែរក្សាកូន។ នៅក្នុងករណីដែលបុរសចាកចេញពីស្ត្រីជាប្រពន្ធទៅរកស្ត្រីមួយ ផ្សេងទៀត ឬក៏ព្រោះបុរសជាស្វាមីត្រូវបញ្ជូនទៅពន្ធនាគារ ស្ត្រីជាភរិយាតែងតែទទួលបន្ទុកចិញ្ចឹមបីបាច់កូន ដោយមិនមានជំនួយផ្នែកហិរញ្ញវត្ថុនោះទេ។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោកបានបង្ហាញថា នៅប្រទេសកម្ពុជា មានគ្រួសារចំនួន ៣០% ដែលមានស្ត្រីជាអ្នកដឹកនាំគ្រួសារ។

ស្ត្រីមានឱកាសតិចតួចក្នុងការជ្រើសរើសគូស្រករ ដោយសារអាពាហ៍ពិពាហ៍ត្រូវបានរៀបចំទុកដាក់ពីឪពុកម្តាយ និងស្ត្រីក្លាយជាកូនក្រមុំទាំងនៅវ័យកុមារ នៅតែជាបញ្ហាក្នុងប្រទេសកម្ពុជានៅឡើយ។ នៅក្នុងករណីជាច្រើន ប្រសិនបើក្មេងស្រីមានអាយុក្មេងខ្លាំង នោះឪពុកម្តាយនិងបុរសជាស្វាមីរបស់ក្មេងស្រីធ្វើការសូកប៉ាន់អាជ្ញាធរក្នុងភូមិ ដើម្បីឲ្យក្លែងបន្លំអាយុកំណើតរបស់ក្មេងស្រីនោះ។ នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍នឹងគ្រួសារបានចែងថា អាចរៀបអាពាហ៍ពិពាហ៍បានបុរសមានអាយុចាប់ពី ២០ ឆ្នាំឡើង និងនារីមានអាយុចាប់ពី ១៨ ឆ្នាំឡើង។

កុមារីជាច្រើន ដែលត្រូវបានគេរំលោភសេពសន្ថវៈជួបបញ្ហាលំបាកក្នុងការរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា ដោយពួកគេទទួលរងការប្រមាថមាក់ងាយ។ មានពាក្យស្លោកខ្មែរពីបុរាណមួយបានលើកឡើងថា "បុរសមានតម្លៃដូចមាស ហើយស្ត្រីវិញមានតម្លៃដូចក្រណាត់ពណ៌ស។" ពាក្យស្លោកនេះមានន័យថា បើទោះជាមាសប្រឡាក់នឹងធូលីក៏នៅតែជាមាស ប៉ុន្តែចំណែកឯក្រណាត់ពណ៌សវិញ នៅពេលដែលមានស្នាមប្រឡាក់ហើយ គឺស្នាមប្រឡាក់នោះនឹងស្ថិតនៅជារៀងរហូត។ លើសពីនេះទៅទៀត នៅពេលដែលស្ត្រីចូលបម្រើការងារក្នុងឧស្សាហកម្មផ្តល់សេវាកំសាន្ត ពួកគាត់ជារឿយៗ ត្រូវបានក្រុមគ្រួសារ និងសហគមន៍ទុកពួកគាត់ឲ្យនៅឯកោ។ ក្មេងស្រីម្នាក់នៅក្នុងវីដេអូ ឯកសារមួយមានចំណងជើងថា "ពាក់កណ្តាលមេឃ" បានរៀបរាប់ថា ក្រោយពីបានចូលបម្រើការងារនៅក្នុងបនពេស្យាមួយកន្លែង ឪពុកម្តាយរបស់នាងចាត់ទុកនាងជាមនុស្សអកុសល ហើយមិនស្វាគមន៍នាងឲ្យត្រឡប់មកផ្ទះវិញទេ សូម្បីតែការពិតនោះ គឺជាកំហុសរបស់ឪពុកម្តាយរបស់នាង ដែលជាអ្នកលក់នាងឲ្យទៅផ្ទះបននោះក៏ដោយ។

នៅក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា "ប្តី ឬប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថាខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន។" នៅក្នុងការអនុវត្តជាក់ស្តែងចំពោះស្ត្រីមានការលំបាកកាន់តែច្រើនឡើង ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។ ស្ត្រីត្រូវប្រឈមនឹងការចំណាយខ្ពស់លើការដាក់ពាក្យសុំប្តឹងលែងលះ។ ជារឿយៗ ស្ត្រីត្រូវធ្វើដំណើរឆ្ងាយដើម្បីមក

- យកករណីអំពើហិង្សា ក្នុងគ្រួសារមកពិភាក្សាក្នុងសាលារៀន និងធ្វើការអប់រំសិស្សានុសិស្សអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ដែលមានចែងនៅក្នុងច្បាប់នេះ។ លើកទឹកចិត្តដល់ជនរងគ្រោះ ឲ្យរាយការណ៍ពីករណីរបស់ខ្លួន និងទប់ស្កាត់មិនឲ្យមានជនល្មើសប្រព្រឹត្តអំពើហិង្សានេះតទៅទៀត។
- រដ្ឋាភិបាល គួរលើកកំពស់ និងពង្រឹងការអនុវត្តក្រមសីលធម៌មន្ត្រីនគរបាល តាមរយៈការបណ្តុះបណ្តាល។ រដ្ឋាភិបាលក៏គួរធ្វើការកែលំអរផងដែរ លើយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់មន្ត្រីនគរបាលកម្ពុជាដើម្បីបង្កើនឲ្យមានការទទួលខុសត្រូវ។
- គួរបង្កើនកម្រិត ទោសទណ្ឌបន្ថែមទៀតលើអ្នករំលោភច្បាប់ស្តីពីអំពើហិង្សា ក្នុងគ្រួសារដោយសង្ឃឹមថា ការបន្ថែមទោសឲ្យធ្ងន់ជាងនេះ នឹងធ្វើឲ្យអត្រានៃអំពើហិង្សា ក្នុងគ្រួសារថយចុះ ហើយនឹងបង្កើនសន្តិសុខនៅក្នុងផ្ទះ ដល់ស្ត្រីបន្ថែមទៀត។
- បើកវគ្គបណ្តុះបណ្តាល សម្រាប់ថ្នាក់ដឹកនាំ ក្នុងជួររដ្ឋាភិបាល និងអ្នកអនុវត្តច្បាប់ ដើម្បីឲ្យពួកគាត់យល់ច្បាស់ពីសារៈសំខាន់ក្នុងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ និងសង្កត់ធ្ងន់លើបញ្ហាជាក់លាក់នៃអំពើហិង្សា ក្នុងគ្រួសារដែលជាបញ្ហាមួយ ត្រូវតែចាត់វិធានការឲ្យបានហ្មត់ចត់។ លើកកម្ពស់ការយល់ដឹងដល់ថ្នាក់ដឹកនាំអំពីសារៈសំខាន់ នៃការការពារសិទ្ធិរបស់ស្ត្រី។

ដាក់ពាក្យបណ្ដឹងសុំលែងលះ។ នៅតាមតំបន់ជនបទនានា ស្ត្រីជាច្រើនបានរៀបអាពាហ៍ពិពាហ៍ដោយមិនមានលិខិតអាពាហ៍ពិពាហ៍ស្របច្បាប់ (អេតាស៊ីវិល) នោះធ្វើឲ្យការលែងលះមិនអាចទៅរួចនោះទេ។ ប្រការនេះ ធ្វើឲ្យស្ត្រីដែលកំពុងប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារមានជម្រើសតិចតួចណាស់ក្នុងការគេចចេញពីអំពើហិង្សានោះ។ ជារឿយៗ ស្ត្រីត្រូវបង្ខំចិត្តបន្តរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍បែបនេះ ដោយសារមូលហេតុផ្លូវច្បាប់ ឬកត្តាសេដ្ឋកិច្ច។ ជារឿយៗ ស្ត្រីមិនមានលទ្ធភាពក្នុងការចិញ្ចឹមខ្លួនឯង និងកូនរបស់គាត់ ប្រសិនបើគាត់ត្រូវដាក់ពាក្យបណ្ដឹងសុំលែងលះ ម្យ៉ាងវិញទៀតស្រីក៏ខ្វះនូវជំនាញផ្សេងៗដើម្បីរកប្រាក់ចិញ្ចឹមគ្រួសាររបស់គាត់ ដោយឯករាជ្យដោយមិនចាំបាច់ពឹងអាស្រ័យលើស្វាមីរបស់ខ្លួន។

បញ្ហាអំពើហិង្សា ក្នុងគ្រួសារជាច្រើននៅតាមទីជនបទ កម្រត្រូវបានគេរាយការណ៍ណាស់។ ករណីដែលមិនរាយការណ៍ពីអំពើ ហិង្សានេះក៏ដោយសារមូលហេតុមួយចំនួន ហើយជាពិសេសនោះ ករណីអំពើហិង្សា កើតមានឡើងលើស្ត្រីរស់នៅក្នុងភូមិតូចៗ។ ច្បាប់ស្រីបានប្រដៅថា ស្ត្រីគួរតែរក្សាទុករឿងរ៉ាវរបស់ខ្លួននៅក្នុងផ្ទះ។ នេះគឺជាសម្ពាធក្នុងការរក្សា "មុខមាត់" ដើម្បីជៀសវាងមិនឲ្យមានភាពអាម៉ាស់នៅក្នុងសហគមន៍។ ស្ត្រីមានការភ្លាចរអាមិនហ៊ាននិយាយប្រាប់គេនោះទេ។ ករណីបែបនេះ ជារឿយៗ ច្រើនកើតមាននៅ ក្នុងគ្រួសារដែលមានជីវភាពកាន់តែក្រីក្រ។ ក៏ប៉ុន្តែករណីបែបនេះក៏កើតមានច្រើនដែលទៅលើជនរងគ្រោះ ដែលមានទ្រព្យសម្បត្តិ និងមានមុខមាត់ផងដែរ។ ពួកគេខ្លាចមិនហ៊ាននិយាយប្រាប់គេនោះទេ ព្រោះនឹងធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ខ្លួននៅក្នុងសង្គម។[៦៥] ទោះបីជានៅពេលស្ត្រីរាយការណ៍ អំពីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏អាជ្ញាធរតែងតែឈរនៅខាងភាគីស្វាមី និងងាយស្រួលទទួលយកប្រាក់កម្រៃ ដើម្បីបញ្ចប់រឿងក្ដី។ ស្ត្រីជាច្រើនបាននិយាយថា ពួកគាត់មានអារម្មណ៍ខ្មាស់អៀននៅពេលរាយការណ៍ អំពីអំពើហិង្សាក្នុងគ្រួសារទៅអាជ្ញាធរជាបុរស ហើយថាបើអាជ្ញាធរជាស្ត្រីវិញ ពួកគាត់នឹងព្យាយាមច្រើនបន្ថែមទៀតក្នុងការស្វែងរកជំនួយ។ ស្ទើរតែគ្រប់អាជ្ញាធរទាំងអស់និយាយថា ពួកគាត់មិនមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារទេ ព្រោះពួកគាត់មិនទាន់បានទទួលការបណ្ដុះបណ្ដាលឲ្យបានត្រឹមត្រូវនៅឡើយ។[៦៦] តាមអ្វីដែលយើងបានដឹង គឺថាអំពើហិង្សាលើផ្នែកសេដ្ឋកិច្ច និងផ្លូវសតិអារម្មណ៍ ឬផ្លូវចិត្ត ក៏ជាបញ្ហាហើយមិនត្រូវបានលើកឡើងនៅក្នុងច្បាប់កម្ពុជានោះទេ។

នៅក្នុងករណីសិក្សាមួយមាន ស្ត្រីម្នាក់បានតេទូរស័ព្ទពីប្រទេសកូរ៉េទៅប្រធានអង្គការ លីកាដូ។[៦៧] គាត់មិនចង់ប្រាប់ពីអត្តសញ្ញាណរបស់ខ្លួនទេ ប៉ុន្តែគាត់ចង់ប្រាប់រឿងរ៉ាវរបស់គាត់ ឲ្យគេឯងបានដឹង ដើម្បីទុកជាមេរៀនដល់ស្ត្រីវ័យក្មេងនៅកម្ពុជា។ ប៉ុន្មានឆ្នាំកន្លងទៅនេះ មានភ្នាក់ងារមួយបានទាក់ទងមកគាត់ និងបានរៀបការជាមួយបុរសជនជាតិកូរ៉េម្នាក់ ដែលបុរសនោះបានសន្យាថានឹងផ្ដល់ជីវិតថ្លៃថ្លានៅបរទេស។ ក្រុមគ្រួសាររបស់គាត់មានភាពរីករាយយ៉ាងខ្លាំង និងបានប្រញាប់រៀបចំអាពាហ៍ពិពាហ៍យ៉ាងឆាប់រហ័ស។ ការរៀបអាពាហ៍ពិពាហ៍នេះ ធ្វើឡើងតាមលក្ខណៈប្រពៃណីកម្ពុជា ប៉ុន្តែមិនមានតម្លៃផ្លូវច្បាប់នោះទេ។ គូស្រករទើបតែរៀបការរួចនេះ បានចេញដំណើរទៅប្រទេសកូរ៉េ។ មិនយូរប៉ុន្មាន ស្ត្រីជាជនរងគ្រោះបានដឹងខ្លួនថា រូបគាត់រៀបការគ្រាន់តែដើម្បីធ្វើជាអ្នកបម្រើ ដែលមិនទទួលបានថ្លៃឈ្នួល ក្នុងក្រុមគ្រួសាររបស់ប្ដីគាត់តែប៉ុណ្ណោះ ដោយធ្វើការតាំងពីភ្លឺស្រាងៗរហូតដល់យប់ជ្រៅ ដោយគ្រាន់តែទទួលបានអាហារមួយចំអែក ដើម្បីរស់រានប៉ុណ្ណោះ។ មិនបានយូរប៉ុន្មានផង ប្ដីរបស់គាត់បានផ្ដល់កិច្ចការដ៏គួរឲ្យធន់ទ្រាន់ឲ្យគាត់ធ្វើ។ គាត់ត្រូវបានបង្ខំឲ្យរួមភេទជាមួយសមាជិកបុរសៗនៅក្នុងក្រុមគ្រួសាររបស់ប្ដីគាត់ ហើយនៅពេលខ្លះ សូម្បីតែជាមួយមិត្តភ័ក្ររបស់ប្ដី។ គាត់

[៦៥] របាយការណ៍សិទ្ធិរបស់ស្ត្រី, សមាគមសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍កម្ពុជា ២០១២។
[៦៦] របាយការណ៍ស្ដីពីការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រីក្រៅតុលាការ។
[៦៧] វេជ្ជបណ្ឌិត ពុង ឈីវ គេក ជាប្រធានអង្គការលីកាដូ និងជាប្រធានអ៊ិន ជី អូ ស៊ី-ដវ

សង្ស័យថា ខ្លួនគាត់ត្រូវបានគេលក់ដូរទៅអ្នកផ្សេងៗ ទៀតនៅអំឡុងពេលបង្ខំឲ្យរួមភេទទាំងនេះ។ ដោយសារតែគាត់មិនបានរៀបការស្របច្បាប់ ដូច្នេះគាត់មិនទទួលបានជំនួយផ្លូវច្បាប់ទេ។ គាត់មិនបានដឹងសូម្បីតែឋានៈផ្លូវច្បាប់របស់ខ្លួននៅប្រទេសកូរ៉េនោះផងដែរ។ បន្ទាប់ពីការរស់នៅក្នុងភាពភ័យខ្លាចអស់ជាច្រើនខែមក គាត់ក៏មានឱកាសរត់គេច ហើយបានរត់ទៅលាក់ខ្លួន។ ក្រោយមកទៀតមានអង្គការមិនមែនរដ្ឋាភិបាលកូរ៉េ ដែលធ្វើការដើម្បីសិទ្ធិស្ត្រីបានជួយរូបគាត់។ បច្ចុប្បន្ននេះ គាត់កំពុងបម្រើការងារឲ្យអង្គការនោះ។ គាត់មិនមានបំណងវិលត្រឡប់មកប្រទេសកម្ពុជាវិញទេ។ ប្រសិនបើគាត់ត្រូវត្រឡប់មកវិញមែន ចំពោះខ្លួនគាត់ និងចំពោះក្រុមគ្រួសារគឺជាការបាត់បង់មុខមាត់ទាំងស្រុង មិនតែប៉ុណ្ណោះភ្នាក់ងារដែលរៀបចំអាពាហ៍ពិពាហ៍ ឲ្យគាត់នៅកម្ពុជាអាចនឹងរកគាត់ឃើញ រួចបញ្ជូនគាត់ត្រឡប់ទៅឲ្យប្តីរបស់គាត់វិញ។ ការក្រើនរំលឹករបស់គាត់ដល់ស្ត្រីកម្ពុជា ដែលមានចំណាប់អារម្មណ៍រៀបការជាមួយជនជាតិបរទេសនោះ គឺថាត្រូវរៀបការដោយមានតម្លៃផ្លូវច្បាប់នៅកម្ពុជា ហើយត្រូវធ្វើឲ្យការរៀបការរបស់ខ្លួនទៅជាផ្លូវការឲ្យបានកាន់តែឆាប់តាម ដែលអាចធ្វើទៅបាននៅក្នុងប្រទេសថ្មីដែលខ្លួនរស់នៅនោះ។ មានតែធ្វើដូច្នេះទេ ទើបជាវិធីដែលធ្វើឲ្យស្ត្រីកម្ពុជាមានសិទ្ធិស្វែងរកនូវកិច្ចការពារផ្លូវច្បាប់មួយចំនួននៅបរទេសបាន។

នៅក្នុងករណីមួយទៀតរាយការណ៍ ដោយអង្គការ លីកាដូ បានឲ្យដឹងថា នៅក្នុងឆ្នាំ២០០៦ ស្ត្រីម្នាក់អាយុ៣៩ ឆ្នាំ មានកូនចំនួន ៤ នាក់។ ស្ត្រីរូបនេះបានកាប់សម្លាប់ប្តីរបស់គាត់ដោយកាំបិតតាំងតោ។ អំពើហិង្សាក្នុងគ្រួសារកើតឡើងជាញឹកញាប់ និងអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងគ្រួសារមួយនេះ។ ប្រជាពលរដ្ឋពេញទូទាំងភូមិបានដឹងលឺពីការប្រព្រឹត្តហិង្សារបស់បុរសជាប្តីរូបនេះ។ នៅពេលដែលបុរសនេះស្រវឹងស្រា គាត់តែងតែវាយធ្វើបាបប្រពន្ធ និងកូន។ មានថ្ងៃមួយ បុរសនេះបានមកដល់ផ្ទះទាំងខ្លួនស្រវឹង និងមានកាន់កាំបិតតាំងតោមកជាមួយផងដោយថែមទាំងបានគំរាមសម្លាប់សមាជិកគ្រួសាររបស់ខ្លួនទាំងអស់។ នៅក្នុងការវាយតប់គ្នា ដើម្បីការពារខ្លួន ស្ត្រីជាប្រពន្ធបានសម្លាប់ប្តីរបស់នាង។ សាក្សីម្នាក់ដែលបានស្គាល់ក្រុមគ្រួសារនេះ បានអះអាងថាអាជ្ញាធរមូលដ្ឋានបានឲ្យបុរសនេះ ចុះហត្ថលេខាលើលិខិតសន្យាជាច្រើនដង ដើម្បីឈប់ប្រើអំពើហិង្សា ក៏ប៉ុន្តែបុរសនេះមិនត្រូវបានស្តីបន្ទោសជាផ្លូវការនោះទេ។ នៅក្នុងច្បាប់កម្ពុជាគ្មានបទប្បញ្ញត្តិណាដែលចែងអំពីការការពារខ្លួនឡើយ។ នៅក្នុងករណីនេះ តុលាការបានសម្រេចកាត់ទោសស្ត្រីជាប្រពន្ធរូបនេះឲ្យជាប់ពន្ធនាគាររយៈពេល ១០ ឆ្នាំ ចំពោះបទឧក្រិដ្ឋរបស់គាត់។មានករណីជាច្រើនដែលស្ត្រីត្រូវជាប់ឃុំឃាំង ដោយសារតែសម្លាប់ប្តីរបស់ខ្លួនដែលអំពើសម្លាប់នេះ គឺបណ្តាលមកពីអំពើហិង្សាក្នុងគ្រួសារ។

ជារឿយៗ ជនល្មើសប្រព្រឹត្តបទល្មើសដោយពុំបានទទួលផលវិបាកពីទង្វើរបស់ខ្លួនឡើយ ដោយសារពួកគេប្រើអំណាច និងសំណូកដើម្បីគេចពីការផ្តន្ទាទោស។ ជារឿយៗ នៅពេលដែលបុរសជាប្តីជាប់ពន្ធនាគារដោយសារការប្រើអំពើហិង្សាក្នុងគ្រួសារ ស្ត្រីជាប្រពន្ធមិនអាចលែងលះបុរសជាប្តី ដែលប្រើអំពើហិង្សានេះបានទេ ដោយសារកត្តាសេដ្ឋកិច្ច។

អង្គការមិនមែនរដ្ឋាភិបាលនានា បានផ្តល់ជម្រកស្នាក់នៅសមរម្យដល់ស្ត្រី ដែលរងការវាយដំធ្ងន់ធ្ងរ ព្រមទាំងបានផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពួកគាត់ផងដែរ។ ចំណែករដ្ឋាភិបាលវិញក៏មានមជ្ឈមណ្ឌលច្រើនដែរ ដែលមានឈ្មោះថា "មជ្ឈមណ្ឌលស្តារសម្បទាឡើងវិញ" ដែលមានលក្ខណៈដូចជាពន្ធនាគារច្រើនជាង ដោយមជ្ឈមណ្ឌលទាំងអស់នោះមិនសូវមានធនធានថវិកាដើម្បីជួយឧបត្ថម្ភដល់ស្ត្រី ដូចជា ម្ហូបអាហារ ឬការថែទាំ និងថែមទាំងមិនមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

ដើម្បីកាត់ទោសបុរសម្នាក់ដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារបានចាំបាច់ត្រូវមានឯកសារ ដែលបង្ហាញពីភស្តុតាងនៃអំពើហិង្សាលើស្ត្រី។ ជារឿយៗទាមទារឲ្យមានសាក្សីដើម្បីផ្តល់ភស្តុតាង ក៏ដូចជាភស្តុតាងជារូបភាពបង្ហាញពីរបួសលើរាង្គកាយ ដែលបង្កដោយចុងចោទ។ ជារឿយៗ បញ្ហានេះរារាំងស្ត្រីពីការស្វែងរកជំនួយដែលពួកគាត់ត្រូវការ។ ជនរង

គ្រោះតែងតែមិនមានលទ្ធភាព ក្នុងការចងក្រងឯកសារបង្ហាញពីរបួសស្នាមរបស់ខ្លួន។ គេបានដឹងលឺថា ចៅក្រមទទួលសំណូកជាលុយកាក់ពីចុងចោទ ដើម្បីជាថ្នូរនឹងការដាក់ទោសស្រាលៗ។ ការដាក់ទោសទណ្ឌលើអំពើហិង្សាក្នុងគ្រួសារអាចមានចាប់ពី ១ឆ្នាំទៅ ៥ឆ្នាំ ដោយអាស្រ័យលើសភាពធ្ងន់ធ្ងរនៃអំពើហិង្សានោះ។ ក៏ប៉ុន្តែការដាក់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៥ឆ្នាំ គឺជាប្រភេទនៃការដាក់ទោសកម្រិតអតិបរមា បើទោះជាករណីខ្លះមានសភាពធ្ងន់ធ្ងរជាងការដាក់ទោសកម្រិតអតិបរមានេះក៏ដោយ។ អង្គការនានា ដែលជួយស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារភាគច្រើនអង្គការទាំងនោះមាន នៅតាមទីក្រុងធំៗមួយចំនួនតែប៉ុណ្ណោះ ដែលប្រការនេះធ្វើឲ្យស្ត្រីនៅតាមជនបទមានជម្រើសតិចតួច នៅពេលដែលទទួលរងអំពើហិង្សាក្នុងគ្រួសារ។

# អនុសាសន៍ទូទៅ ១៩: អំពើហិង្សាលើស្ត្រី



រូបថត លីកាដូ

មាត្រា២ នៃអនុសញ្ញា ស៊ី-ដវ បានកំណត់និយមន័យនៃអំពើហិង្សាលើយេនឌ័រថា "អំពើហិង្សាដែលសម្ដែងចេញដោយផ្ទាល់លើស្ត្រី ពីព្រោះជនរងគ្រោះជាស្ត្រី ឬដែលអំពើហិង្សានោះប៉ះពាល់ដល់ស្ត្រីច្រើនជាង។ ជារួម រាល់ការប្រព្រឹត្តទាំងឡាយណា ដែលធ្វើទុក្ខទោសលើរាង្គកាយសតិ-អារម្មណ៍ ឬការធ្វើទុក្ខទោសលើផ្លូវភេទ ឬការឈឺចាប់ការគំរាមកំហែងក្នុងការប្រើអំពើទាំងនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាព។"

គួរធ្វើការកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា មិនបានបង្ហាញការដោះស្រាយលើអនុសាសន៍ទូទៅ ១៩ នៅក្នុងរបាយការណ៍ជាតិនោះទេ។

ស្ត្រីនៅកម្ពុជា ទទួលរងអំពើហិង្សាលើយេនឌ័រនៅស្ទើរគ្រប់ទិដ្ឋភាពនៃជីវិត។ ទស្សនៈវប្បធម៌ និងប្រពៃណីដែលមានចំពោះស្ត្រីត្រូវបានចងក្រងនៅក្នុងច្បាប់ស្រីជំរុញឲ្យស្ត្រី ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់បុរស។ ជាលទ្ធផល ស្ត្រីពុំសូវមានវត្តមាននៅក្នុងជីវភាពនយោបាយ ឬក្នុងតំណែងជាអ្នកដឹកនាំផ្សេងៗនោះទេ។ អំពើហិង្សាក្នុងគ្រួសារ ការបៀតបៀនផ្លូវភេទ អំពើជួញដូរផ្លូវភេទ និងអំពើជួញដូរមនុស្ស បញ្ហាទាំងអស់នេះបានកើតមានឡើងទូទៅនៅកម្ពុជា។ ស្ត្រីប្រឈមនឹងអំពើហិង្សា ដែល

## អនុសាសន៍:

- ផ្ដល់ការបណ្ដុះបណ្ដាលដល់អាជ្ញាធរឲ្យចេះផ្ដន្ទាទោសនូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី រួមមាន អំពើជួញដូរផ្លូវភេទ អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ។ តាមបទសម្ភាសន៍របស់យើង បានរកឃើញថា ជារឿយៗអាជ្ញាធរចូលរួម នៅក្នុងគម្រោងជួញដូរមនុស្ស ដូច្នេះធ្វើឲ្យជនល្មើសរួចផុតពីការដាក់ទោស។
- បង្កើនការបណ្ដុះបណ្ដាលជំនាញដឹកនាំ និងបង្កើនឱកាសសម្រាប់ស្ត្រី ដើម្បីធ្វើការផ្លាស់ប្ដូរចេញនូវទស្សនៈវប្បធម៌ដែលឲ្យតម្លៃស្ត្រីទាបជាងបុរស។
- កែលំអរប្រព័ន្ធអប់រំ និងលើកទឹកចិត្តកុមារីឲ្យបន្តការសិក្សា។

ការប្រឈមនេះកើតចេញពីទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងកើតចេញពីអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់។

នៅប្រទេសកម្ពុជា អំពើហិង្សាក្នុងគ្រួសារកើតមានជាទូទៅ ទាំងនៅភ្នំពេញ និងតាមតំបន់ជនបទនានា។ មានការផ្តន្ទាទោសតិចតួចចំពោះជនល្មើសដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ មួយផ្នែកបណ្តាលមកពីអំពើពុករលួយ នៅក្នុងប្រព័ន្ធច្បាប់ ព្រមទាំងកង្វះការយល់ដឹងផ្នែកច្បាប់ ជាពិសេសនៅតាមតំបន់ជនបទ។ អស្ថេរភាពផ្នែកហិរញ្ញវត្ថុ គឺជាមូលហេតុចម្បង ដែលរារាំងស្ត្រីក្នុងការដាក់ពាក្យបណ្តឹងសុំលែងលះ។

អំពើជួញដូរផ្លូវភេទ គឺជាបញ្ហាដ៏ធំមួយនៅកម្ពុជា។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងនៅក្នុងឆ្នាំ២០១២ ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលធ្វើការដើម្បីសិទ្ធមនុស្សបានរកឃើញថា ជនល្មើសដែលត្រូវបានចោទប្រកាន់ពីបទជួញដូរផ្លូវភេទទាំងអស់ គឺមានត្រឹមតែ ២៣% ប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន។ ក្មេងស្រីខ្លះដែលជាអនីតិជន ក្មេងស្រីខ្លះទៀតមានអាយុត្រឹម ៥ ឆ្នាំ ប៉ុណ្ណោះ ត្រូវបានឪពុកម្តាយ ឬសាច់ញាតិរបស់ពួកគេលក់ទៅឲ្យអាជីវកម្មផ្លូវភេទ។ ឧបសគ្គចម្បងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរផ្លូវភេទ និងអំពើពេស្យាកម្មដោយបង្ខំនៅកម្ពុជា គឺដោយសារអាជីវកម្មផ្លូវភេទរកប្រាក់ចំណូលបានច្រើន ហើយមន្ត្រីរដ្ឋាភិបាល និងនគរបាលក៏ទទួលបានផលប្រយោជន៍ពីរបរនេះផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៅតែកើតមានឡើង និងបានលើកឡើងនូវកម្មវិធីសមស្របមួយចំនួន ដើម្បីលុបបំបាត់បញ្ហានេះ ដូចជា "ពង្រឹងសមត្ថភាពតុលាការក្នុងការចាត់ការពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងករណីជួញដូរមនុស្សឲ្យកាន់តែមានភាពច្បាស់លាស់ និងមានប្រសិទ្ធិភាព" និង "ជំរុញឲ្យមានការស្វែងរក និងការស៊ើបអង្កេតឲ្យកាន់តែសកម្មលើករណីជួញដូរមនុស្សនានា។" ក៏ប៉ុន្តែ រដ្ឋាភិបាលមិនបានលំអិតឲ្យបានច្បាស់លាស់អំពីវិធីសាស្ត្រ ដែលនឹងធ្វើឲ្យសម្រេចនូវគោលដៅទាំងនេះនោះទេ។

អំពើហិង្សាលើយេនឌ័រ ក៏កើតមានផងដែរនៅក្នុងផ្នែកផ្សេងៗនៃជីវភាពរស់នៅ ដូចជា នៅក្នុងផ្នែកអប់រំជាដើម។ កុមារីត្រូវបានឈប់រៀនដើម្បីជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ។យោងតាមបទសម្ភាសន៍របស់យើងបានឲ្យដឹងថា ឪពុកម្តាយទំនងជាឈប់ឲ្យកូនស្រីទៅរៀនជាជាងកូនប្រុស។ កុមារីខ្លះ ត្រូវធ្វើដំណើរផ្លូវឆ្ងាយទៅសាលារៀន ហើយនៅតាមផ្លូវអាចជួបនឹងគ្រោះថ្នាក់ ដូច្នេះហើយទើបឪពុកម្តាយជាច្រើនសំរេចចិត្តទុកកូនស្រីឲ្យនៅផ្ទះ។

**អំពើជួញដូរផ្លូវភេទ គឺជាបញ្ហាដ៏ធំមួយនៅកម្ពុជា។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងនៅក្នុងឆ្នាំ២០១២ ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលធ្វើការដើម្បីសិទ្ធមនុស្សបានរកឃើញថា ជនល្មើសដែលត្រូវបានចោទប្រកាន់ពីបទជួញដូរផ្លូវភេទទាំងអស់ គឺមានត្រឹមតែ ២៣% ប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន។ ក្មេងស្រីខ្លះដែលជា អនីតិជន ក្មេងស្រីខ្លះទៀតមានអាយុត្រឹម ៥ ឆ្នាំ ប៉ុណ្ណោះ ត្រូវបានឪពុកម្តាយ ឬសាច់ញាតិរបស់ពួកគេលក់ទៅឲ្យអាជីវកម្មផ្លូវភេទ។ ឧបសគ្គចម្បងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរផ្លូវភេទ និងអំពើពេស្យាកម្មដោយបង្ខំនៅកម្ពុជា គឺដោយសារអាជីវកម្មផ្លូវភេទរកប្រាក់ចំណូលបានច្រើន ហើយមន្ត្រីរដ្ឋាភិបាល និងនគរបាលក៏ទទួលបានផលប្រយោជន៍ពីរបរនេះផងដែរ។**

គាំទ្រដោយៈ

The Cambodian Committee of Women
(CAMBOW)

E–mail: ngocedaw.pnh@gmail.com
Website: www.ngocedaw.org Facebook: www.facebook.com/ngocedaw